សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការបង្កើនទិន្នផលស្រូវតាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រ

ករណីសិក្សា៖ ស្ថានីយន៍បូមទឹកស្រោចស្រពទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ពុំ ឌីណា** | បណ្ឌិត **ចាន់ ស៊ុនដេត** |
| **កៅ គឹមជុន** | |
| ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ឆ្នាំចូលសិក្សា ២០១៤ |
| ជំនាន់ទី ២ | ឆ្នាំសរសេរសារណា ២០១៨ |

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំ **ពុំ ឌីណា** និង **កៅ គីមជុន** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមប្រណិបត្តិសំដែងនូវសេចក្ដីកត្តញ្ញូតាធម៌ដឹងគុណ និងសូមគោរពចំពោះ៖

- លោកឪពុក **នុត ណាត** និង អ្នកម្ដាយ **ទូច ស៊ីថា**
- លោកឪពុក **កៅ គីមសេខ** និង អ្នកម្ដាយ **ស៊ឹម សេរី**

ដែលលោកបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់រូបកូនតាំងពីតូច រហូតដល់ធំពេញវ័យ ព្រមទាំងបានផ្ដល់ដំបូន្មានល្អៗដល់រូបកូន ជួយទំនុកបម្រុងទាំងផ្នែកស្មារតី កំលាំងកាយចិត្ត ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ រហូតដល់ពួកយើងបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

- លោកពូ **ឈា ប៊ុនរិទ្ធិ** និង អ្នកមីង **ទូច ម៉ាលីស**

ដែលលោកទាំងពីរមានចិត្តមេត្តាករុណាដល់រូបខ្ញុំ ក្នុងការផ្ដល់កន្លែងស្នាក់នៅ អាហារ សម្ភារៈប្រើប្រាស់ ផ្ដល់ថវិកាបង់ថ្លៃសិក្សា និងការចាយវាយប្រចាំថ្ងៃ ហើយបានផ្ដល់ដំបូន្មានល្អៗជាច្រើនដល់រូបខ្ញុំ។

- ឯកឧត្ដមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានដេប៉ាដឺម៉ង់ ប្រធានការិយាល័យ អនុប្រធានការិយាល័យ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- សាស្ត្រាចារ្យបណ្ឌិត **ខ៉ាន់ ស៊ុនដេត** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរ និងរៀបចំរបាយណ៍ការកម្មសិក្សាបញ្ចប់ការសិក្សានេះ។
- លោកពូ **ឃុន សាឃឿន** អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រៃវែងដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរនាក់បានចុះទៅធ្វើកម្មសិក្សាស្រាវជ្រាវ និងបានផ្ដល់ជាឯកសារដល់ដំណើរការស្រាវជ្រាវនេះ។
- លោកស្រី **គីម លួន** ប្រធានការិយាល័យកសិកម្ម និងលោកពូ **កែវ ស្រេខ** ប្រធានសហគមន៍កសិករប្រើប្រាស់ទឹកស្ថានីយ៍ទី២ ស្រុកព្រះស្ដេច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីអ្នកធ្វើការសម្ភាសន៍ និងផ្ដល់ជាឯកសារដល់ដំណើរការសិក្សាស្រាវជ្រាវនេះ។

# អារម្ភកថា

បើយើងក្រឡេកមើលស្ថានភាពប្រទេសកម្ពុជានាពេលបច្ចុប្បន្នប្រមាណ មួយភាគបីនៃសេដ្ឋកិច្ចជាតិ គឺនៅតែបន្តពឹងផ្អែកលើវិស័យកសិកម្ម បើទោះបីជាអត្រានៃការចូលរួមពីវិស័យឧស្សាហកម្ម និងសេវាកម្មមានកំណើនគួរអោយកត់សំគាល់ក៏ដោយ។ក្រៅពីការចូលរួមចំណែកនៅក្នុងGDP វិស័យកសិកម្មក៏ជាធាតុមួយយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលនយោបាយ កាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយហេតុថាប្រជាពលរដ្ឋជាង ៨០% ដែលរស់នៅតំបន់ជនបទនៅតែបន្តពឹងផ្អែកលើវិស័យកសិកម្មក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

បច្ចុប្បន្នវិស័យកសិកម្ម កំពុងតែទទួលរងនូវការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរពីបំរែបំរួលអាកាសធាតុ និងការកើនឡើងកំដៅនៅលើផែនដី ដែលនាំអោយមានភាពញឹកញាប់នៃគ្រោះរាំងស្ងួត និងទឹកជំនន់ជាដើម។ ហើយការធ្វើកសិកម្មនៅកម្ពុជា ពឹងផ្អែកទាំងស្រុងលើធម្មជាតិ។ ផលិតកម្មកសិកម្មភាគច្រើនស្ថិតនៅជាកសិកម្មបែបយថាផលនៅឡើយ ដោយហេតុថាកសិករភាគច្រើននៅតែបន្តអនុវត្តកសិកម្មតាមបែបប្រពៃណីលើផ្ទៃដីដែលគាត់មាន។ ដោយសារតែភាពខ្វះខាតនៃប្រព័ន្ធស្រោចស្រព និង កង្វះខាតយន្តការនៃការផ្តល់ព័ត៌មានអោយបានទូលំទូលាយទៅដល់កសិករដើម្បីចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានឡើងមកពីការប្រែប្រួលអាកាសធាតុជាដើម។ ការធ្វើស្រែដាំដំណាំមានសកម្មភាពភាគច្រើននៅខែវស្សានៅពេលដែលមានភ្លៀង។ ក្នុងរដូវវស្សា ទឹកនៅតាមតំបន់មួយចំនួនមានច្រើនលើសតម្រូវការ រហូតធ្វើឲ្យជន់លិចថែមទៀតផង។ លុះដល់ខែប្រាំង ដីប្រែបែកក្រហែងព្រោះខ្វះទឹក ចំណែកដំណាំសព្វមុខប្រែជាក្រៀមស្រពោន ហើយប្រព័ន្ធធារាសាស្ត្រខ្លះមានសភាពចាស់ទ្រុឌទ្រោម ដែលមានការលំបាកដល់ការរក្សាទឹក ការបែងចែកទឹក ការផ្តល់ទឹកសម្រាប់វិស័យកសិកម្ម និងការរស់នៅប្រចាំថ្ងៃ។ ដោយសារតែខ្វះទឹក កសិករខ្មែរភាគច្រើនត្រូវបង្ខំចិត្តផ្អាកធ្វើកសិកម្ម ហើយទុកដីឲ្យទំនេរចោលពេញមួយរដូវប្រាំងតែម្តង។ នៅតំបន់ខ្លះដែលជួបប្រទះភាពរាំងស្ងួតខ្លាំងមែនទែន កុំថាឡើយដល់ទឹកធ្វើស្រែ សូម្បីតែទឹកសម្រាប់បម្រើដល់ការប្រើប្រាស់ប្រចាំថ្ងៃក៏រកមិនបានផង។

ដោយយល់ឃើញពីសារៈសំខាន់ និងអត្ថប្រយោជន៍របស់ដំណាំស្រូវ ទើបក្រុមរបស់យើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទដែលមានចំណងជើងថា "ការបង្កើនទិន្នផលស្រូវតាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រ" របស់ស្ថានីយ៍បូមទឹកផ្គត់ផ្គង់ការស្រោចស្រពទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ខេត្តព្រៃវែងមកធ្វើការសិក្សាស្រាវជ្រាវ។

យើងខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវនេះមិនត្រឹមតែអាចបំពេញសេចក្តីត្រូវការ នៃការចង់ដឹងចង់ឮ របស់អ្នកអានប៉ុណ្ណោះទេ តែវាជាជ្រុងមួយនៃគំនិតដែលមានសារៈសំខាន់សម្រាប់ការសិក្សាស្វែងយល់ និងទុកជាទុនខាងចំណេះដឹងសម្រាប់ការអភិវឌ្ឍដំណាំស្រូវរបស់ប្រទេសកម្ពុជា ដើម្បីឱ្យប្រជាកសិករអាចទទួលបានទិន្នផលខ្ពស់។

ជាចុងក្រោយ យើងខ្ញុំក៏សូមអភ័យទោសចំពោះកំហុសខុសឆ្គងដែលកើតឡើងដោយអចេតនា និងសូមស្វាគមន៍រាល់ពាក្យរិះគន់ពីសំណាក់អ្នកអាន ដើម្បីធ្វើការកែលម្អរឯកសារនេះឱ្យកាន់តែប្រសើរឡើងថែមទៀត។

# មាតិកា

**ទំព័រ**

បញ្ជីតារាង ........ v
បញ្ជីរូបភាព ........ v
បញ្ជីក្រាហ្វិក ........ v

## សេចក្តីផ្តើម

១. កម្មវត្ថុស្រាវជ្រាវ ........ ២
២. សំណួរស្រាវជ្រាវ ........ ៣
៣. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៤
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១
## រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងធារាសាស្ត្រ

១.១ និយមន័យ ........ ៥
១.២ ប្រភេទនៃប្រព័ន្ធធារាសាស្ត្រ ........ ៦
១.២.១ ប្រព័ន្ធធារាសាស្ត្រនៅលើផ្ទៃដី ........ ៧
១.២.២ ប្រព័ន្ធធារាសាស្ត្រដោយប្រើម៉ាស៊ីនស្រោចស្រព ........ ៨
១.២.៣ ប្រព័ន្ធធារាសាស្ត្រដោយការប្រើប្រាស់ការបន្តក់ទឹក ........ ៨
១.៣ ប្រវត្តិនៃប្រព័ន្ធធារាសាស្ត្រ ........ ៨
១.៣.១ ប្រវត្តិប្រព័ន្ធធារាសាស្ត្រនៅលើពិភពលោក ........ ៨
១.៣.២ បទពិសោធន៍របស់ប្រទេសដែលទទួលបានជោគជ័យលើប្រព័ន្ធធារាសាស្ត្រ ........ ៩
១.៣.២.១ បទពិសោធន៍ប្រទេសថៃ ........ ៩
ក. ប្រវត្តិប្រព័ន្ធធារាសាស្ត្រ ........ ៩
ខ. ស្ថានភាពប្រព័ន្ធធារាសាស្ត្រ ........ ១១
គ. គោលនយោបាយជាតិលើវិស័យធនធានទឹក ........ ១១

ឃ. ការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ........................................................ ១៣
ង.ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព ........................... ១៥
១.៣.២.២ បទពិសោធន៍ប្រទេសវៀតណាម ........................................................ ១៦
ក. ស្ថានភាពប្រព័ន្ធធារាសាស្ត្រ ........................................................... ១៦
ខ. បញ្ហាប្រឈមលើប្រព័ន្ធធារាសាស្ត្រ........................................................ ១៧
គ. គោលនយោបាយលើការគ្រប់គ្រងធនធានទឹក .................................... ១៧
ឃ. ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព ........................... ១៨
១.៤. ប្រវត្តិប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា............................................................... ១៩
១.៤.១ ប្រព័ន្ធធារាសាស្ត្រសម័យអង្គរ............................................................... ២០
១.៤.២ ប្រព័ន្ធធារាសាស្ត្រសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣) ........................... ២១
១.៤.៣ ប្រព័ន្ធធារាសាស្ត្រសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ........................... ២២
១.៤.៤ ប្រព័ន្ធធារាសាស្ត្រសម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ........................... ២៤
១.៤.៥ ប្រព័ន្ធធារាសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ..................... ២៥
១.៤.៦ ប្រព័ន្ធធារាសាស្ត្រសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)........ ២៦
១.៥ ស្ថានភាពប្រព័ន្ធធារាសាស្ត្រនាពេលបច្ចុប្បន្ន................................................... ២៦
១.៥.១ ទំហំខ្នាតនៃប្រព័ន្ធធារាសាស្ត្រ............................................................... ២៨
១.៥.២ អត្ថប្រយោជន៍របស់ប្រព័ន្ធធារាសាស្ត្រ ..................................................... ២៨
១.៥.៣ បញ្ហាប្រឈមលើប្រព័ន្ធធារាសាស្ត្រ ........................................................ ២៨
១.៥.៤ គោលនយោបាយលើការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ................ ៣០
១.៥.៥ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព.................................. ៣២
១.៥.៦ ការពង្រឹងសមត្ថភាពស្ថាប័នលើវិស័យធនធានទឹក ....................................... ៣៤
១.៥.៧ គោលនយោបាយហិរញ្ញវត្ថុលើវិស័យធនធានទឹក........................................ ៣៤
១.៦ សេចក្តីសន្និដ្ឋាន....................................................................................... ៣៦

## ជំពូកទី២

## ស្ថានភាពទូទៅនៃប្រព័ន្ធស្រោចស្រពកំពង់ត្របែក

២.១. ប្រវត្តិនៃការកកើត និងទីតាំងភូមិសាស្ត្រប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ........................... ៣៧

២.២. ការអភិវឌ្ឍប្រព័ន្ធប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ........ ៣៨
២.២.១ ដំណើរការសាងសង់ ........ ៣៨
២.២.២ ការគ្រប់គ្រងកិច្ចដំណើរការ និងការជួសជុលថែទាំ ........ ៣៩
២.៣ ស្ថានភាពទូទៅនៅក្នុងតំបន់ធ្វើការស្រាវជ្រាវ ........ ៤១
២.៣.១ ស្ថានភាពនៃស្ថានីយ៍បូមស្រោចស្រពទី២ ........ ៤១
២.៣.២ ស្ថានភាពដំណាំស្រូវ ........ ៤១
២.៣.៣ ការប្រើប្រាស់ទឹក ........ ៤២
២.៤ អត្ថប្រយោជន៍ដែលទទួលបានក្រោយពីការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ........ ៤៣
២.៥ គោលដៅបន្តនាពេលអនាគត ........ ៤៣
២.៦ សេចក្តីសន្និដ្ឋាន ........ ៤៤

## ជំពូកទី៣
## ការវិភាគទិន្នន័យ

៣.១. វិធីសាស្ត្រវិភាគ ........ ៤៥
៣.១.១ ប្រៀបធៀបទិន្នផលស្រូវមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ ... ៤៥
៣.១.២ ប្រៀបធៀបចំណូលមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ ........ ៤៧
៣.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារក្រោយមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ........ ៤៨
៣.៣ អត្រាទាញរកភាគចំណេញផ្ទៃក្នុង នៃការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ (Internal Rate of Return = IRR) ........ ៤៩
៣.៤ បញ្ហាប្រឈម និងដំណោះស្រាយ ........ ៥១
៣.៤.១ បញ្ហាប្រឈម ........ ៥១
៣.៤.១.១ កង្វះខាតហិរញ្ញវត្ថុ ........ ៥១
៣.៤.១.២ ការចូលរួមរបស់កសិករក្នុងការគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត ........ ៥២
៣.៤.១.៣ កង្វះប្រឡាយរង ........ ៥២
៣.៤.២ ដំណោះស្រាយលើបញ្ហាប្រឈម ........ ៥២
៣.៤.២.១ ហិរញ្ញវត្ថុ ........ ៥២

៣.៤.២.២ ការចូលរួមរបស់កសិករក្នុងការគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ...៥២
៣.៤.២.៣ ប្រឡាយរង ........................................................................................៥២
៣.៥ លទ្ធផលស្រាវជ្រាវ ........................................................................................................ ៥៣

## សេចក្តីសន្និដ្ឋាន

១. សេចក្តីសន្និដ្ឋាន ........................................................................................................................៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

## បញ្ជីតារាង

តារាង១៖ បម្រែបម្រួលទិន្នផលស្រូវ មុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ.........៤៥
តារាង២៖ ចំណូលរបស់ប្រជាកសិករមុនមានការពង្រីកប្រព័ន្ធធារាសាស្ត្រ................................. ៤៧
តារាង៣៖ ចំណូលរបស់ប្រជាកសិករក្រោយមានការពង្រីកប្រព័ន្ធធារាសាស្ត្រ........................... ៤៧
តារាង៤៖ បម្រែបម្រួលចំណូលកសិករមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ..... ៤៧
តារាង៥៖ ចំណាយ និងចំណូលលើផលិតកម្មស្រូវ ...................................................................៥០
តារាង៦៖សរុបការចំណាយ និងចំណូលលើផលិតកម្មស្រូវ ទាញពីតារាង៥ ...............................៥០
តារាង៧៖ ចំណេញពីផលិតកម្មស្រូវប្រចាំឆ្នាំ ទាញចេញពីតារាង ៦ ...........................................៥១

## បញ្ជីរូបភាព

រូបភាព១៖ ទិដ្ឋភាពនៃការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក............................. ៣៩
រូបភាព២៖ ទិដ្ឋភាពនៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែកដែលបានស្តារ និងសាងសង់ហើយ........... ៣៩
រូបភាព៣៖ ផែនទីបង្ហាញពីទីតាំងប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក............................................. ៣៩
រូបភាព៤៖ ផែនទីបង្ហាញពីប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ...................................................... ៣៩
រូបភាព៥៖ សកម្មភាពរបស់មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានធារាសាស្ត្រកសិកម្ម និងមន្ទីរ
ធនធានទឹក និងឧតុនិយម ខេត្តព្រៃវែងចុះធ្វើការកែលម្អរ និងជួសជុលថែទាំប្រចាំ ......៤១
រូបភាព៦៖ ទិដ្ឋភាពរបស់ស្ថានីយ៍បូមទឹកស្រោចស្រពទី២ ..........................................................៤១
រូបភាព៧៖ ស្ថានភាពដំណាំស្រូវនៅក្នុងតំបន់ស្រាវជ្រាវ ............................................................៤២
រូបភាព៨៖ ការទាញយកទឹកពីប្រឡាយរបស់ប្រជាកសិករនៅក្នុងរដូវប្រាំង ................................៤២

## បញ្ជីក្រាហ្វិក

ក្រាហ្វិក១៖ ទិន្នផលស្រូវប្រចាំឆ្នាំគិតជាមធ្យមក្នុងមួយហិកតា (តោន).......................................៤៦

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានផ្ទៃដី ១៨១.០៣៥គម² មានស្ថានភាពដីរាបស្មើនៅកណ្តាល និងព័ទ្ធជុំវិញដោយភ្នំ និងខ្ពង់រាប។ ក្នុងនោះផ្ទៃដីប្រមាណ ២៥.០៦៩គម² ជាដីទំនាប ៦៧.៦៦៨គម² ត្រូវបានហ៊ុមព័ទ្ធនៅជុំវិញបឹងទន្លេសាប ដែលជាប្រភពយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ដីដែលមានជីជាតិ សម្រាប់ការប្រកបរបរកសិកម្ម និង ៦៨.០៦១គម² ជាដីភ្នំនិងខ្ពង់រាប ហើយកំណើនសេដ្ឋកិច្ចមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាមួយអត្រាជាមធ្យមប្រមាណ ៧%។[1] ស្រូវគឺជាដំណាំដ៏សំខាន់ណាស់នៅកម្ពុជា ដោយដំណាំនេះបានគ្របដណ្តប់លើផ្ទៃដីដាំដុះអស់ប្រមាណ ៨០% និងជាទំនិញកសិកម្មនាំចេញសំខាន់បំផុត។ ស្រូវ មានតួនាទីដ៏សំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា។ ទោះបីជាមានការចូលរួមយ៉ាងច្រើនពីវិស័យឧស្សាហកម្ម និងសេវាកម្មនៅក្នុងផលិតផលក្នុងស្រុកសរុបក៏ដោយ ក៏វិស័យកសិកម្មនៅតែជាវិស័យដែលមានអាទិភាពខ្ពស់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍប្រទេសជាតិរបស់រាជរដ្ឋាភិបាល។

សព្វថ្ងៃប្រទេសកម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ចជាតិ ពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម ដែលប្រជាពលរដ្ឋជាង ៨០% រស់នៅតាមជនបទគឺធ្វើការប្រកបរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត។ ប៉ុន្តែ ការធ្វើកសិកម្មនៅកម្ពុជា ពឹងផ្អែកទាំងស្រុងលើធម្មជាតិ មានន័យថាការធ្វើស្រែដាំដំណាំមានសកម្មភាពច្រើននៅខែវស្សាដែលមានភ្លៀង។ ក្នុងរដូវវស្សា ទឹកនៅតាមតំបន់មួយចំនួនមានច្រើនលើសតម្រូវការ រហូតធ្វើឲ្យជន់លិចថែមទៀត។ លុះដល់ខែប្រាំង ដីប្រែបែកក្រហែងព្រោះខ្វះទឹក ចំណែកដំណាំសព្វមុខប្រែជាក្រៀមស្រពោន ហើយប្រព័ន្ធធារាសាស្ត្រខ្លះមានសភាពចាស់ទ្រុឌទ្រោម ដែលមានការលំបាកដល់ការរក្សាទឹក ការបែងចែកទឹក ការផ្តល់ទឹកសម្រាប់វិស័យកសិកម្ម និងការរស់នៅប្រចាំថ្ងៃ។ ដោយសារតែខ្វះទឹក កសិករខ្មែរភាគច្រើនត្រូវបង្ខំចិត្តផ្អាកធ្វើកសិកម្ម ហើយទុកដីឲ្យទំនេរចោលពេញមួយរដូវប្រាំងតែម្តង។

ដោយទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់វិស័យកសិកម្ម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍជាតិ ដោយផ្តោតលើការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ តាមរយៈការបង្កើនផលិតភាពកសិកម្មដើម្បីធានានូវស្ថេរភាពសន្តិសុខស្បៀង ការបង្កើតការងារ និងការបង្កើនចំណូលដល់គ្រួសារកសិករដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

[1] ហោង បូមករា, សារុន ហៃលីដា, ការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម, ២០១៦, ១

## ១. កម្មវត្ថុស្រាវជ្រាវ

ដំណាំស្រូវ គឺជាដំណាំមួយដែលត្រូវបានទទួលស្គាល់ជាសាកលថា មានអាយុកាលរាប់ពាន់ឆ្នាំមកហើយ បើទោះបីជាអាយុកាលនៃការដាំដុះដំបូងបំផុតពុំមានឯកសារអះអាងក៏ដោយ។ ដំណាំស្រូវ គឺជាប្រភពអាហារដ៏សំខាន់នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ចំណីអាហារនៅលើពិភពលោក។ ដែលប្រហែលជាពាក់កណ្ដាលនៃមនុស្សនៅលើពិភពលោក ជាពិសេសបណ្ដាប្រទេសនៅអាស៊ីបានរស់ពឹងផ្អែកលើ ស្រូវជាអាហារសំខាន់បំផុតរបស់ពួកគេ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្រូវត្រូវបានចាត់ទុកជាដំណាំសំខាន់ និងជាអាហារចាំបាច់បំផុតដែលផ្ដល់ថាមពលសម្រាប់ទ្រទ្រង់ជីវិតរបស់មនុស្ស។ ប្រជាពលរដ្ឋខ្មែរ ចាត់ទុកថាស្រូវគឺជាព្រះមេ ព្រោះស្រូវ ជាអាហារដែលមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋគ្រប់ៗរូប ដូច្នេះហើយ បានជាបុព្វបុរសយើងតែងតែទូន្មានប្រៀនប្រដៅ កុំឱ្យជាន់លើអង្ករ ឬខ្ជះខ្ជាយទោះបីជាមួយគ្រាប់ក្ដី។

ដំណាំស្រូវ មិនត្រឹមតែជាអាហារចាំបាច់សម្រាប់ទ្រទ្រង់រាងកាយនោះទេ ប៉ុន្តែស្រូវ ថែមទាំងបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងសង្គមដូចជា បង្កើតទីផ្សារការងារជាច្រើនដល់ប្រជាពលរដ្ឋ បង្កើនប្រាក់ចំណូលដល់ប្រជាកសិករដែលរស់នៅតាមតំបន់មូលដ្ឋាន លើកស្ទួយប្រពៃណីវប្បធម៌សាមគ្គីធម៌ ពង្រឹងស្ថេរភាពនយោបាយ លើកស្ទួយ និងថែរក្សាបរិស្ថានធម្មជាតិ ជាពសេសចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា ឱ្យមានភាពរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ផងដែរ។ បច្ចុប្បន្ននេះ ដំណាំស្រូវបានជួបប្រទះនឹងបញ្ហាជាច្រើនដូចជា៖

- ការប្រែប្រួលអាកាសធាតុ ដែលពេលខ្លះមានទឹកជំនន់ និងពេលខ្លះទៀតក៏មានភាពរាំងស្ងួត។
- កង្វះកម្លាំងពលកម្ម ដោយសារតែការធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសគេ ដើម្បីស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់ដល់គ្រួសារ។
- កង្វះខាតបច្ចេកទេសក្នុងការដាំដុះ ប្រជាកសិករភាគច្រើនអនុវត្តទៅតាមបទពិសោធន៍ និងចំណេះដឹងដែលទទួលបានពីឪពុក ម្ដាយ ឬសមាជិកក្នុងក្រុមគ្រួសារ។
- កង្វះខាតហិរញ្ញវត្ថុ ភាគច្រើននៃប្រជាកសិករមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទិញវត្ថុធាតុដើម សម្រាប់ផ្គត់ផ្គង់ក្នុងដំណើរការដាំដុះដំណាំស្រូវ។
- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ដែលពិបាកក្នុងការធ្វើដំណើរទៅមក ជាពិសេសមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពដំណាំ ដោយសារមិនមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់។

ដោយសារតែបញ្ហាប្រឈមខាងលើនេះហើយ ទើបបានធ្វើឱ្យដំណាំស្រូវមិនសម្រេចបាន

ទៅតាមការរំពឹងទុករបស់ប្រជាកសិករ ក៏ដូចជាតាមផែនការដែលបានគ្រោងទុករបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ យ៉ាងណាមិញ យើងសង្កេតឃើញថា ស្រូវមានសារៈសំខាន់ណាស់ដោយស្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា។

ដោយយល់ឃើញពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនរបស់ដំណាំស្រូវ ទើបក្រុមរបស់យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទដែលមានចំណងជើងថា "ការបង្កើនទិន្នផលស្រូវតាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រ" មកធ្វើការសិក្សាស្រាវជ្រាវ។

## ២. សំណួរស្រាវជ្រាវ

យ៉ាងណាមិញ បើទោះបីជាមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលក៏ដោយ ទឹកនៅតែជាបញ្ហាចំបងរបស់ប្រជាកសិករដោយសារតែការប្រែប្រួលអាកាសធាតុ និងបញ្ហាផ្សេងៗដែលបង្ករឡើងពីអ្នកប្រើប្រាស់ បានធ្វើឱ្យសមត្ថភាពនៃការស្តុកទឹករបស់ប្រព័ន្ធធារាសាស្ត្រពីមួយថ្ងៃទៅមួយថ្ងៃកាន់ថយទៅៗ ដែលទាមទាឱ្យផ្នែកពាក់ព័ន្ធទាំងអស់ ជាពិសេសរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រឱ្យបានខ្ពស់ ព្រោះថាវាជាចំណុចស្នូលមួយសំខាន់សម្រាប់ការឈានទៅរកការអភិវឌ្ឍវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ខាងក្រោមនេះ គឺជាសំណួរដែលក្រុមរបស់យើងខ្ញុំនឹងធ្វើការស្រាវជ្រាវ៖

តើការពង្រីកប្រព័ន្ធធារាសាស្ត្រធ្វើឱ្យទិន្នផលស្រូវប្រែប្រួលដូចម្តេចខ្លះ?

## ៣. សារៈសំខាន់នៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះបានផ្តល់សារៈសំខាន់ជាច្រើន ដល់សមាជិកក្រុមរបស់យើងខ្ញុំ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺ អត្ថបទនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សង្គមផងដែរក្នុងនោះរួមមាន៖

១. ផ្តល់ជាឯកសារស្រាវជ្រាវ និងបទពិសោធន៍ចំពោះអង្គភាពរដ្ឋបាលសាធារណៈនៅតាមតំបន់ផ្សេងៗ អង្គការ សមាគមន៍ សហគមន៍ និងផ្នែកដែលពាក់ព័ន្ធ សម្រាប់យកទៅប្រើប្រាស់ក្នុងការអភិវឌ្ឍលើវិស័យធនធានទឹកនៅតាមតំបន់របស់ខ្លួន ដើម្បីសម្រេចបាននៅការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

២. ដើម្បីពញ្ញាក់ស្មារតីដល់ផ្នែកដែលពាក់ព័ន្ធ ជាពិសេសរាជរដ្ឋាភិបាល ក្នុងការយកចិត្តទុកដាក់លើការគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។

៣. ផ្តល់ជាឯកសារដល់សិស្ស និស្សិត ឬសាធារណៈជនទូទៅ លើការសិក្សាស្រាវជ្រាវដើម្បីបង្កើនចំណេះដឹងបន្ថែម ជាពិសេសក្នុងគោលបំណងដើម្បីលើកស្ទួយធនធានមនុស្សនៅកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការជ្រើសរើសយកស្ថានីយ៍បូមទឹកស្រោចស្រព ទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ដែលមានទីតាំងស្ថិតនៅក្នុង ភូមិកំពង់ថ្នល់ ឃុំល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែងដើម្បីធ្វើកម្មសិក្សា លើការស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានបទ "ការបង្កើនទិន្នផល ស្រូវតាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រ" ចាប់ពីឆ្នាំ ២០១៥ ដល់ ២០១៧។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក. ទិន្នន័យបឋម៖ ធ្វើការសម្ភាសន៍ជាមួយមន្ត្រីជំនាញក្នុងដំណើរការស្រាវជ្រាវនៅតំបន់មូលដ្ឋាន នៃស្ថានីយ៍បូមទឹកផ្គត់ផ្គង់ការស្រោចស្រពទី២ ដែលមានទីតាំងស្ថិតនៅ ភូមិកំពង់ថ្នល់ ឃុំល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែង។ គោលបំណងនៃការសម្ភាសន៍ គឺដើម្បីដឹងពីព័ត៌មាន សម្រាប់ការយកទៅបកស្រាយលើប្រធានបទ។

ខ. ទិន្នន័យមានស្រាប់៖

- របាយការណ៍របស់ ក្រសួងធនធានទឹក ឧតុនិយម
- របាយការណ៍របស់ មន្ទីរធនធានទឹក ឧតុនិយម ខេត្តព្រៃវែង
- របាយការណ៍របស់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង

គ. វិធីសាស្ត្រវិភាគ៖ ចំពោះទិន្នន័យដែលប្រមូលបានគឺយើងធ្វើការវិភាគតាម Excel ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវនេះ យើងបានធ្វើការបែងចែកជាបួនផ្នែកដូចជា៖

**សេចក្ដីផ្ដើម** ក្រុមយើងខ្ញុំធ្វើការសិក្សាអំពី កម្មវត្ថុ សំណួរ សារៈសំខាន់ ទំហំ និងដែនកំណត់ វិធីសាស្ត្រ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ពាក់ព័ន្ធនឹងប្រធានបទខាងលើ។ **ជំពូកទី១** អ្វីដែលក្រុមយើងខ្ញុំផ្ដោតសំខាន់គឺ ការបកស្រាយអំពីទ្រឹស្ដីដែលពាក់ព័ន្ធទៅនឹងប្រធានបទ។ **ជំពូកទី២** យើងខ្ញុំធ្វើការសិក្សាអំពី ស្ថានភាពទូទៅនៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក និងស្ថានភាពទូទៅនៅក្នុងតំបន់សិក្សាស្រាវជ្រាវ។ ក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក តើប្រជាជនទទួលបានអត្ថប្រយោជន៍ដូចម្ដេចខ្លះពីប្រព័ន្ធធារាសាស្ត្រនេះ? **ជំពូកទី៣** នៅក្នុងផ្នែកនេះ យើងខ្ញុំធ្វើការវិភាគទិន្នន័យ ដែលទទួលបានពីការសម្ភាសន៍ពីមន្ត្រីជំនាញ នៅក្នុងដំណើរការស្រាវជ្រាវ តើទិន្នផលស្រូវ និងប្រាក់ចំណូលប្រជាកសិករប្រែប្រួលដូចម្ដេច មុន និងក្រោយ ពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក។

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងធារាសាស្ត្រ

## ១.១ និយមន័យ

### ក. ស្រូវ

ដំណាំស្រូវ ជាដំណាំមួយដែលត្រូវបានទទួលស្គាល់ជាសាកលថា មានអាយុកាលរាប់ពាន់ឆ្នាំមកហើយទោះបីជាកាលនៃការដាំដុះដំបូងបំផុតហាក់ដូចជាពុំមានឯកសារអះអាងច្បាស់លាស់ ឬត្រូវបានបាត់បង់ក្នុងសម័យបុរេប្រវត្តិក៏ដោយ ។ **ស្រូវ** គឺជាប្រភពដ៏សំខាន់នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ចំណីអាហារពិភពលោក ។ ប្រហែលជាពាក់កណ្តាលនៃមនុស្សនៅលើពិភពលោក ជាពិសេសប្រជាជននៅបណ្តាប្រទេសអាស៊ីបានរស់នៅដោយពឹងផ្អែក លើស្រូវជាអាហារសំខាន់របស់ពួកគេ ។[2] ខាងក្រោមនេះ គឺជានិយមន័យខ្លះនៃពាក្យ ស្រូវៈ

ពាក្យថា "**ស្រូវ**" ដែលបានដកចេញពីស្តង់ដាអង្គរសម្រិតកម្ពុជា បានឱ្យនិយមន័យថា **ស្រូវ** សំដៅដល់គ្រាប់ស្រូវដែលទទួលបានពីការបោកបែនហើយ។[3] **ស្រូវ** ជាគ្រាប់ធុញ្ញជាតិមួយប្រភេទដែលបានផ្តល់នូវសារធាតុជាច្រើន ដល់ការរស់នៅរបស់មនុស្សលោកយើងដែលកំពុងតែរស់នៅសព្វថ្ងៃនេះ ហើយវាក៏ជាចំណីរបស់សត្វជាច្រើនផងដែរ។[4] **ស្រូវ** ជាគ្រាប់ធញ្ញជាតិ ល្អិតតូចៗ ដើមដុះដូចស្បូវ មានដុះជាគួរ មានគ្រាប់ច្រើនសំរាប់យកមកស្រិតធ្វើជាអាហារ មានរស់ជាតិវីតាមីនល្អសម្រាប់ចិញ្ចឹមជីវិត។[5]

### ខ. ប្រព័ន្ធធារាសាស្ត្រ

ពាក្យថា **ធារាសាស្ត្រ** ត្រូវបានគេផ្តល់និយមន័យផ្សេងៗជាច្រើនដែលមានដូចជាៈ អ្នកនិពន្ធសៀវភៅ "គោលការណ៍វិស្វកម្មធារាសាស្ត្រ" លោក **Federick** និងលោក **Daniel** បានបកស្រាយថា ធារាសាស្ត្រ គឺជាដំណើរការ ឬការអនុវត្តនានាសម្រាប់ការផ្គត់ផ្គង់ទឹកបែបសិប្បនិម្មិតឱ្យទៅដល់ដីស្រែចំការ សម្រាប់ធ្វើការដាំដុះ។[6] ពួកគាត់បានបន្ថែមទៀតថា ធារាសាស្ត្រក៏រួមបញ្ចូលទាំងការថែទាំ ការស្តុកទុកទឹក ការទាញយកទឹកពីប្រភពនានា មកក្នុងតំបន់ស្រោចស្រព ហើយធ្វើការចែកចាយទឹកទាំងនោះទៅដល់ដីស្រែចំការ។ បើតាមការបកស្រាយរបស់ការិយាល័យគ្រប់គ្រងបុគ្គលិក របស់សហរដ្ឋអាមេរិក បានឱ្យនិយមន័យនៃពាក្យ **ធារាសាស្ត្រ** ថាជាសមាស

[2] https://choukhmer.wordpress.com/agriculture/rice-production-in-cambodia/rice-economy-and-markets/
[3] http://www.foodsafetyadvisor.cf/2017/08/blog-post_23.html
[4] https://km.wikipedia.org/wiki/អ្នកប្រើប្រាស់:Seangbopha_sc
[5] https://km.wiktionary.org/wiki/ស្រូវ
[6] Fedeick and Daneil, សៀវភៅ "គោលការណ៍វិស្វកម្មធារាសាស្ត្រ",១៩៩៣, ទំព័រ១

ធាតុនៃប្រឡាយទឹក រចនាសម្ព័ន្ធ និងឧបករណ៍នានាដែលពាក់ព័ន្ធក្នុងការដឹកនាំទឹកពីទីកន្លែងដែលសំបូរទឹក ទៅទីកន្លែងដែលមានតម្រូវការទឹក។[7] នៅក្នុងឯកសារស្រាវជ្រាវរបស់សាស្ត្រាចារ្យ **Suat Irmak** នៅសាកលវិទ្យាល័យ **Nabraska-Lincoln** នៃសហរដ្ឋអាមេរិក បានឱ្យនិយមន័យថា **ធារាសាស្ត្រ** គឺជាវិធីសាស្ត្រមួយដែលប្រើសម្រាប់ទាញទឹកពីប្រភពណាមួយ ហើយបញ្ជូនទឹកពីប្រភពនោះ ទៅផ្គត់ផ្គង់ដំណាំតាមរយៈការបង្ហូរទឹកតាមបែបធម្មជាតិ ការកសាងប្រឡាយទឹក ឬការប្រើប្រាស់បំពង់បង្ហូរទឹក។[8] បើតាមលោកសាស្ត្រាចារ្យម្នាក់ឈ្មោះ **Wim Van Averbeke** នៃសាកលវិទ្យាល័យ **Tshwane ប្រព័ន្ធធារាសាស្ត្រ** គឺជាគម្រោងការកសិកម្មដែលពឹងផ្អែកប្រព័ន្ធចែកចាយរួម អាងស្តុកទឹក ឬបរិក្ខាដែលមានលក្ខណៈចម្រុះដើម្បីយកទឹកមកប្រើប្រាស់លើការស្រោចស្រពដំណាំ។[9] លោក **Hargreaves** និង លោក **Merkley** ដែលជាអ្នកនិពន្ធសៀវភៅ គោលការណ៍គ្រឹះនៃធារាសាស្ត្រ បានផ្តល់និយមន័យនៃពាក្យ **ធារាសាស្ត្រ** ថាគឺជាប្រព័ន្ធមួយដែលប្រើសម្រាប់ផ្គត់ផ្គង់ទឹកឱ្យទៅដល់ដំណាំនានា ហើយក៏អាចប្រើសម្រាប់បង្ហូរទឹកដែលលើសចេញពីដីស្រែចំការផងដែរ។[10] ប្រពន្ធធារាសាស្ត្រ គឺជាបណ្តុំនៃសំណង់ទាំងឡាយដែលបំរើឱ្យការងារស្រោចស្រព និងបញ្ចៀសនូវការលិចលង់ផ្សេងៗ។[11]

ដោយសារតែការផ្តល់នូវនិយមន័យលើពាក្យ **ធារាសាស្ត្រ** នេះមានចំនួនច្រើន ដូចនេះនៅក្នុងឯកសារមួយនេះ យើងកំណត់យកនិយមន័យនៃពាក្យ ធារាសាស្ត្រ ថាជាវិធីសាស្ត្រមួយដែលបង្កើតឡើងដោយមនុស្សផ្ទាល់ ដូចជា ការជីកប្រឡាយ ការសាងសង់អាងស្តុកទឹក ឬការប្រើប្រាស់ឧបករណ៍នានា ដើម្បីទាញយកទឹកពីប្រភពផ្សេងៗ ហើយផ្គត់ផ្គង់ទៅលើវិស័យកសិកម្ម និងអាចបង្ហូរទឹកដែលលើសចេញពីផ្ទៃដីដាំដុះបានផងដែរ។

## ១.២ ប្រភេទនៃប្រព័ន្ធធារាសាស្ត្រ[12]

បន្ថែមពីលើនិយមន័យ របស់ប្រព័ន្ធធារាសាស្ត្រ គឺថាប្រព័ន្ធធារាសាស្ត្រ មានច្រើនប្រភេទណាស់ ដែលក្នុងនោះមានដូចជា៖

- ប្រព័ន្ធធារាសាស្ត្រនៅលើផ្ទៃដី

[7] ការិយាល័យបុគ្គលិករបស់សហរដ្ឋអាមេរិក, ១៩៧៩

[8] ឯកសណ្ឋានភាព និងប្រសិទ្ធផលធារាសាស្ត្រ និងការប្រើប្រាស់សម្រាប់ដាំដុះឱ្យមានប្រសិទ្ធផល, ២០១១ ទំព័រ២

[9] Averbeke, W.V., Denison, J. & Mnkeni, PNS. (2011) Smallholder irrigation schemes in south Africa: A review of Knowledge generated by the water research commission . (Definition 1)

[10] Hargreaves, G.H & Merkley, G.H. សៀវភៅ គោលការណ៍គ្រឹះនៃធារាសាស្ត្រ, ១៩៩៨ ទំព័រ២

[11] សៀវភៅស្តីពី ការរៀបចំក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក កិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ, ទំព័រ៧

[12] លោក Brouwer,C, សៀវភៅវិធីសាស្ត្រស្រោចស្រព ២០០១, ទំព័រ ៧-៨

- ប្រព័ន្ធធារាសាស្ត្រដោយប្រើម៉ាស៊ីនស្រោចស្រព
- ប្រព័ន្ធធារាសាស្ត្រដោយប្រើប្រាស់ការបន្តក់ទឹក

### ១.២.១ ប្រព័ន្ធធារាសាស្ត្រនៅលើផ្ទៃដី

ប្រព័ន្ធធារាសាស្ត្រនៅលើផ្ទៃដី គឺជាប្រភេទនៃប្រព័ន្ធធារាសាស្ត្រមួយបែប ដែលគេអាចប្រើប្រាស់លំហូរទឹកនៅលើផ្ទៃដី ដើម្បីយកទឹកនោះមកប្រើប្រាស់ក្នុងការស្រោចស្រពដំណាំ។ ហើយការយកលំហូរទឹកមកប្រើប្រាស់នេះ គេមានវិធីសាស្ត្រជាច្រើនដោយរបៀបផ្សេងៗគ្នាដូចខាងក្រោម៖

- **វិធីសាស្ត្រធ្វើអាងស្តុកទឹក**

វិធីសាស្ត្រធ្វើអាងស្តុកទឹក គឺជាវិធីសាស្ត្រមួយដែលជាទូទៅគេនិយមធ្វើនៅតំបន់ដែលមានដីរាប ហើយជាពិសេសគឺប្រើសម្រាប់ដាំដំណាំស្រូវ។ វិធីសាស្ត្រមួយនេះ គេជីកដីដើម្បីសាងសង់ជាអាងទឹកមួយនៅជិតដីកសិកម្ម ដោយមានបន្ថែមទំនប់ទប់ទឹក ដែលមានលក្ខណៈជាភ្លឺទាបៗ ហើយមានកម្ពស់ចាប់ពី ១០ទៅ២០សង់ទីម៉ែត្រ ដើម្បីការពារទឹកមិនឱ្យហូរចេញពីអាងនោះ។ នៅរដូវវស្សា នៅពេលដែលមានភ្លៀងធ្លាក់ ឬមានទឹកជំនន់ នោះគេអាចស្តុកទឹកទុកបាន ហើយអាចប្រើប្រាស់ទឹកនោះសម្រាប់ធ្វើកសិកម្មនៅរដូវប្រាំង។ ក្នុងករណីដែលទឹកដែលនៅលើដីនោះមានចំណុះច្រើនជាងអ្វីដែលគេត្រូវការ គេអាចបង្ហូរទឹកនោះចេញបានផងដែរ ដោយធ្វើការបើកទឹក ឬកាប់ភ្លឺ។

- **វិធីសាស្ត្រប្រើប្រាស់ប្រឡាយទឹក**

វិធីសាស្ត្រប្រើប្រាស់ប្រឡាយទឹកនេះ គឺគេធ្វើការស្ថាបនាប្រឡាយទឹកដែលមានលក្ខណៈជាប្រឡាយមេធំៗ ឬប្រឡាយរងតូចៗ ដើម្បីនាំយកទឹកពីប្រភពនានាមកស្រោចស្រពដំណាំ។ វាក៏អាចភ្ជាប់ពីអាងស្តុកទឹកដែលគេជីកហើយទៅប្រភពទឹកបានផងដែរ។ វិធីសាស្ត្រមួយនេះអាចជួយដល់ការគ្រប់គ្រងទឹកបានល្អ ពោលគឺវាអាចជួយចែករំលែកទឹកបានច្រើន ហើយអាចជួយការពារការប្រែប្រួលសណ្ឋានដីបានផងដែរ។ លើសពីនេះទៀត វាអាចជួយការពារផ្ទៃដីដាំដុះបានទាំងស្រុង ព្រោះថាគេអាចបង្ហូរទឹកចេញបាន។

- **វិធីសាស្ត្រលើកដីខណ្ឌ**

វិធីសាស្ត្រលើកដីខណ្ឌ គឺគេលើកដីឡើងជារាងចតុកោណដែលមានបណ្ដោយវែង ហើយមានគែមផ្លូវតូចនៅចន្លោះពីចតុកោណមួយ ទៅចតុកោណមួយទៀត។ ផ្លូវតូចៗទាំងនោះ គឺប្រើសម្រាប់ឱ្យទឹកហូរកាត់។ វិធីសាស្ត្រមួយនេះ អាចប្រើប្រាស់បានស្ទើរតែគ្រប់គ្រប់ដំណាំទាំងអស់

លើកលែងតែដំណាំដែលគេដាក់ដាំនៅក្នុងទឹកផ្ទាល់។ គេអាចភ្ជាប់ជាមួយនឹងប្រឡាយទឹកបាន ឬអាចប្រើប្រាស់ម៉ាស៊ីនបូមទឹកក៏បានករណីនៅជិតប្រភពទឹកស្រាប់។

### ១.២.២ ប្រព័ន្ធធារាសាស្ត្រដោយប្រើម៉ាស៊ីនស្រោចស្រព

ការប្រើប្រាស់ម៉ាស៊ីន គឺជាវិធីសាស្ត្រមួយបែបដែលមានលក្ខណៈស្រដៀងទៅនឹងទឹកភ្លៀងបែបធម្មជាតិផងដែរ។ គេអាចធ្វើការចែកចាយទឹកបានដោយប្រើប្រាស់បំពង់បង្ហូរទឹកភ្ជាប់ទៅនឹងឧបករណ៍សម្រាប់ស្រោចស្រព ដែលនៅខាងក្បាលអាចវិលបាន។ បន្ទាប់មក វានឹងបាញ់ទឹកសាចឡើងទៅលើ ហើយធ្លាក់ចុះមកលើផ្ទៃដីដាំដំណាំវិញ។ លើសពីនេះទៅទៀត គេអាចកំណត់ពេលវេលាដែលត្រូវស្រោចស្រព និងបរិមាណទឹកដែលត្រូវស្រោចស្រពបានទៀតផង។ ប្រព័ន្ធធារាសាស្ត្រប្រភេទនេះ អាចប្រើប្រាស់បានចំពោះដំណាំ សណ្ឋានដី និងប្រភេទដីជាច្រើន។

### ១.២.៣ ប្រព័ន្ធធារាសាស្ត្រដោយការប្រើប្រាស់ការបន្តក់ទឹក

វិធីស្រោចស្រពបែបបន្តក់ទឹក គឺគេប្រើប្រាស់ប្រព័ន្ធបន្តក់ទឹកដែលមានបំពង់បង្ហូរតូចៗសម្រាប់បញ្ជូនទឹកទៅបន្តក់នៅកន្លែងដាំដំណាំ។ វិធីសាស្ត្រមួយនេះ អាចជួយសន្សំទឹក និងជីបានច្រើនដោយសារតែ គេបន្តក់ទឹកយឺតៗទៅលើផ្ទៃដី ឬចូលទៅក្នុងឬសដំណាំផ្ទាល់តែម្តង។ ប្រព័ន្ធនេះ មានលក្ខណៈមួយដូចនឹងម៉ាស៊ីនស្រោស្រពដែរ គឺគេអាចកំណត់ពេលវេលា និងបរិមាណទឹកបាន។ វិធីស្រោចស្រពបែបបន្តក់ទឹកនេះ ភាគច្រើនប្រើប្រាស់នៅក្នុងប្រទេសដែលមានបច្ចេកវិទ្យាខ្ពស់ និងមានទឹកតិច។ ដំណាំដែលស្រោចស្រពដោយការបន្តក់ទឹកនេះ គឺឆាប់លូតលាស់បានលឿន ហើយផ្តល់ផលបានខ្ពស់ ព្រោះថាដំណាំទាំងនោះ អាចទទួលបានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ហើយស្លឹករបស់ពួកវាមិនត្រូវបានសើមដូចការស្រោចស្រពដោយប្រើម៉ាស៊ីនស្រោចស្រពទឹកនោះទេ តែវាអាចជួយការពារជំងឺដែលកើតលើស្លឹកបាន។

## ១.៣ ប្រវត្តិនៃប្រព័ន្ធធារាសាស្ត្រ

### ១.៣.១ ប្រវត្តិប្រព័ន្ធធារាសាស្ត្រលើពិភពលោក

នៅក្នុងប្រវត្តិសាស្ត្រ គេបានរកឃើញថាប្រព័ន្ធធារាសាស្ត្រមានតាំងពីយូយារណាស់មក ហើយពោលគឺប្រហែលជា ៤០០០ ទៅ ៦០០០ឆ្នាំមុន គ.ស។ ហើយប្រទេសអេស៊ីប គឺជាប្រទេសមួយដែលបានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រក្នុងវិស័យកសិកម្មដំបូងគេបង្អស់ ហើយប្រទេសនេះបានស្ថាបនាអាងស្តុកទឹក ដោយសាងសង់ទំនប់ទឹកជុំវិញអាង នៅពេលដែលមានទឹកជំនន់ពីទន្លេនីលមក ពួកគេអាចស្តុកទឹកនោះទុកហើយប្រើប្រាស់សម្រាប់ធ្វើកសិកម្ម។[13] ក្រោយមក

[13] Postel, S. (1999). Pillar of sand: Can the irrigation Miracle Last?, W.W. NortonCompany (A Worlwacth Book), New Yok. ដកស្រង់ចេញពីគេហទំព័រ www.worldwacth.org)

ដោយសារតែមានការរីកចម្រើននៃបច្ចេកវិទ្យា បានធ្វើឱ្យប្រព័ន្ធធារាសាស្ត្រមានលក្ខណៈល្អប្រសើរជាងមុន។

គេសង្កេតឃើញថាមានការជីកប្រឡាយទឹក ក្នុងកំឡុងឆ្នាំ១៥០០ មុន គ.ស នឹងការប្រើប្រាស់របាត់ទឹកនៅក្នុងកំឡុងឆ្នាំ៣២៥ មុន គ.ស។ កត្តាបច្ចេកវិទ្យានេះទៀតសោត បានអនុញ្ញាតឱ្យប្រទេសមួយចំនួនផ្សេងទៀតចាប់ផ្តើមបង្កើតនិងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រក្នុងវិស័យកសិកម្មផងដែរ។ ដែលប្រទេសទាំងនោះមានដូចជា ប្រទេសផាស៊ាន ៨០០ ឆ្នាំមុន គ.ស ប្រទេសឥណ្ឌា ៣៥០ ឆ្នាំមុន គ.សប្រទេសសេរីលង្កា ៣០០ ឆ្នាំមុន គ.ស និងប្រទេសចិន ២៥៦ឆ្នាំមុន គ.ស។[14]

### ១.៣.២ បទពិសោធន៍ប្រទេសដែលទទួលបានជោគជ័យលើប្រព័ន្ធធារាសាស្ត្រ

#### ១.៣.២.១ បទពិសោធន៍ប្រទេសថៃ

ថៃជាប្រទេសមួយ ស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែបើនិយាយអំពីវិស័យកសិកម្ម គឺរីកលូតលាស់សម្បើម និងនាំចេញអង្ករក្នុងបរិមាណច្រើន រហូតដល់រាប់សិបលានតោនក្នុងមួយឆ្នាំៗ ដំណាំស្រូវ មិនត្រឹមតែជាដំណាំសំខាន់របស់ប្រទេសថៃប៉ុណ្ណោះទេ ថៃមទាំងជាដំណាំនាំចេញដ៏សំខាន់ទៀតផងសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។ តាំងពីរាប់សិបឆ្នាំមុនមកម្ល៉េះ ប្រទេសថៃនាំមុខគេជានិច្ចខាងនាំអង្ករចេញទៅលក់នៅទីផ្សារអន្តរជាតិ។ តំបន់ដាំស្រូវសំខាន់ជាងគេ គឺនៅតាមដងទន្លេចៅប្រាយ៉ា និងនៅតំបន់វាលទំនាបខូរ៉ា។

កាលពីក្នុងទសវត្សទី៦០ ចំណូលពីវិស័យកសិកម្មមានចំណែក ៤០% នៃចំណូលជាតិសរុប ប៉ុន្តែអាស្រ័យដោយសារការរីកលូតលាស់យ៉ាងឆាប់រហ័សខាងឧស្សាហកម្ម ធ្វើឲ្យចំណូលពីវិស័យនេះធ្លាក់ចុះមកនៅ ១២% កាលពីទសវត្សទី ៨០ និងបច្ចុប្បន្ននៅសល់ក្រោម ៩%។ ក្នុងចំណោមកម្លាំងពលកម្មរបស់ថៃដែលមានប្រមាណ ៣០ លាននាក់ គឺត្រូវវិស័យកសិកម្មស្រូបយក ៥០%។ វិស័យកសិកម្មនៅតែជាវិស័យដែលបង្កើតមុខរបរ និងការងារជូនប្រជាពលរដ្ឋថៃ និងធ្វើឲ្យប្រទេសនេះមានភាពឯករាជម្ចាស់ការផ្នែកគ្រឿងឧបភោគបរិភោគ និងស្បៀងអាហារ (មិនត្រូវការនាំចូលពីក្រៅស្រុក)។ កត្តាសំខាន់ដែលធ្វើឲ្យប្រទេសថៃមានអំណោយផលផ្នែកដាំដំណាំ គឺថៃសម្បូរប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងធនធានទឹកបានល្អ។

##### ក. ប្រវត្តិប្រព័ន្ធធារាសាស្ត្រ[15]

ប្រទេសថៃជាប្រទេសមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយមានផ្ទៃដី ៥៣១.១២០គីឡូម៉ែត្រការេ។ កសិកម្មនៅក្នុងប្រទេសថៃកាលពីសម័យមុន ប្រជាកសិករភាគច្រើន

[14] គណៈកម្មការប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធបង្ហូរទឹកអន្តរជាតិ (ICID),២០០២

[15] Royal Irregation Development (www.ird.go.th)

ពឹងផ្អែកលើការដាំដុះដោយមើលទៅលើទឹកភ្លៀង ដែលជាការដាំដុះបែបប្រពៃណី។ រហូតមកដល់ទសវត្សឆ្នាំ១៨០០ ប្រឡាយត្រូវបានសាងសង់នៅតំបន់ទំនាបកណ្តាលដើម្បីបង្ហូរទឹកពីទន្លេចៅប្រាយ៉ា និងនៅពាក់កណ្តាលនៃទសវត្សនេះ គេក៏បានជីកប្រឡាយផ្សេងទៀត។ ប៉ុន្តែប្រឡាយទាំងនោះ មិនបានបង្កើតជាប្រព័ន្ធធារាសាស្ត្រដែលមានការផ្ទុកទឹកនោះទេ តែទោះជាយ៉ាងណាក៏វាអាចចែកចាយទឹក និងបន្ថែមទឹកដល់កសិករផងដែរ ប៉ុន្តែចំណុះទឹកគឺអាស្រ័យទៅនឹងកម្រិតនៃទឹកទន្លេ។ ដោយសារតែប្រទេសនេះភាគច្រើន ប្រជាកសិករគឺប្រើប្រាស់ដីក្នុងការធ្វើកសិកម្ម ដែលជាហេតុនាំឱ្យរាជរដ្ឋាភិបាលបានបង្កើតនូវនាយកដ្ឋានធារាសាស្ត្រ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលដែលមាននៅក្នុងប្រវត្តិសាស្ត្រនៃការអភិវឌ្ឍ។ ការអភិវឌ្ឍធនធានទឹក ដែលមានទម្រង់ជាសាកល និងជាប្រព័ន្ធនោះ គឺកើតមាននៅក្នុងរជ្ជកាលព្រះបាទ ជូឡាឡុងកន ឬស្តេចរាមាទី៥ នៃរាជវង្សរតនៈ។ ព្រះអង្គបានបង្កើតឱ្យមាននូវ នាយកដ្ឋានប្រឡាយ នៅក្នុងព.ស ១៩៤៥ (គ.ស១៩០២) ដោយមានការទទួលខុសត្រូវលើ ការថែទាំប្រឡាយ និងដើម្បីបង្ការពេលប្រឡាយនោះរាក់ និងធានាឱ្យមានភាពសមស្របដល់ការស្តុកទឹកសម្រាប់បម្រើឱ្យវិស័យកសិកម្ម និងការដឹកជញ្ជូននៅក្នុងតំបន់។

ក្រោយមកទៀត នៅក្នុងរជ្ជកាលព្រះបាទ **Mongkulklao** ឬព្រះបាទរាមាទី៦ ព្រះអង្គបានធ្វើការកែសម្រួលរាល់សកម្មភាពរបស់នាយកដ្ឋានប្រឡាយ។ នៅឆ្នាំ១៩១៤ ព្រះអង្គបានតែងតាំងលោក **RCRWilson** ដែលជាវិស្វករជនជាតិអង់គ្លេស ជានាយកទូទៅនៃនាយកដ្ឋាននោះ។ នាយកដ្ឋានបានចាប់ផ្តើមធ្វើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ដើម្បីឱ្យស្របជាមួយគោលការណ៍បច្ចេកទេសក្នុងទិសដៅបង្កើនការដាំដុះ និងបានអនុវត្តគម្រោងនៃប្រព័ន្ធធារាសាស្ត្រនៅភាគខាងត្បូងតំបន់ផាសាក ដោយធ្វើការសាងសង់ប្រឡាយដែលមានទ្រង់ទ្រាយធំនៅទូទាំងទន្លេផាសាក ដែលជាប្រឡាយដំបូងគេនៃប្រទេសថៃ ដែលបានសាងសង់ទៅតាមគោលការណ៍វិស្វកម្មទំនើប ហើយបានដាក់ឈ្មោះថា ប្រឡាយរាមាទី៦ ដែលមានទីតាំងស្ថិតនៅទីក្រុងលូង នៃខេត្តអយុធ្យា។ ក្រោយមកទៀត នៅក្នុងរជ្ជកាលព្រះបាទ **Phrapokklao** ឬព្រះបាទរាមាទី៧ ដែលព្រះអង្គបានចាត់ទុកថា ការងារដែលបានធ្វើដោយនាយកដ្ឋានពីមុន មិនត្រឹមតែជាបញ្ហាចម្បងនោះទេ តែវាជាការព្រួយបារម្ភមួយនៅក្នុងការជីកប្រឡាយទឹក និងការចែកចាយ ក៏ដូចជាការប្រមូលទឹកនៅក្នុងតំបន់ដាំដុះផងដែរ។ ក្រោយយល់ឃើញដូច្នេះហើយ ព្រះអង្គបានប្តូរឈ្មោះ នាយកដ្ឋាននោះទៅជានាយកដ្ឋានភូមិន្ទធារាសាស្ត្រ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩២៧ ។ ចាប់ពីពេលនោះមក ការអភិវឌ្ឍធនធានទឹកបានបន្តការរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

### ខ. ស្ថានភាពប្រព័ន្ធធារាសាស្ត្រ

នៅក្នុងផលិតកម្មស្រូវប្រាំងរបស់ប្រទេសថៃ ក៏ដូចជានៅតំបន់អាស៊ីអាគ្នេយ៍ គឺពឹងផ្អែកទៅលើប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រព។ ហើយប្រព័ន្ធធារាសាស្ត្រពេលបច្ចុប្បន្នមិនដូចសម័យមុនទេ ព្រោះប្រព័ន្ធធារាសាស្ត្រពីមុន គឺសាងសង់សម្រាប់តែរដូវវស្សា ប៉ុន្តែប្រព័ន្ធធារាសាស្ត្របច្ចុប្បន្ន គឺគេសង់សម្រាប់ទាំងរដូវប្រាំង និងរដូវវស្សា។ ប្រព័ន្ធធារាសាស្ត្រនីមួយៗ មានការកសាងជាលក្ខណៈប្រឡាយមេធំៗ ដែលអាចយកទឹកពីទន្លេសំខាន់ៗ ដែលធ្វើឱ្យមានប្រភពទឹកគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ទឹកសស្រោចស្រព និងអាចធ្វើការរំដោះទឹកចេញពីស្រែបានផងដែរនៅពេលមានទឹកជន់លិចម្តងៗ។ ប្រព័ន្ធធារាសាស្ត្រដែលកសាងគឺមានមានទៅតាមទំហំ ធំ មធ្យម និងតូច។ បើសិនជាប្រព័ន្ធធារាសាស្ត្រមានទំហំធំ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានធារាសាស្ត្ររដ្ឋ ដែលគម្រោងធំអាចផ្ទុកទឹកបានចំនួន ៦ពាន់លានម៉ែត្រគូប គម្រោងមធ្យមអាចផ្ទុកទឹកបានប្រមាណជាង ៣ពាន់លានម៉ែត្រគូប និងគម្រោងតូចអាចផ្ទុកទឹកបានប្រមាណជា ២ពាន់លានម៉ែត្រគូប។

នៅក្នុងឆ្នាំ២០១១ ផ្ទៃដីដែលគ្របដណ្តប់ដោយប្រព័ន្ធធារាសាស្ត្រ មានចំនួន ២៩,៦០៣,២៩២រ៉ៃ ដែលក្នុងនោះគម្រោងធំមានចំនួន ៩៣កន្លែង ស្រោចស្រពលើផ្ទៃដីបានប្រមាណជា ១៨,០៣៦,៩២៨រ៉ៃ ផ្ទុកទឹកបាន ៧០,០១៣,១៦០ម៉ែត្រគូប រីឯគម្រោងមធ្យមមានចំនួន ៧៥៩កន្លែង ស្រោចស្រពលើផ្ទៃដីបានចំនួន ៦,២៧១,៩៦៤រ៉ៃ ដែលអាចផ្ទុកទឹកបាន ៣,៨៥៧,៣៩៥ម៉ែត្រគូប ចំណែកឯ គម្រោងតូចវិញមានចំនួន ១៣,៣៣៩កន្លែង ដែលអាចស្រោចស្រពលើផ្ទៃដីបាន ៩៧៥,០៤៣រ៉ៃ ផ្ទុកទឹកបាន ១,៧៤៥,៩៨៣ម៉ែត្រគូប។[16] ក្រៅពីនេះ ក៏មានគម្រោងផ្សេងទៀតដូចជា គម្រោង Electronic Pumps មានចំនួន ២,៤២៧កន្លែង គ្រប់ដណ្តប់លើផ្ទៃដី ៤,២៦០,៤៥៧រ៉ៃ និងគម្រោង Temporay Reservpir ចំនួន ១៦៤កន្លែង ដែលអាចស្តុកទឹកបានចំនួន ៣៧៧,៩៥៣ម៉ែត្រគូប និងស្រោចស្រពលើផ្ទៃដីបានប្រហែលជាប្រមាណ ៥៨,៩០០រ៉ៃ។[17]

### គ. គោលនយោបាយជាតិលើវិស័យធនធានទឹក[18]

តម្រូវការទឹក គឺជាកត្តាដ៏សំខាន់នៅក្នុងការអភិវឌ្ឍជាតិ និងនៅក្នុងគ្រប់ផ្នែកទាំងអស់ដែលមិនអាចខ្វះបាន។ ដូច្នេះហើយ ទឹកត្រូវបានគេគ្រប់គ្រងយ៉ាងហ្មត់ចត់ និងសម្រេចបានតាមតម្រូវ

[16] Source of data Royal Irregation Department of Thailand

[17] www.agriinfo.doae.go.th/en/2013/agriculture/irr

[18] គោលនយោបាយជាតិលើវិស័យធនធានទឹក, អាចរកបាននៅ http://www.fao.org/docrep/005/ac623e/ac623e0m.htm

ការរបស់ប្រជាជន។ នៅក្នុងរយៈពេលប៉ុន្មានទសវត្សរកន្លងមកនេះ រាជរដ្ឋាភិបាលនៃប្រទេសថៃបានដាក់ចេញនូវគោលនយោបាយនៃការអភិវឌ្ឍធនធានទឹករបស់ខ្លួន ដោយមានបំណងឆ្លើយតបទៅនឹងតម្រូវការទឹកក្នុងសកម្មភាពសេដ្ឋកិច្ច កសិកម្ម និងសកម្មភាពផ្សេងៗទៀតដោយសង្កត់ធ្ងន់លើការគ្រប់គ្រង និងការផ្គត់ផ្គង់ទឹក។ នៅក្នុងឆ្នាំ ២០២៥ ប្រទេសថៃត្រូវបានគេព្យាករណ៍ថានឹងមានទឹកគ្រប់គ្រាន់ដែលមានគុណភាពល្អ សម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដោយសារការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រព័ន្ធច្បាប់ដែលធានាឱ្យមានសមធម៌ និងការប្រើប្រាស់ធនធានទឹករបស់ខ្លួនប្រកបដោយនិរន្តរភាព ដោយមានការពិចារណាទៅលើគុណភាពនៃជីវិត និងការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់។

ខាងក្រោមនេះ គឺជាគោលនយោបាយជាតិលើវិស័យធនធានទឹករបស់ប្រទេសថៃ៖

១. ពន្លឿនការអនុវត្តសេចក្ដីព្រាងច្បាប់ស្ដីពីទឹក ដែលជាក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងទឹកថ្នាក់ជាតិ តាមរយៈការពិនិត្យសេចក្ដីព្រាង និងអនុវត្តរាល់ជំហានចាំបាច់នានាដើម្បីធ្វើឱ្យមានប្រសិទ្ធភាពរួមទាំងការពិនិត្យឡើងវិញនូវច្បាប់ និងបទបញ្ញាទាំងឡាយដែលមានស្រាប់។

២. បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងទឹកនៅថ្នាក់ជាតិ និងការគ្រប់គ្រងអាងទឹកទន្លេដោយមានច្បាប់គាំទ្រ។ គណៈកម្មាធិការជាតិគ្រប់គ្រងទឹកទទួលខុសត្រូវ ក្នុងការបង្កើតគោលនយោបាយជាតិ ត្រួតពិនិត្យ និងសម្របសម្រួលសកម្មភាពដើម្បីបំពេញគោលនយោបាយ។ គណាកម្មាធិការជាតិអាងទឹកទន្លេ ទទួលខុសត្រូវក្នុងការរៀបចំផែនការនៃការបង់ថ្លៃទឹករបស់ប្រជាកសិករ។

៣. បញ្ជាក់ពីការបែងចែកទឹកដែលសមស្រប សម្រាប់វិស័យដែលប្រើប្រាស់ទឹកទាំងអស់ និងបំពេញនូវតម្រូវការទឹកជាមូលដ្ឋានក្នុងវិស័យកសិកម្ម និងការប្រើប្រាស់ទឹកក្នុងស្រុកដើម្បីសំរេចបានតាមរយៈការបង្កើតនូវអាទិភាពនៃការប្រើប្រាស់ទឹកទន្លេដែលមានប្រសិទ្ធភាព និងមាននិរន្តភាពនៅក្រោមលក្ខណៈវិនិច្ឆ័យការបែងចែកទឹកច្បាស់លាស់ រួមបញ្ចូលទាំងការចែករំលែកនូវតម្លៃរបស់អ្នកទទួលផលដោយផ្អែកលើ លទ្ធភាពបង់ប្រាក់ និងកម្រិតសេវាដែលបានប្រើ។

៤. បង្កើតទិសដៅច្បាស់លាស់សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការអភិវឌ្ឍដែលសមស្របទៅនឹងសក្ដានុពល និងតម្រូវការអាងស្ដុកទឹកដែលធានាគុណភាពសមស្រប ខណៈពេលដែលមានការអភិរក្សធនធានធម្មជាតិ និងការថែរក្សាបរិស្ថាន។

៥. ផ្ដល់ និងធ្វើការអភិវឌ្ឍប្រភពទឹកឆៅសម្រាប់កសិករឱ្យបានទូលំទូលាយ ប្រកបដោយសមភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកសម្រាប់កសិកម្មប្រកបដោយនិរន្តរភាព និងការប្រើ

ប្រាស់ទឹកក្នុងស្រុកដែលស្រដៀងនឹងការផ្តល់សេវាកម្មហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈជាមូលដ្ឋានដទៃទៀត។

៦. ដាក់បញ្ចូលប្រធានបទដែលទាក់ទងទៅនឹងទឹក នៅគ្រប់កម្រិតនៃកម្មវិធីសិក្សាអប់រំ ដើម្បីបង្កើតការយល់ដឹងពីតម្លៃនៃធនធានទឹកទឹក ដោយយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់ទឹកចាំបាច់ និងមានប្រសិទ្ធភាពក្នុងការថែរក្សាប្រភពទឹកធម្មជាតិ។

៧. លើកកម្ពស់ និងគាំទ្រដល់ការចូលរួម រួមទាំងការកំណត់អត្តសញ្ញាណអំពីគោលការណ៍ណែនាំច្បាស់លាស់ ស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់អង្គការសាធារណៈ ក្នុងការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងទឹករួមមានការប្រើប្រាស់ទឹក ការការពារប្រភពទឹក ការតាមដាន និងការការពារគុណភាពទឹក។

៨. ពន្លឿនការរៀបចំផែនការសម្រាប់ការការពារទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយត្រួតពិនិត្យការខូចខាត និងការស្តារឡើងវិញប្រកបដោយសមធម៌ និងសមភាពជាមួយនឹងការប្រើប្រាស់ដី និងធនធានធម្មជាតិដទៃទៀត។

៩. ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ និងមាននិរន្តភាពសម្រាប់កម្មវិធីសកម្មភាពស្របតាមគោលនយោបាយជាតិ រួមទាំងការស្រាវជ្រាវទាក់ទងនឹងទឹក ទំនាក់ទំនងសាធារណៈ ការប្រមូលព័ត៌មាន និងការផ្ទេរបច្ចេកវិទ្យាដល់សាធារណៈជន។

ក្នុងឆ្នាំ ២០០៧ ការប្រើប្រាស់ទឹកសរុបគឺប្រមាណ ៥៧.៣ គីឡូម៉ែត្រ³ ដែលក្នុងនោះ ៩០.៤ ភាគរយគឺសម្រាប់កសិកម្ម ៤.៨ ភាគរយសម្រាប់សម្រាប់ការប្រើប្រាស់ក្នុងទីក្រុង និង ៤.៨ ភាគរយសម្រាប់ឧស្សាហកម្ម ក្នុងនោះ ៨២.៩%ជាទឹកនៅលើផ្ទៃដី និង១៧.១% ជាទឹកក្រោមដី ។ នៅក្នុងឆ្នាំ ១៩៩០ ការប្រើប្រាស់ទឹកសរុបគឺប្រមាណ ៣៣.១ គីឡូម៉ែត្រ³ ដែលក្នុងនោះមាន ៩១ ភាគរយសម្រាប់វិស័យកសិកម្ម ៥ ភាគរយសម្រាប់ការប្រើប្រាស់ក្នុងក្រុង និង៤ ភាគរយសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម។[19]

### ឃ. ការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ[20]

នៅក្នុងការធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រ ប្រទេសថៃបានណែនាំនូវបច្ចេកវិទ្យាថ្មីជាមួយគម្រោងថ្មីជាច្រើនដើម្បីឱ្យសមស្របទៅនឹងបរិយាកាស ដែលធ្វើឱ្យការគ្រប់គ្រងទឹកស្រោចស្រពកាន់តែមានប្រសិទ្ធភាព ដែលគោលការណ៍នោះមានដូចជា៖

[19] ការប្រើប្រាស់ទឹកនៅប្រទេសថៃ, ២០០៧ (http://www.fao.org/nr/water/aquastat/countries_regions/THA/)

[20] http://www.fao.org/docrep/005/ac623e/ac623e0m.htm

- Overnight Storage and Distribution Systems: ជាប្រព័ន្ធគ្រប់គ្រងស្វ័យប្រវត្តិនិងការបែងចែកទឹកទៅដល់កសិដ្ឋានជាច្រើន ដែលជំនួសដោយការប្រើកម្លាំងរបស់មនុស្សក្នុងការមកប្រើប្រព័ន្ធបែងចែកទឹកឈ្មោះ NEYRTEC។
- **ប្រព័ន្ធគ្រប់គ្រងកំរិតទឹកស្វ័យប្រវត្តិ ឬរបាំងស្វ័យប្រវត្តិ** AVIO: ឧបករណ៍ម៉ាស៊ីនវាស់កម្រិតទឹក និងប្រព័ន្ធគ្រប់គ្រងដើរដោយស្វ័យប្រវត្តិមានសមត្ថភាពគ្រប់គ្រងចលនាទឹកដែលធ្វើដំណើរតាមប្រព័ន្ធស្រោចស្រពទាំងអស់ និងតាមប្រភពទឹកនានាបានគ្រប់ស្ថានភាព។

  Telemetering Systems: ជាពត៌មានបច្ចេកវិទ្យាទំនើបខ្ពស់បំផុតដោយមានការជួយឧបត្ថម្ភពីធានាគារពិភពលោក ក្រោមកិច្ចសហប្រត្តិបត្តិការជាមួយនឹងអាជ្ញាធរអគ្គិសនី ប្រទេសថៃ Telemetering ជាឧបករណ៍ជួយបង្កើតគម្រោង និងគ្រប់គ្រងប្រព័ន្ធស្រោចស្រពដែលឆ្លើយតបទៅនឹងលំហូរទឹកដែលជួយឱ្យការប្រើប្រាស់មានប្រសិទ្ធភាពលើសពីមុន ហើយវាក៏ជួយផ្តល់សញ្ញាឱ្យមានការត្រៀមទុកជាមុននៃគ្រោះទឹកជំនន់។ ប្រព័ន្ធនេះត្រូវបានដាក់សាកល្បងឱ្យប្រើប្រាស់ក្នុងទន្លេចៅប្រាយ៉ា និងអាងទឹកទន្លេផាសាក់។
- **ប្រព័ន្ធកំនត់ទីតាំងភូមិសាស្ត្រ** (GPS): ឧបករណ៍នេះត្រូវបានដាក់ឱ្យដំណើរក្នុងការត្រួតពិនិត្យទឹកនៅក្រោមទំនប់ដែលស្ថិតនៅ Lat Krathing Reservoir ក្នុងខេត្ត Chachoengsao ជាពិសេស GPS មានឧបករណ៍សំលេងសំរាប់ផ្តល់ជាសញ្ញាប្រកាសអាសន្ន ។ វាក៏ផ្តល់សញ្ញាសំគាល់នៅលើផែនទីដែលត្រូវបានបង្ហាញនៅលើប្រព័ន្ធនេះ ហើយវាមានសមត្ថភាពក្នុងការគណនាចំណុះទឹកបានម្តងទៀតផងដែរ។
- **ប្រព័ន្ធប្រលាយទឹកដែលមានរាងជាអក្សរអ៊ុយ** (Ready-made U-shaped canals): ប្រឡាយទឹកប្រភេទនេះ ត្រូវបានដាក់ណែនាំឱ្យប្រើប្រាស់ពីឆ្នាំ១៩៩៧-១៩៩៨ ស្ថិតក្នុងទំរង់ការអភិវឌ្ឍកសិដ្ឋាន។ វាបានផ្តល់នូវគុណសម្បត្តិមួយចំនួនដូចជាជួយកាត់បន្ថយការចំណាយពេលវេលាទៅការសាងសង់ និងធ្វើឱ្យមានការប្រើប្រាស់ទឹកកំរិតអប្បបរមាហើយមានប្រសិទ្ធភាពថែមទៀតផង ដែលជាកត្តាជួយជំរុញការគ្រប់គ្រងទឹកមានប្រសិទ្ធភាពផងដែរ។ គម្រោងដំបូង ត្រូវបានសាងសង់

នៅក្នុងខេត្ត Chiangmai, Ubon Ratchthani and Krabi ដែលគ្រប់ដណ្តប់លើផ្ទៃដីស្រោចស្រពសរុប ២០៨០ហិកតា។

**ខ. ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព**[21]

នៅក្នុងការគ្រប់គ្រងប្រពន្ធ័ធារាសាស្ត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យកាន់តែលឿន រដ្ឋាភិបាលបានធ្វើការកែប្រែពីការគ្រប់គ្រងដោយរដ្ឋាភិបាលទាំងស្រុងឱ្យទៅជាមានការចូលរួមពីសំណាក់ប្រជាកសិករនៅក្នុងទំនួលខុសត្រូវមួយនេះ។ ដំណើការនៃការគ្រប់គ្រងគឺប្រព្រឹត្តទៅតាមសកម្មភាពចំនួន១១ដូចខាងក្រោមៈ

១. ទំនាក់ទំនងសាធារណៈ គឺតម្រូវឱ្យអ្នកដែលពាក់ព័ន្ធទាំងអស់ក្នុងការគ្រប់គ្រង ដូចជាមន្ត្រីនាយកដ្ឋានធារាសាស្ត្រ ប្រជាកសិករ និងរដ្ឋបាលក្នុងតំបន់ ឱ្យយល់ច្បាស់ពីសកម្មភាពទាំង១១នេះ។

២. បង្កើតកិច្ចព្រមព្រៀងនៃការចូលរួម ដែលជាចំណុចចាប់ផ្តើមជាផ្លូវការសម្រាប់ការចូលរួម និងដើម្បីធ្វើឱ្យមានការយកចិត្តទុកដាក់ក្នុងការចូលរួមផងដែរ។

៣. បង្កើតក្រុមអ្នកប្រើប្រាស់ទឹក ដែលមានកសិករជាសមាជិក បន្ទាប់មកទៀត ទើបធ្វើការជ្រើសរើសប្រធាន អនុប្រធាន និងគណៈកម្មការដើម្បីបង្កើតលក្ខ័ណ្ឌវិន័យផ្សេងៗ។

៤. ពង្រឹងអង្គភាពអ្នកប្រើប្រាស់ទឹក ផ្តល់ការអប់រំ ដោយធ្វើការបណ្តុះបណ្តាលឱ្យប្រជាកសិករយល់ដឹងអំពីសារៈសំខាន់នៃធនធានទឹក។

៥. បង្កើនប្រសិទ្ធភាពអង្គភាពអ្នកប្រើប្រាស់ទឹក

៦. បង្កើតគណៈកម្មការសម្រាប់ការគ្រប់គ្រងទឹករួម

៧. បង្កើតមូលនិធិសម្រាប់ជួសជុស និងបង្កើនសមត្ថភាពប្រពន្ធ័ធារាសាស្ត្រ ដោយធ្វើការប្រមូល ប្រាក់ពីប្រជាកសិករដែលប្រើប្រាស់ទឹកនោះ និងអ្នកដទៃទៀតដែលមិនមែនជាប្រជាកសិករ តែក៏អាចចូលរួមក្នុងការប្រើប្រាស់ទឹកនោះបានផងដែរ។

៨. ចាត់ចែងភារកិច្ចទៅឱ្យក្រុមអ្នកប្រើប្រាស់ទឹកក្នុងការថែទាំ ឬអង្គភាពរដ្ឋបាលក្នុងតំបន់

៩. ធ្វើឱ្យក្រុមកសិករប្រើប្រាស់ទឹក និងអង្គភាពរដ្ឋបាលក្នុងតំបន់ យល់ឱ្យច្បាស់ពីដំណើរការនៃការចែកចាយទឹក។

---

[21] លោក Urit Rattanatangtrakul ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម, ទំព័រ២-៤ អាចរកបាននៅ http://www.rid.go.th/thaicid/_5_article/2549/07PIM.pdf

១០. វាយតម្លៃទៅលើចំណុចខ្លាំងរបស់ក្រុមកសិករប្រើប្រាស់ទឹក ដែលធ្វើឡើងរៀងរាល់ខែកញ្ញាជារៀងរាល់ឆ្នាំ។

១១. ប្រមូលទិន្នន័យសំខាន់ៗដើម្បីឱ្យដឹងពីសមិទ្ធិផលដែលទទួលបាន។

### ១.៣.២.២ បទពិសោធន៍ប្រទេសវៀតណាម

វៀតណាម គឺជាប្រទេសមួយស្ថិតនៅក្នុងទ្វីបអាស៊ីអាគ្នេយ៍ ដែលមានផ្ទៃដីប្រមាណជា ៣៣១,៦៩០គីឡូម៉ែត្រការេ និងប្រជាជនប្រមាណជា ៨៩លាននាក់។[22] វៀតណាមក៏ជាប្រទេសមួយដែលផលិត និងនាំចេញស្រូវអង្ករទៅកាន់ទីផ្សារពិភពលោកចំណាត់ថ្នាក់លេខពីរ បន្ទាប់ពីប្រទេសថៃផងដែរ។ ដំណាំស្រូវភាគច្រើនត្រូវគេដាំនៅតំបន់ដីសណ្ដរទន្លេមេគង្គ និងនៅតាមដីសណ្ដរទន្លេក្រហម ព្រោះថានៅតំបន់ទាំងពីរនេះមានទឹកគ្រប់គ្រាន់សម្រាប់ដាំដំណាំស្រូវ ហើយតំបន់នេះក៏ជាតំបន់ប្រជុំទីផ្សារតាមផ្លូវទឹកផងដែរ។ នៅជុំវិញ តំបន់ដីសណ្ដរទន្លេមេគង្គ និងតំបន់ដីសណ្ដរទន្លេក្រហម ត្រូវបានគេទទួលស្គាល់ថាជា ចានបាយ របស់ជនជាតិវៀតណាម ព្រោះប្រជាជនប្រមាណជា ៨០% នៃតំបន់នេះបានផ្សារភ្ជាប់ទៅនឹងការដាំដំណាំស្រូវ ដែលជាអាហារចាំបាច់សម្រាប់ប្រជាជនវៀតណាមទូទាំងប្រទេស។ កត្តាសំខាន់ ដែលធ្វើឲ្យប្រទេសវៀតណាមមានអំណោយផលផ្នែកដាំដុះដំណាំស្រូវ គឺដោយសារវៀតណាមបានយកចិត្តទុកដាក់នៅក្នុងការពង្រីកប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងធនធានទឹកបានល្អ។

#### ក ស្ថានភាពប្រព័ន្ធធារាសាស្ត្រ[23]

សព្វថ្ងៃនេះ ប្រមាណជា ៨២%នៃការប្រើប្រាស់ទឹកសរុប គឺបានបម្រើឱ្យការងារស្រោចស្រព។ ប្រទេសវៀតណាមមានប្រព័ន្ធធារាសាស្ត្រខ្នាតធំ ៧៥ និងខ្នាតមធ្យមចំនួន៨០០ ហើយអាងទឹកច្រើនជាង ៣៥០០ ដែលមានសមត្ថភាពផ្ទុកទឹកលើសពី ១លានម៉ែត្រគូប ទ្វារទឹកខ្នាតធំចំនួន ៥០០០ ស្ថានីយ៍បូមទឹកប្រមាណជាង ២០០០ និងប្រព័ន្ធខ្នាតតូចជាច្រើនពាន់កន្លែងទៀត។ ផ្ទៃដីទំហំប្រមាណជា ៣.៣លានហិកតា ស្ថិតនៅក្រោមការស្រោចស្រពទាំងស្រុង និងប្រមាណជា ១លានហិកតាទៀតស្ថិតក្រោមការស្រោចស្រពខ្លះៗ។ ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពយ៉ាងខ្លាំងក្លា ក្នុងរយៈប៉ុន្មានឆ្នាំមកនេះបានធ្វើឱ្យវៀតណាមជួយធានាសន្តិសុខស្បៀង និងក្លាយជាប្រទេសនាំមុខលើការនាំចេញស្រូវអង្ករនៅលើពិភពលោកផងដែរ។

[22] អភិបាលកិច្ចទឹក , ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ, ទំព័រ៣៥
[23] អភិបាលកិច្ចទឹក , ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ, ទំព័រ៣៩

**ខ បញ្ហាប្រឈមលើប្រព័ន្ធធារាសាស្ត្រ**[24]

- ក្របខ័ណ្ឌស្ថាប័ន ច្បាប់ និងគោលនយោបាយ ដែលអនុវត្ត មិនបានបែងចែកច្បាស់លាស់អំពីតួនាទី ដែលជាហេតុធ្វើឱ្យមានបញ្ហាលើការគ្រប់គ្រងធនធានទឹក ការស្រោចស្រព ការដោះទឹក ជម្រុញឱ្យមានភាពអសកម្ម និងទំនាស់អំពីតំបន់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ស្ថាប័ននានា។
- ការអនុវត្តការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួមពីកសិករ ត្រូវបានរាំងស្ទះដោយសារភាពយឺតយ៉ាវនៃការអនុវត្ត និងការលើកទឹកចិត្តដល់កសិករ មានតិចតួចដោយសារតែការចូលរួមរបស់កសិករក្នុងការប្រើប្រាស់ទឹកមិនត្រូវបានគិតថ្លៃ។
- កសិករមានសិទ្ធតិចតួចក្នុងការបញ្ចេញយោបល់លើការគ្រប់គ្រងប្រព័ន្ធធារាសស្ត្រ

**គ គោលនយោបាយលើការគ្រប់គ្រងធនធានទឹក**[25]

ការគ្រប់គ្រងធនធានទឹកដោយគ្មានប្រសិទ្ធភាព អាចបណ្តាលឱ្យបណ្តាលឱ្យការប្រើប្រាស់ទឹកមិនមានសភាពត្រឹមត្រូវទៅតាមស្តង់ដាបច្ចេកទេស ហើយអាចប៉ះពាល់ដល់ទិន្នផលដំណាំរបស់ប្រជាកសិករថែមទៀត។ ដោយយល់ឃើញពីសារៈសំខាន់របស់ទឹក រដ្ឋាភិបាលវៀតណាមបានដាក់ចេញនូវច្បាប់ គោលនយោបាយជាច្រើនដូចជា៖

- ច្បាប់ស្តីពី ការការពារបរិស្ថានឆ្នាំ១៩៩៣ ដែលធ្វើការបកស្រាយពីសិទ្ធិលើការគ្រប់គ្រងនិងការទទួលខុសត្រូវ ដែលទាក់ទងនឹងការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិដែលទាក់ទងនិងតំបន់ដីសើម។
- ច្បាប់ស្តីពី ធនធានទឹកឆ្នាំ១៩៩៨ បានផ្តល់ជាមូលដ្ឋានសម្រាប់
  - ✓ ការបង្កើតគោលនយោបាយ គោលការណ៍ និងក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់ការកសាងផែនកា ការធ្វើអាជីវកម្ម ការប្រើប្រាស់ ការអភិរក្ស កិច្ចការពារ និយ័តកម្ម និងការគ្រប់គ្រងធនធានទឹកទាំងអស់សម្រាប់ការអភិវឌ្ឍទូលាយ តាមបែបសមាហរណកម្ម និងប្រកបដោយនិរន្តរភាព។
  - ✓ កំណាត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋាភិបាល អ្នកប្រើប្រាស់ទឹក និងសាធារណៈជន នៅក្នុងការប្រើប្រាស់ និងការការពារធនធានទឹក។
  - ✓ ចែងអំពីសមត្ថកិច្ច និងការទទួលខុសត្រូវខាងរដ្ឋបាល ដើម្បីអនុវត្តច្បាប់នេះ ដែលរួមទាំងកិច្ចសហប្រតិបត្តិការ ការប្រាស្រ័យឆ្លើយឆ្លង និងការ

[24] អភិបាលកិច្ចទឹក , ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ, ទំព័រ៣៩

[25] អភិបាលកិច្ចទឹក , ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ, ទំព័រ៣៥-៣៧

សម្របសម្រួលរវាងក្រសួង និងទីភ្នាក់ងារនានានៃរដ្ឋាភិបាល ថ្នាក់ខេត្ត អ្នកប្រើប្រាស់ទឹក និងសាធារណៈជន។

ច្បាប់នេះ បានចែងអំពីការបង្កើតក្រុមប្រឹក្សាធនធានទឹក និងគណៈកម្មាធិការអាងទន្លេតាមអាងទន្លេសំខាន់ៗ។ ច្បាប់នេះមានគោលបំណង បង្កើតភាពចុះសម្រុងនៃការគ្រប់គ្រងទឹក ដែលផ្តល់នូវយន្តការមួយសម្រាប់ការកសាងផែនការ ការប្រើប្រាស់ និងកិច្ចការពារធនធានទឹកតាមរយៈការ ផ្តល់អាជ្ញាប័ណ្ណដល់អ្នកប្រើប្រាស់ទឹក និងការចេញលិខិតអនុញ្ញាត សម្រាប់ការបញ្ចេញកាកសំណល់រាវ។ ច្បាប់នេះក៏បានផ្តល់ជាមធ្យោបាយសម្រាប់តាមដាន វាយតម្លៃ និងពង្រឹងការអនុវត្តច្បាប់ផងដែរ។

- យុទ្ធសាស្ត្រជាតិផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទឆ្នាំ២០០០-២០២០ ដែលយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំដោយក្រសួងសំណង់ ក្រោមកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធនានា ដោយមានការគាំទ្រពីជំនួយអភិវឌ្ឍន៍អន្តរជាតិប្រទេសដាណឺម៉ាក និងមានអនុម័តនៅឆ្នាំ២០០០ ដែលយុទ្ធសាស្ត្រនេះមានគោលបំណងសម្រេចឱ្យបាននូវៈ
    - ✓ ការកែលម្អសុខភាពរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ
    - ✓ កែលម្អលក្ខណ្ឌនៃការរស់នៅ
    - ✓ កាត់បន្ថយការបំពុលបរិស្ថានពីលាមកមនុស្ស និងសត្វ
- យុទ្ធសាស្ត្រជាតិលើវិស័យធនធានទឹកឆ្ពោះទៅកាន់ឆ្នាំ ២០២០ ដែលយុទ្ធសាស្ត្រនេះមានគោលបំណង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើការគ្រប់គ្រងធនធានទឹកតាមរយៈកម្មវិធី ពហុភាគី ទ្វេភាគី និងពង្រឹងភាពជាដៃគូជាមួយភ្នាក់ងារផ្តល់ជំនួយ និងអង្គការអន្តរជាតិនានា ក៏ដូចជាការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសសមាជិកនៃគណៈកម្មាធិការទន្លេមេគង្គ និងអាងទន្លេដទៃទៀត។

**ឃ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព**

ដោយយល់ឃើញពីសារៈសំខាន់របស់ប្រព័ន្ធធារាសាស្ត្រ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ រដ្ឋាភិបាលប្រទេសវៀតណាមបានអនុម័តសេចក្តីសម្រេចមួយស្តីពី "ការបង្កើតមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម" ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិទ្យាស្ថានស្រាវជ្រាវធនធានទឹកប្រទេសវៀតណាម។ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការ

ចូលរួម គឺជាកត្តាដ៏សំខាន់ក្នុងការកែលម្អរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយប្រជាកសិករត្រូវចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ។[26]

មជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម គឺជាស្ថាប័នមួយដែលមានសិទ្ធិពេញលេញក្នុងការ បង្កើតគោលនយោបាយ និងការឃ្លាំមើលការអនុវត្តគោលនយោបាយរបស់ប្រជាកសិករក្នុងដំណើរការគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រ។ ខាងក្រោមនេះ គឺជាតួនាទីរបស់មជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម[27]៖

- ធ្វើការស្រាវជ្រាវ និងបង្កើតគោលនយោបាយលើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។
- ផ្តល់ការណែនាំ និងណែនាំអំពីការបង្កើត និងអនុវត្តការទទួលខុសត្រូវការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីកសិករ។
- ធ្វើការផ្តល់យោបល់ និងចូលរួមក្នុងការអនុវត្តគម្រោង ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម។
- រៀបចំវគ្គបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការយល់ដឹងពីគោលនយោបាយ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមដល់ប្រជាកសិករ។ ណែនាំ និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនៅក្នុងប្រទេស និងក្រៅប្រទេសក្នុងគោលបំណងជួយដល់អាជ្ញាធរមូលដ្ឋាន និងកសិករដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ១.៤ ប្រវត្តិប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា

ចំពោះប្រទេសកម្ពុជាវិញ ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រក្នុងវិស័យកសិកម្មក៏មានតាំងពីយូយារណាស់មកហើយដែរ ពោលគឺប្រហែលជា ១០០០ឆ្នាំមុន គ.សមកម្ល៉េះ ដែលអាចសន្និដ្ឋានបានថានៅក្នុងកំឡុងសម័យអង្គរដ៏រុងរឿងរបស់កម្ពុជា។ បន្ទាប់ពីការរុករកឃើញប្រាសាទអង្គរដែលបន្សល់ទុកក្នុងព្រៃអស់រយៈពេលរាប់រយឆ្នាំ គេក៏បានបន្តការសិក្សាទៅលើតំបន់នានា ជុំវិញប្រាសាទជាច្រើនទៀត ហើយគេក៏បានរកឃើញនូវប្រព័ន្ធទឹកនាសម័យអង្គរបុរាណ ដែលក្នុងប្រព័ន្ធនោះមានដូចជា បារាយណ៍ទឹក ស្រះទឹក និងប្រឡាយទឹកជាដើម ដែលប្រព័ន្ធទឹកទាំងនោះ

[26] http://www.pim.vn/En/Web/Content.aspx?distid=505

[27] http://www.pim.vn/En/Web/Content.aspx?distid=501

រួមបញ្ចូលគ្នាបង្កើតបានជាប្រព័ន្ធធារាសាស្ត្រមួយដ៏អស្ចារ្យសម្រាប់ការដាំដុះដំណាំស្រូវ។[28]

### ១.៤.១ ប្រព័ន្ធធារាសាស្ត្រសម័យអង្គរ[29]

ក្រោយការរំដោះរួចផុតពីការត្រួតត្រារបស់ជ្វានិងការប្រកាសខ្លួនជាទេវរាជាដោយព្រះបាទជ័យវរ្ម័នទី២ នាឆ្នាំ៨០២ លើកំពូលភ្នំគូលែន គឺជាការចាប់ផ្តើមនៃសម័យអង្គរដ៏រុងរឿងបំផុតក្នុងប្រវត្តិសាស្ត្រនៃកម្ពុជា។ សម័យអង្គរគឺជាយុគមាសនៅក្នុងប្រវត្តិសាស្ត្រខ្មែរ ដោយសម័យនេះបាននាំមកនូវកិត្តិយស ការបង្រួបបង្រួមប្រទេសជាតិ និងវឌ្ឍនភាពចម្រុងចម្រើន។ នាសម័យនោះសំណង់ធារាសាស្ត្រធំៗជាច្រើន បានត្រូវកសាងសម្រាប់ជាការ គោរពដល់សាសនា ប៉ុន្តែទន្ទឹមគ្នានោះក៏បានបម្រើផងដែរដល់កិច្ចអភិវឌ្ឍន៍សង្គមពិសេសក្នុងផលិតកម្មដំណាំស្រូវ។ សំណង់បារាយណ៍ ឥន្ទ្រតាដាក (នៅជុំវិញប្រាសាទលលៃ) បារាយណ៍ទឹកថ្លាខាងលិច និងខាងកើត (នៅក្នុងបរិវេណទីក្រុងអង្គរ) សុទ្ធតែបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនៅក្នុងកិច្ចការសាសនា ក៏ដូចជាក្នុងកិច្ចការសង្គម។

ព្រះរាជាឥន្ទ្រវរ្ម័នទី១ ក្រោយពីបានឡើងសោយរាជសម្បត្តិនាឆ្នាំ៨៧៧-៨៨៩ ព្រះអង្គបានរៀបចំកសាងប្រព័ន្ធស្រោចស្រពជាច្រើន ដើម្បីជាការឧទ្ទិសដល់អទិទេពទឹកដី ដែលក្នុងនេះមានការកសាងបារាយណ៍ដ៏ធំមួយដែលគេ ស្គាល់ថាជាបារាយណ៍ ឥន្ទ្រតាដាក។ បារាយណ៍នេះបានកសាងនៅលើផ្ទៃដីប្រមាណ៣០០ហិកតា ទុកសម្រាប់ជាអាងស្តុកទឹកដែលបានមកពីការប្រមូលទឹកភ្លៀង។ ជាបន្តក្រោយពីបានសោយរាជសម្បត្តិភ្លាម ព្រះបាទយសោធវរ្ម័នទី១ ដែលត្រូវជាព្រះរាជបុត្រព្រះបាទ ឥន្ទ្រវរ្ម័នទី១ ព្រះអង្គក៏បានបន្តការកសាងប្រព័ន្ធស្រោចស្រព តាមលំនាំដែលព្រះបិតា របស់ព្រះអង្គបានបន្សល់ទុក លើការដោះស្រាយបញ្ហាទឹក ដោយព្រះអង្គបានកសាងបារាយណ៍សោធរតាដាក នៃទីក្រុងអង្គរដែលបច្ចុប្បន្នត្រូវគេស្គាល់ថា ជាបារាយណ៍ខាងកើតស្ថិតនៅក្នុងខេត្តសៀមរាប។

ដូចនេះតាមរយៈការយកសាសនាមកបម្រើសង្គមដោយព្រះមហាក្សត្រខ្មែរ នៅក្នុងសម័យអង្គរបានជំរុញដល់ ការអភិវឌ្ឍយ៉ាងខ្លាំងក្លា នៅក្នុងវិស័យប្រព័ន្ធធារាសាស្ត្រសម្រាប់វប្បកម្មដំណាំស្រូវនៅក្នុងប្រទេសកម្ពុជានាសម័យនោះ។ ជាលទ្ធផលការរីកចម្រើននៃប្រព័ន្ធធារាសាស្ត្រនេះបានក្លាយទៅជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការកសាងប្រព័ន្ធផលិតកម្មដំណាំស្រូវ ដ៏មានសក្តានុ

---

[28] ចាន់ ស៊ីណាត ការវិនិយោគទៅលើដី និងទឹកក្នុងប្រទេសកម្ពុជា, អាចរកបាននៅ(http://www,fao.org/docrep/005/ac623e/ac623e0c.htm)

[29] វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា.ដំណាំស្រូវនៅកម្ពុជា . (ភ្នំពេញៈវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា,២០០៧), ទំព័រ៥-៨

ពលដែលជាការពិតនេះគឺជាកត្តាដ៏សំខាន់មួយដែលបាននាំប្រទេសឱ្យឈានទៅជា មហាប្រទេសនៅក្នុងតំបន់។

ក្រៅពីការអនុវត្តវប្បកម្មដំណាំស្រូវដោយមានប្រព័ន្ធស្រោចស្រពជាមូលដ្ឋាន ជាក់ស្តែងនៅក្នុងសម័យអង្គរ អាស្រ័យដោយមានប្រព័ន្ធស្រោចស្រពយ៉ាងល្អដូចនេះហើយ ទើបវប្បកម្មដំណាំស្រូវត្រូវបានអនុវត្តពី៣ទៅ៤ដងក្នុងមួយឆ្នាំៗ។ ប្រជាកសិករខ្មែរនាសម័យនោះ ក៏បានដាំដុះផងដែរនូវស្រូវប្រដេញទឹកដែលភាគច្រើន គេតែងតែធ្វើនៅតាមបឹងទន្លេសាបនាពេលដែលទឹកចាប់ផ្តើម ស្រកចុះ។ ដូចនេះយើងឃើញថាការដាំដុះស្រូវប្រដេញទឹក បានត្រូវអនុវត្តពីយូរលង់មកហើយ ហើយកំពុងតែប្រើប្រាស់ យ៉ាងពេញនិយមនៅក្នុងប្រទេសនាពេលបច្ចុប្បន្ន ពិសេសនៅតាមតំបន់ប្រពៃណីរបស់ខ្លួនគឺនៅតាមបឹងទន្លេសាប នៃខេត្តសៀមរាប និងនៅតាមមាត់បឹងធំៗទាំងឡាយនៅក្នុងប្រទេស។

នាសម័យអង្គរ ផលិតកម្មស្រូវកើនឡើងខ្លាំងដែលនេះគឺជាកត្តាយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ ផលិតផលស្រូវដែលទទួលបានត្រូវយកទៅប្រើប្រាស់ទាំងនៅក្នុងការការពារប្រទេស "ធ្វើស្រែនិងទឹក ធ្វើសឹកនឹងបាយ" ក៏ដូចជាសម្រាប់ជាទុកក្នុងការការពារសុខមាលភាពរបស់ប្រជាពលរដ្ឋផងដែរ។ នៅក្នុងរជ្ជកាលនៃព្រះបាទជ័យវរ្ម័នទី៧ អតិរេកនៃដំណាំស្រូវត្រូវបានពិព័ណនា ហើយអាស្រ័យដោយការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះភាពជាសុខទុក្ខរបស់ប្រជារាស្ត្រ ព្រះបាទជ័យវរ្ម័នទី៧ បានរៀបចំអោយមានមន្ទីរព្យាបាលរោគចំនួន១០២ នៅទូទាំងប្រទេស និងបានបរិច្ចាគ ព្រះរាជទ្រព្យព្រះអង្គយ៉ាងក្រាស់ក្រែល ក្នុងការចំណាយប្រចាំថ្ងៃនៅក្នុងមន្ទីរព្យាបាលរោគទាំងនោះ។ នៅក្នុងនេះគេបានដឹងថាក្នុងមួយឆ្នាំៗ ក្រសួងរោគាភិបាលរបស់ព្រះអង្គ បានចំណាយរហូតដល់៤.៥៥៣.៦០០ គីឡូក្រាមស្រូវ សម្រាប់ការព្យាបាលនៅមន្ទីរទាំង១០២ (Hill,1977)។

### ១.៤.២ ប្រព័ន្ធធារាសាស្ត្រសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣)

បន្ទាប់ពីកម្ពុជាបានស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង រយៈពេលយូរយារូចមកហើយ ដែលគេហាក់ដូចជាពុំទាន់ឃើញមានឥទ្ធិពលអ្វីខ្លាំងក្លា ដែលធ្វើឱ្យមានការប៉ះពាល់ប្រពៃណីទំនៀមទំលាប់ នៃនយោបាយទំនាក់ទំនងសេដ្ឋកិច្ចសង្គម នៅក្នុងប្រទេសឡើយ។ ដោយសារតែដំបូងបារាំងគិតថា ការចូលមកកាន់កាប់ប្រទេសកម្ពុជា មិនមែនជាប្រភពសេដ្ឋកិច្ចនោះឡើយ គឺគ្រាន់តែជាទីតាំងយុទ្ធសាស្ត្រក្នុងការប្រកួតប្រជែងនៅលើពិភពលោកជាមួយនិងអង់គ្លេស ដើម្បីគ្រប់គ្រងក្នុងតំបន់អាស៊ីអាគ្នេយ៍តែប៉ុណ្ណោះ។

ដូចយើងបានដឹងហើយថា ការបង្កើតនូវការគ្រប់គ្រងពីសំណាក់អាណានិគមនិយមបារាំង នៅក្នុងប្រទេសកម្ពុជា នៅគ្រប់នៃដំណើរវិវត្តទាំងអស់ គឺបានមកពីការធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅ និងដំណើរអភិវឌ្ឍន៍នៃសង្គមខ្មែរ។ បន្ទាប់ពីធ្វើកំណែទម្រង់រួចមក ផលិតកម្មស្រូវមានការប្រែប្រួលយ៉ាងខ្លាំងណាស់ដែរ។ នៅឆ្នាំ១៩២៧ ទំហំដីសំរាប់ដំណាំស្រូវនៅកម្ពុជាមានដល់៩០០ពាន់ហិចតា មានន័យថា គេបានបង្កើនទំហំដីបើគេប្រៀបធៀបឆ្នាំ១៩០៤ មានផ្ទៃដីដាំស្រូវត្រឹមតែ៣០០ពាន់ហិកតា។[30] ដីដាំដំណាំស្រូវច្រើនមាននៅខេត្តបាត់ដំបង ស្វាយរៀង និងព្រៃវែង។ ផលិតផលស្រូវបានមកពីការដាំដំណាំស្រូវនៅកសិដ្ឋានធំៗពីការធ្វើស្រែដោយការប្រវាស់។ នេះសរបញ្ជាក់ថា ប្រជាពលរដ្ឋនាំគ្នាធ្វើស្រែច្រើនដងដោយសារតែនៅតំបន់ទាំងនេះ ដោយសារតែប្រព័ន្ធប្រលាយទឹក ឬប្រភពទឹកជាព្រែកដែលធ្វើឱ្យដំណាំស្រូវមានការកើនឡើងដែលឈានដល់ការពង្រីកផ្ទៃដីដាំដុះថែមទៀត។ ហើយឯកសារនេះបានបង្ហាញទៀតថា ជារៀងរាល់ឆ្នាំប្រទេសកម្ពុជាជាមធ្យមមានការនាំ ចេញស្រូវទៅប្រទេសក្រៅពី១៥០ដល់២៥០ពាន់តោន។ នៅឆ្នាំ១៩៣៧ មានការនាំចេញទៅក្រៅនូវផលដំណាំដូចជាស្រូវ៥០០ពាន់តោន។[31] ការកើនឡើងនេះ គឺដោយសារ ការធ្វើកំណែទម្រង់លើដីធ្លី និងការពង្រីកប្រព័ន្ធធារាសាស្ត្រដើម្បីលើកស្ទួយវិស័យកសិកម្ម ដោយសារតែ បារាំងបានជ្រើសរើសយកស្រូវអង្ករគឺជាស្នូលនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

តាមរយៈភស្តុតាងខាងលើនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា បទពិសោធន៍នៃការកសាងប្រព័ន្ធទំនប់ទឹក ឬប្រព័ន្ធធារាសាស្ត្រពិតជាបានធ្វើឱ្យមានការកើនឡើងនូវ ភោគផលដំណាំកសិកម្ម ជាពិសេសដំណាំស្រូវដែលជួយទ្រទ្រង់សេដ្ឋកិច្ចជាតិនិងផ្តល់នូវស្បៀងអាហារដែលមានសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋខ្មែរនាសម័យអានិគមបារាំង។

### ១.៤.៣ ប្រព័ន្ធធារាសាស្ត្រសម័យសង្គមរាស្ត្រនិយម[32] (១៩៥៣-១៩៧០)

រដ្ឋាភិបាលឯករាជ្យកម្ពុជា បានចាប់ផ្តើមកាន់អំណាចនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៣ នៅក្នុងខណៈដែលប្រព័ន្ធផលិតកម្មទីផ្សារបែបសេរី ប្រពៃណីទំនៀមទំលាប់ កំពុងតែជួបប្រទះនឹងភាពរង្គោះរង្គើយ៉ាងខ្លាំង។ វិបត្តិនយោបាយដែលទទួលឥទ្ធិពលពីសង្គ្រាមលោកលើកទី២ និងការបាត់បង់ប្រភពទីផ្សារសម្រាប់កសិផលប្រជាកសិករកម្ពុជា បានធ្វើឱ្យសេដ្ឋកិច្ចមានការធ្លាក់ចុះយ៉ាងខ្លាំង ជាពិសេសលើវិស័យដែលនាំមកនូវផលចំណេញច្រើន។

[30] ពៅ សារឿន, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ២០១១

[31] ដៀប សុផល,កម្ពុជា នយោបាយ សេដ្ឋកិច្ច សង្គម (១៨៦៣-១៩៧៩), ទំព័រ ៦២

[32] ដៀប សុផល,កម្ពុជា នយោបាយ សេដ្ឋកិច្ច សង្គម (១៨៦៣-១៩៧៩), ទំព័រ ៧១-៨៦

ចាប់តាំងពីឆ្នាំ១៩៤៦ នៅក្នុងប្រទេសកម្ពុជាបានលេចឡើងនូវការតស៊ូដោយអាវុធប្រឆាំងនឹងបារាំង។ សកម្មភាពប្រយុទ្ធប្រឆាំងតទល់នឹងកងទ័ពបារាំង និងកងទ័ពរដ្ឋាភិបាលបានប្រព្រឹត្តឡើង ភាគច្រើននៅតាមស្រុកស្រែចម្ការ ដែលនាំមកនូវការខូចខាតយ៉ាងខ្លាំង។ ចំពោះហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ក៏ត្រូវជួបប្រទះនឹងការខូចខាតយ៉ាងខ្លាំងណាស់ដែរ ក្នុងការប៉ះទង្គិចដោយអាវុធ នាំឱ្យមានការខូចខាតភូមិកររបស់អ្នកស្រុកអស់រាប់ពាន់កន្លែង ប្រព័ន្ធស្រោចស្រពត្រូវខូចខាតអស់ជាច្រើន ដីស្រែរាប់ពាន់ហិកតាត្រូវបោះបង់ចោល ស្ពានជាច្រើនត្រូវបានកាត់ផ្តាច់ការដឹកជញ្ជូនត្រូវតភ្ជាប់ដោយកាណូត។

ក្រោយពីទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មកប្រទេសកម្ពុជានៅក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់ នរោត្តម សីហនុ ទ្រង់បានលើកកម្ពស់កម្មវិធីរៀបចំផ្ទះសម្បែងប្រជាជននៅតាមទីជនបទ ដោយក្នុងនោះរដ្ឋាភិបាលមានទិសដៅជួយដល់ឃុំស្រុកដោយលើកកម្ពស់បច្ចេកទេសកសិកម្ម ក្នុងលក្ខណៈជាប្រពៃណីទំនៀមទំលាប់ជួយគ្នាទៅវិញទៅមក ដែលមានតាំងពីយូរយារណាស់មកហើយនៅក្នុងសង្គមខ្មែរ។ ព្រះបាទ នរោត្តម សីហនុ ក៏បានធ្វើការដោះស្រាយបញ្ហាលើប្រព័ន្ធស្រោចស្រព និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីជនបទ ដោយទ្រង់បានឈរលើមាគ៌ានាសម័យអង្គរ ព្រះអង្គបានអនុវត្តនូវគោលនយោបាយទឹកតាមរយៈការប្រមូលប្រជាពលរដ្ឋនៅតាមតំបន់ជនបទឱ្យនាំគ្នាជីកប្រឡាយទឹក ដើម្បីប្រើប្រាស់ និងទប់ទឹកសំរាប់ការធ្វើស្រែចំការ។ ព្រះអង្គបានប្រើមធ្យោបាយ "ចលនាហត្ថកម្ម" ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តធ្វើការងារដោយមិនយកកម្រៃរបស់ប្រជាជនកម្ពុជា ដើម្បីអភិវឌ្ឍន៍មាតុភូមិ។ ប្រជាជនកម្ពុជាទាំងអស់ដោយមិនគិតពីបុណ្យសក្តិ មាន ឬក្រ ត្រូវចូលរួមក្នុង ចលនាហត្ថកម្ម ទៅតាមកាលកំណត់ជាក់លាក់មួយ ជាការងារជាប្រចាំ។ នៅក្នុងការងារទាំងនោះមានដូចជា ដកស្ទូង ប្រមូលផល សំណង់ប្រព័ន្ធធារាសាស្ត្រ។ល។ ក្នុងស្ថានភាពបែបនេះ ចលនាហត្ថកម្ម មានលក្ខណៈដែលពីមុនមកហៅថា "ពលកម្មដើម្បីព្រះមហាក្សត្រ"។ ការធ្វើហត្ថកម្ម មេដឹកនាំបានគិតថាជាការងារដោយមិនចាំបាច់ចំណាយទុនធ្វើឡើយ ហើយគេអាចទទួលបានជាលទ្ធផលនូវប្រព័ន្ធស្រោចស្រព ផ្លូវដែលជាបញ្ហាមួយបន្សល់ទុកក្នុងទីជនបទតាំងពីយូរណាស់មកហើយ។

ក្រោយបានចាប់ផ្តើមលើកគម្រោងធារាសាស្ត្រដ៏ទូលំទូលាយនៅខេត្តមួយចំនួននៃបណ្តាខេត្តដែលមានប្រជាជនច្រើនបំផុតដូចជា ខេត្តកំពង់ចាម និងខេត្តកណ្តាល ដើម្បីជំរុញ និងបង្កើនទិន្នផលស្រូវនៅក្នុងប្រទេសដែលធ្លាប់តែពឹងផ្អែករបបទឹកភ្លៀងដ៏លំបាក។ ពេលនោះកសិកម្មរបស់ប្រទេសកម្ពុជាបានងើបឡើងជាថ្មី រហូតធ្វើឲ្យប្រទេសជាតិយើងមានសេដ្ឋកិច្ចល្អប្រសើរ

ឡើងវិញ។ ដែលជាលទ្ធផល កម្ពុជាអាចផលិតស្រូវបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញ។ នៅក្នុងឆ្នាំ១៩៦៧ ទិន្នផលស្រូវជាមធ្យមទទួលបាន ៣.២តោនក្នុងមួយហិកតា ចំណែកឯឆ្នាំ១៩៧០ ទិន្នផលស្រូវមានការកើនឡើងដល់ទៅ ៣.៨តោនក្នុងមួយហិកតាងណោះ។

### ១.៤.៤ ប្រព័ន្ធធារាសាស្ត្រសម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

នៅក្នុងលក្ខន្តិកនៃការលេចឡើងនូវអស្ថេរភាព និងស្ថានភាពកាន់តែលង់ជ្រៅទៅៗនៃសង្គ្រាមស៊ីវិល នៅក្នុងប្រទេសកម្ពុជាបានផ្ទុះឡើងនូវការធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តមសីហនុ នាថ្ងៃទី១៨ខែមីនាឆ្នាំ១៩៧០ ដោយឧត្តមសេនីយ លន់ ណុល និងឧត្តមសេនីយ សិរិមតៈ ឡើងកាន់អំណាចជំនួសវិញ។[33] នៅក្នុងឱកាសរដ្ឋប្រហារនេះ កងទ័ពជាតិមិនត្រឹមតែជាឧបករណ៍សម្រាប់ដណ្តើមអំណាចប៉ុណ្ណោះទេ ហើយក៏មានតួនាទីគ្រប់គ្រងអំណាចនយោបាយថែមទៀត។

នៅក្នុងវិស័យកសិកម្មរដ្ឋាភិបាល លន់ ណល់ បានធ្វើសេចក្តីប្រកាសអំពីកម្មវិធីនយោបាយរបស់ខ្លួន ដែលមានលក្ខណៈថែរក្សាគំរូចាស់ ជាប្រពៃណីទំនៀមទំលាប់ ដូចកាលពីសម័យសង្គមរាស្ត្រនិយមដែរ។ ឧទាហរណ៍ ការស្រោចស្រព ត្រូវតែអាស្រ័យទៅលើមធ្យោបាយរបស់កសិករដោយផ្ទាល់នៅលើប្រព័ន្ធស្រោចស្រពតូចៗ ហើយក៏មានការចូលរួមពីសំណាក់រដ្ឋាភិបាល និងជំនួយពីខាងក្រៅលើប្រព័ន្ធធំៗក្នុងការលើកកម្ពស់បរិមាណផលិតកម្មកសិកម្ម។[34]

អាស្រ័យដោយសង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំ បានធ្វើឱ្យមធ្យាបាយផលិតកម្មកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសាធារណនិងជនបទ ទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរនិងស្របពេលដែលប្រជាកសិករនាពេលនោះ គ្មានពេលវេលានិងលទ្ធផលគ្រប់គ្រាន់ក្នុងការបង្កបង្កើនផលផង បានធ្វើឱ្យផ្ទៃដីដាំដុះដំណាំស្រូវប្រមាណ ៧៧ភាគរយបានត្រូវបោះបង់ចោលដែលជាហេតុ ធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះប្រមាណ៨៤ភាគរយ។[35] ដើម្បីផ្គត់ផ្គង់និងបំពេញតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងស្រុក អង្ករស្ទើរតែទាំងស្រុងនាំចូលពីបរទេសតាមរយៈជំនួយរបស់សហរដ្ឋអាមេរិក។ ដូចនេះប្រទេសកម្ពុជាបានក្លាយ ទៅជាប្រទេសមួយដែររស់នៅដោយសារជំនួយពីបរទេស ហើយការនាំចូលអង្ករគឺជាប្រធានបទយ៉ាងសំខាន់ក្នុងសម័យនោះ។

[33] ដៀប សុផល,កម្ពុជា នយោបាយ សេដ្ឋកិច្ច សង្គម (១៨៦៣-១៩៧៩), ២០០៨, ទំព័រ១៨០

[34] ដៀប សុផល,កម្ពុជា នយោបាយ សេដ្ឋកិច្ច សង្គម (១៨៦៣-១៩៧៩), ទំព័រ១៨៦

[35] វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា.ដំណាំស្រូវនៅកម្ពុជា . (ភ្នំពេញៈវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា,២០០៧), ទំព័រ១៣

### ១.៤.៥ ប្រព័ន្ធធារាសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យ[36] (១៩៧៥-១៩៧៩)

អាស្រ័យដោយភាពវឹកវរដែលបណ្តាលមកពីសង្គ្រាមជាច្រើននៅក្នុងប្រទេស អំពើពុករលួយ ការកេងប្រវ័ញ្ច គ្រប់រូបភាព និងភាពអត់ឃ្លាន ។ បានធ្វើឱ្យរបបសាធារណខ្មែរចុះអន់ថយ និងធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ចូលទៅ ក្រោមការកាន់អំណាចផ្តាច់ការរបស់ពួកខ្មែរក្រហមនៃរបបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលជិតបួនឆ្នាំ គឺចាប់តាំងពី ខែមេសាឆ្នាំ១៩៧៥ រហូតដល់ខែមករាឆ្នាំ១៩៧៩។

នៅលើពិភពលោក ពុំមានរបបទំនើបណាមួយឱ្យតម្លៃខ្ពស់លើការអភិវឌ្ឍប្រព័ន្ធស្រោចស្រពថាមានសារៈសំខាន់នោះទេ មានតែរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះដែលចាត់ទុកថាប្រព័ន្ធស្រោចស្រពមានសារៈសំខាន់។ ក្រោមការកាន់អំណោចរបស់ខ្មែរក្រហម វិស័យកសិកម្មកម្ពុជា ជាពិសេសការបង្កបង្កើនផលស្រូវមានការរីកចម្រើនបន្តិចបន្តួចឡើងវិញ ដោយពួកគេបានជន្លៀសប្រជាពលរដ្ឋពីទីក្រុង និងទីប្រជុំជននានា ឱ្យទៅកាន់ទីជនបទ និងបានបង្ខំប្រជាពលរដ្ឋទាំងនោះឱ្យធ្វើការសាងសង់សំណង់ធារាសាស្ត្រតូចធំ ជីកប្រឡាយខ្វែងខ្វាត់ លើកទំនប់ជាដើមដើម្បីពង្រីកប្រព័ន្ធស្រោចស្រព និងកាប់ឆ្ការព្រៃបន្ថែមទៀតដើម្បីពង្រីកផ្ទៃដីដាំដុះដំណាំស្រូវ។

ផ្ទៃដីដាំដុះស្រូវនៅមុនសម័យសង្គ្រាមមានប្រហែលជា ២.៥លានហិកតា ក្នុងនោះមានផ្ទៃដីប្រមាណជា ១៧.០០០ហិកតាប៉ុណ្ណោះដែលត្រូវបានស្រោស្រព។ នៅខែធ្នូ ឆ្នាំ១៩៧៥ ប៉ុល ពត បានមានប្រសាសន៍នៅក្នុងបទសម្ភាសនមួយថា ផែនការបក្ស គឺការស្រោចស្រពផ្ទៃដី១.៥លានហិកតា និងទិន្នផល ៣តោនក្នុងមួយហិកតា។ យុទ្ធសាស្ត្រសំខាន់សម្រាប់ការបង្កើនផលិតផលស្រូវ គឺការបង្កើនការដាំដុះស្រូវពីរ ទៅបីដងក្នុងមួយឆ្នាំ ទៅតាមតំបន់ជាច្រើនដែលអាចធ្វើបានតាមរយៈប្រព័ន្ធស្រោចស្រពនេះ។ មរតកនៃស្នាដៃក្នុងរបប ប៉ុល ពត គឺមានបរិមាណដ៏ច្រើននៃប្រឡាយទឹក ទំនប់ទឹក និងសំណង់ទាំងអស់ដែលបានសាងសង់នៅក្នុងប្រទេសកម្ពុជា លើកលែងតែតំបន់ភ្នំដែលមិនអាចសាងសង់ប្រឡាយបាន។ នៅក្នុងតំបន់ដែលមានប្រព័ន្ធស្រោចស្រពបែបបុរាណ ឬទំនប់ទឹកដែលត្រូវបានសាងសង់នៅសម័យបារាំង ត្រូវខ្មែរក្រហមបានពង្រីកទំនប់ទឹកបន្ថែម និងសាងសង់ថ្មីៗជាច្រើន។

វិសាលភាពនៃការបង្កើតស្នាដៃនេះ គឺមានលក្ខណៈចម្លែកខ្លាំងដែលធ្វើឱ្យ លោក ដាបៃលយូជៀវនលៀ ដែលជាអ្នកជំនាញម្នាក់ខាងកសិកម្ម និងប្រព័ន្ធស្រោចស្រពនៅកម្ពុជានៃលេខាធិការដ្ឋានទន្លេមេគង្គ បានសិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍប្រព័ន្ធស្រោចស្រពដោយប្រើ

[36] មជ្ឈមណ្ឌលឯកសារកម្ពុជា, លេខ៨៧ ខែមីនា ឆ្នាំ២០០៧, ឯកសារស្តីពី ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្នុងសម័យខ្មែរក្រហម

ប្រាស់នូវរូបភាពដែលចាប់តាមផ្កាយរណប នៅក្នុងបញ្ជីរាយឈ្មោះប្រព័ន្ធស្រោចស្រពនៅកម្ពុជា រវាងឆ្នាំ១៩៩៣ និង១៩៩៤ ដែល ៧៩ភាគរយនៃផែនការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ត្រូវបាន សម្រេចដោយជោគជ័យក្នុងរយៈពេលដ៏ខ្លីនៃរបបនេះ ហើយផែនការដែលមានមុនរបបកម្ពុជា ប្រជាធិបតេយ្យ ត្រូវបានរបបនេះធ្វើការផ្លាស់ប្តូរស្ទើរគ្រប់ផ្នែកទាំងអស់។

**១.៤.៦ប្រព័ន្ធធារាសាស្ត្រសម័យសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា**[37](**១៩៧៩-១៩៨៩**)

ទោះបីជាស្ថិតក្នុងទុក្ខវេទនាដោយសង្គ្រាមពុំរៃ នៅក្នុងស្រុកអស់រយៈពេលជាច្រើនឆ្នាំ យ៉ាងណាក៏ដោយ ក៏សេដ្ឋកិច្ចរដ្ឋនៅតែពឹងផ្អែកលើវិស័យកសិកម្ម ដែលប្រជាជន៩០%ជាកសិករ ប្រកបរបរធ្វើស្រែចម្ការ ពិសេសដំណាំស្រូវ។ ឆ្នាំ១៩៨៨ផលស្រូវមាន២.៧០០.០០០តោនហើយ កើនដល់ដល់៣.០០០.០០០តោននៅឆ្នាំ១៩៩០។ មហាសន្និបាតបក្សលើទី៥ បានចាត់វិធានការបី យ៉ាងដើម្បីផលិតស្បៀងគឺពង្រីកផ្ទៃដីកសិកម្ម បង្កើនរដូវដាំដុះ និងប្រពលវប្បកម្ម ។ ក្រោយពេល ដែលរបបផ្តាច់ការត្រូវបានបញ្ចប់នាឆ្នាំ១៩៧៩ វិស័យកសិកម្មកម្ពុជាជាពិសេសផលិតកម្មស្រូវ ត្រូវ បានរៀបចំ អភិវឌ្ឍឡើងវិញដោយផ្អែកលើការប្រមូលផ្តុំគ្នាជាក្រុមសាមគ្គីដែលមានសមាជិកពី ២០ ទៅ ២៥គ្រួសារក្នុងគោលបំណង ចែករំលែកគ្នាទៅវិញទៅមកនូវធនធានដែលខ្សត់ខ្សោយ និងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាបន្ទាន់មួយ ដែលទាក់ទងទៅនឹងបញ្ហាសន្តិសុខស្បៀង របស់ប្រជាពល រដ្ឋនៅក្នុងប្រទេស។

នៅកំឡុងឆ្នាំ១៩៨០ និងដើមឆ្នាំ១៩៩០ ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រភាគច្រើនគឺផ្តោតតែ លើប្រព័ន្ធធារាសាស្ត្រខ្នាតតូចប៉ុណ្ណោះ។ ចាប់ពីពេលនោះមកផ្ទៃដីដាំដុះដំ ដំណាំស្រូវបានកើនពី ១.៤លានហិកតារហូតដល់១.៩លានហិកតា ឯទិន្នផលក៏មានការកើនឡើងពី១.២តោនក្នុងមួយ ហិកតា ដល់១.៤តោនក្នុងមួយហិកតាផងដែរ។ នៅក្នុងរយៈពេលនេះ ផលិតកម្មស្រូវមានការកើន ឡើងខ្លាំង បើទោះជាមានភាពប្រែប្រួលខ្លះៗដោយកត្តាអាកាសធាតុក៏ដោយ។

## ១.៥ ស្ថានភាពប្រព័ន្ធធារាសាស្ត្រនាពេលបច្ចុប្បន្ន

យោងតាមទីតាំងភូមិសាស្ត្ររបស់ប្រទេសកម្ពុជា និងរបបទឹកភ្លៀងពីតំបន់ត្រូពិច ប្រទេស កម្ពុជាមានប្រភពទឹកយ៉ាងសំបូរសម្រាប់បម្រើឱ្យវិស័យកសិកម្ម ឧស្សាហកម្ម វារីវប្បកម្ម ការដឹក ជញ្ជូន និងគោលដៅនៃការប្រើប្រាស់ទឹកក្នុងស្រុកផ្សេងៗទៀត។ នៅកំឡុងឆ្នាំ១៩៨០ និងដើមឆ្នាំ ១៩៩០ ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រភាគច្រើនគឺផ្តោតតែលើប្រព័ន្ធធារាសាស្ត្រខ្នាតតូច ប៉ុន្តែ ក្រោយការបង្កើតក្រសួងធនធានទឹក និងឧតុនិយមនៅឆ្នាំ១៩៩៩ គេបានបង្វែរចំនុចដោយផ្តោត

[37] វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា.ដំណាំស្រូវនៅកម្ពុជា . (ភ្នំពេញ៖វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ កសិកម្មកម្ពុជា,២០០៧), ទំព័រ១៥-១៦

លើប្រព័ន្ធខ្នាតមធ្យម និងខ្នាតធំវិញ ដោយសារមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយជាដើម។

ជាក់ស្តែងនាឆ្នាំ ១៩៩៨ ប្រព័ន្ធធារាសាស្ត្រមានលទ្ធភាពស្រោចស្រពលើផ្ទៃដីបង្កបង្កើនផលស្រូវ ៤០៧.០០០ ហិកតា ស្មើនឹងប្រមាណ ១៨ ភាគរយ នៃផ្ទៃដីបង្កើនផលសរុបនាឆ្នាំ ១៩៩៨។[38]កាលពីឆ្នាំ២០០៥ ផ្ទៃដីដាំដុះដំណាំកសិកម្មនៅកម្ពុជាមានទំហំ ២.៨៣លានហិកតា ដែលក្នុងនោះប្រមានណជា ២.៣៧លានហិកតាគឺជាផ្ទៃដីដាំដុះដំណាំស្រូវ ហើយផ្ទៃដីស្រោចស្រពត្រូវបានប៉ាន់ប្រមាណថាមានទំហំ ៥៨៨,០០០ហិកតា ដែលស្មើរនឹង២១%នៃផ្ទៃដីដាំដុះ និង ២៥%នៃដីស្រែ (រាជ រដ្ឋាភិបាលកម្ពុជា ២០០៥)។ តាមរយៈយុទ្ធសាស្ត្រកសិកម្ម និងទឹក ឆ្នាំ ២០០៦-២០១០ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្ត មិនត្រឹមតែបង្កើនផ្ទៃដីស្រោចស្រពឱ្យដល់ ៦៥០,០០០ហិកតា មុនឆ្នាំ២០១០ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំពង្រីកផ្ទៃដីដាំដុះឱ្យបាន ៣.៥លានហិកតាទៀតផង ដែលក្នុងនោះ ២.៥លានហិកតាជាផ្ទៃដីសម្រាប់ការផលិតស្រូវ។[39]

នៅក្នុងឆ្នាំ២០១០ ផ្ទៃដីស្រោចស្រពត្រូវបានរាយការណ៍ថាមានទំហំប្រមាណជា៤២%នៃផ្ទៃដីស្រែដែលមានទំហំប្រហែលជា ១.១៦លានហិកតា។ ប្រការនេះ បានបង្ហាញនូវសមទ្ធិផលខ្ពស់មួយ ប្រសិនបើប្រៀបធៀបចំណុចដៅនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ ដែលគ្រោងសម្រេចបានផ្ទៃដីដែលមានប្រព័ន្ធធារាសាស្ត្រ ឬប្រព័ន្ធស្រោចស្រពទំហំ ៦៥០,០០០ ហិកតា មុនដំណាច់ឆ្នាំ២០១០។[40]

នៅចុងឆ្នាំ២០១៣ ប្រព័ន្ធធារាសាស្ត្រមានលទ្ធភាពស្រោចស្រព លើផ្ទៃដីប្រមាណជា ១,៤៨៥,៦៧០ហិកតា នៃផ្ទៃដីដាំដុះសរុបក្នុងឆ្នាំ២០១៣។[41] រហូតដល់ដំណាច់ឆ្នាំ២០១៧ ប្រព័ន្ធធារាសាស្ត្រមានលទ្ធភាពស្រោចស្រពលើផ្ទៃដីបង្កបង្កើនផលប្រមាណជា ១.៧១៦.៧២០ហិកតា ស្មើនឹងប្រមាណ ៥៩ ភាគរយ នៃផ្ទៃដីបង្កបង្កើនផលសរុបនៅឆ្នាំ២០១៧។[42]

---

[38] ក្រសួងធនធានទឹក និងឧតុនិយម,២០១៨

[39] ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ពីអត្ថប្រយោជន៍ និងបញ្ហាប្រឈម របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល, ២០១១, ទំព័រ១

[40] ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ពីអត្ថប្រយោជន៍ និងបញ្ហាប្រឈម របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល, ២០១១, ទំព័រ១

[41] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨), ទំព័រ

[42] ក្រសួងធនធានទឹក និងឧតុនិយម,២០១៨

### ១.៥.១ ទំហំខ្នាតនៃប្រព័ន្ធធារាសាស្ត្រ[43]

ប្រព័ន្ធធារាសាស្ត្រ ត្រូវបានបែងចែកទៅតាមទំហំផ្ទៃដីប្រើប្រាស់ទឹកដែលបានកំណត់ដោយក្រសួងធនធានទឹក និងឧតុនិយម ដែលមានចែងដូចខាងក្រោមៈ

- **ប្រព័ន្ធធារាសាស្ត្រខ្នាតតូច** គឺជាប្រព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីមិនលើសពី ២០០ហិកតា។
- **ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម** គឺជាប្រព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីចាប់ពី ២០០ ទៅ ៥០០០ហិកតា។
- **ប្រព័ន្ធធារាសាស្ត្រខ្នាតធំ** គឺជាប្រព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីចាប់ពី ៥០០០ហិកតាឡើងទៅ។

### ១.៥.២ អត្ថប្រយោជន៍របស់ប្រព័ន្ធធារាសាស្ត្រ[44]

ប្រព័ន្ធធារាសាស្ត្រ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជាៈ

- ផ្តល់ទឹកដើម្បីបង្កបង្កើនផលដំណាំផ្សេងៗ ជាពិសេសដំណាំស្រូវ
- ធ្វើឱ្យកសិករទទួលបាននូវទិន្នផលខ្ពស់
- កសិករអាចបង្កបង្កើនផលស្រូវបានពីរ ទៅបីដងក្នុងមួយឆ្នាំ
- ធានាបាននូវសុវត្ថិភាពស្បៀងសម្រាប់កសិករ
- កសិករមានជីវភាពល្អប្រសើរជាងមុន
- អន្តរាគមន៍ក្នុងពេលមានគ្រោះរាំងស្ងួត
- រំដោះទឹកចេញនៅពេលមានទឹកជំនន់កើតឡើង
- លើខ្នងប្រឡាយអាចផ្តល់ជាផ្លូវសម្រាប់ធ្វើដំណើរ និងការដឹកជញ្ជូនផ្សេងៗ
- កសិករមានឱកាសសម្រាប់ធ្វើការអភិវឌ្ឍគម្រោងផ្សេងៗទៀត។

### ១.៥.៣ បញ្ហាប្រឈមក្នុងវិស័យធារាសាស្ត្រ[45]

ថ្វីបើប្រព័ន្ធធារាសាស្ត្របានផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ក្នុងនោះដែរផងដែប្រព័ន្ធធារា

[43] ការរៀបចំក្រុមសហគមន៍កសិករប្រើប្រាស់ទឹក និងកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ របស់មជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ, ២០១១, ទំព័រ៩

[44] ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ពីអត្ថប្រយោជន៍ និងបញ្ហាប្រឈម របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល, ២០១១, ទំព័រ៩

[45] ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ពីអត្ថប្រយោជន៍ និងបញ្ហាប្រឈម របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល, ២០១១, ទំព័រ១៤-១៦

សាស្ត្រតែងតែជួបប្រទះនូវបញ្ហាជាច្រើនដែលកើតមានឡើងជាញឹកញាប់ គឺបណ្តាលមកពីកត្តាដូចខាងក្រោម៖

- **ការគ្រប់គ្រង** គឺជាបញ្ហាមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ការប្រើប្រាស់ទឹកដែលមិនមានការវិភាគច្បាស់លាស់ គ្មានក្រុមកសិករប្រើប្រាស់ទឹក ខ្វះការទទួលខុសត្រូវ និងការចូលរួមថែទាំពីកសិករ បានធ្វើឱ្យមានការកាប់ប្រឡាយយកទឹក ឬធ្វើទំនប់ក្នុងប្រឡាយ ការជីកអន្លុងក្នុងប្រឡាយចាប់ត្រី ការកាប់ភ្លឺប្រឡាយបង្ហូរទឹកមិនដាក់លូ ការបើកទ្វារទឹកដាក់ទ្រូចាប់ត្រី តាមសំណង់ធារាសាស្ត្រ បណ្តាលឱ្យទំនប់ប្រឡាយ និងសំណង់ត្រូវហូរច្រោះដាច់។ ដែលកត្តាទាំងនេះស្ទើរតែកើតមានគ្រប់ទីកន្លែងនៃប្រព័ន្ធធារាសាស្ត្រ។
- **ការផ្គត់ផ្គង់ទឹកមិនគ្រប់គ្រាន់** បញ្ហាប្រឈមមួយក្នុងចំណោមក្នុងចំណោមបញ្ហាចម្បងជាងគេនៅក្នុងប្រព័ន្ធធារាសាស្ត្រ គឺការមិនមានទឹកគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ទឹកដល់ផ្ទៃដីដែលបានគ្រោងសម្រាប់ស្រោចស្រព។ ការផ្គត់ផ្គង់ទឹកមិនបានគ្រប់គ្រាន់ ត្រូវបានពន្យល់ដោយសារកត្តាពីរយ៉ាង ១) បរិមាណទឹកប្រែទៅជាមិនសូវសម្បូរដោយសារភ្លៀងតិច ២) តម្រូវការទឹកកាន់តែច្រើនដោយសារការស្រូបយកនៃប្រព័ន្ធធារាសាស្ត្រនានាដែលស្ថិតនៅឆ្ងាយខាងលើខ្សែទឹក។
- **ប្រព័ន្ធមិនពេញលេញ** ប្រព័ន្ធធារាសាស្ត្រភាគច្រើន មានលក្ខណៈមិនពេញលេញដោយសារវាមិនមានសំណង់ស្ទាក់ទឹកសម្រាប់គ្រប់គ្រងទឹកក្នុងប្រព័ន្ធនិងប្រឡាយរងទី៣ ជាពិសេសប្រព័ន្ធធារាសាស្ត្រទាំងឡាយណា ដែលទទួលហិរញ្ញប្បទានពីរាជរដ្ឋាភិបាលកម្ពុជា។ ដោយប្រព័ន្ធភាគច្រើនមានតែក្បាលហុងទឹក និងប្រឡាយមេប៉ុណ្ណោះ។
- **កិច្ចដំណើរការ និងការគ្រប់គ្រងរបស់សហគមន៍កសិករប្រប្រាស់ទឹក** (Farmer Water Users Communities = FWUCs) បើទោះបីជា FWUCs ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក៏ដោយ ក៏មិនមែនមានន័យថា FWUCs ទាំងនោះសុទ្ធតែដំណើរការយ៉ាងសកម្មនោះទេ។ កិច្ចដំណើរការរបស់ FWUCs ត្រូវបានសង្កេតឃើញថាមានភាពខុសគ្នាពីករណីមួយទៅករណីមួយដូចជា ១) សមត្ថភាពមិនគ្រប់គ្រាន់របស់ FWUCs 2) កង្វះការផ្គត់ផ្គង់ទឹកក្នុងធារាសាស្ត្រ ៣)ប្រព័ន្ធមិនពេញលេញ ៤) កង្វះការចូលរួមពីកសិករ និងគ្មានឆន្ទៈក្នុងការបង់ប្រាក់លើសេវាប្រើប្រាស់ទឹក ៥) កង្វះការលើកទឹកចិត្តសម្រាប់សមាជិក FWUCs។ ក្នុង

ករណីខ្លះ FWUCs មិនហ៊ានបង្ខំឱ្យអនុវត្តន៍បទបញ្ជារបស់ខ្លួន និងការប្រមូលថ្លៃទឹកនោះទេ ដោយសារប្រព័ន្ធមិនបានផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់ជូនដល់ប្រជាកសិករ។ ពេលខ្លះដោយសារប្រព័ន្ធមិនពេញលេញ ក៏ជាកត្តាមួយដែលធ្វើឱ្យរាំងដល់សមត្ថភាព FWUCs ក្នុងការប្រមូលថ្លៃទឹក ដោយសារកង្វះប្រឡាយរងទី៣ កសិករត្រូវចំណាយប្រាក់ជាច្រើនការបូមទឹកបញ្ចូលស្រែរបស់ខ្លួន។ ដោយសារមូលហេតុនះ ជារឿយៗកសិករសំដែងនូវការមិនសប្បាយចិត្តចំពោះ FWUCs ដែលជាហេតុធ្វើឱ្យពួកគាត់មិនហ៊ានទៅប្រមូលថ្លៃទឹក។

- **សំណង់ និងប្លង់** បញ្ហារួមលើការងារបច្ចេកទេស គឺអ្នកបច្ចេកទេស (អ្នកគ្រោងប្លង់) មិនបានធ្វើការសិក្សាឱ្យបានលំអិតពីបរិមាណធារទឹក ឱ្យបានច្បាស់លាស់មុននិងគ្រោងប្លង់ អ្នកគ្រោង ប្លង់មិនបានដឹងពីកម្រិតលំហូរទឹកដែលមាននៅក្នុងអាង ជាហេតុធ្វើឱ្យមានការបាត់បង់ទឹកដោយរំហូត ជំរាប និងការបាត់បង់តាមប្រព័ន្ធធារាសាស្ត្រទាំងមូល។
- **គ្រោះមហន្តរាយ** ភាគច្រើននៃប្រព័ន្ធធារាសាស្ត្រត្រូវទទួលរងគ្រោះធម្មជាតិ និងមនុស្សបង្កើតឡើងតាមរូបភាពផ្សេងៗ ការហូរច្រោះពីទឹកភ្លៀង ឬគំរាមគំហែងពីទឹកជំនន់រៀងរាល់ឆ្នាំបណ្ដាលឱ្យទំនប់ ប្រឡាយ សំណង់ត្រូវហូរ ច្រោះដាច់ និងស្រុតសំណង់ជាដើម។

### ១.៥.៤ គោលនយោបាយលើគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

ទឹក ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចឱ្យបាននូវគោលដៅចំបងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនសមត្ថភាពយេនឌ័រ ការអភិវឌ្ឍសេដ្ឋកិច្ច សន្តិសុខស្បៀង និងការអភិរក្សបរិស្ថាន ហើយទឹកគឺជាធនធានដែលទ្រទ្រង់ដល់វិស័យនានាដូចជាកសិកម្ម ឧស្សាហកម្ម ថាមពល នាវាចរណ៍ ទេសចរណ៍ ជលផល ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងការប្រើប្រាស់ក្នុងគ្រួសារជាដើម។ ដូចនេះ ការបែងចែកទឹកត្រូវតែធ្វើឱ្យមានតុល្យភាពចំពោះតម្រូវការក្នុងវិស័យខាងលើ ដើម្បីប្រើប្រាស់ទឹកឱ្យអស់ពីលទ្ធភាពសម្រាប់ផលប្រយោជន៍ជាតិ។

ជារៀងរាល់ឆ្នាំ ប្រជាកសិករតែងតែប្រឈមនឹងការខ្វះខាតទឹក គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ជាដើម។ បញ្ហាទាំងនេះបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ផលិតផលកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសង្គម។ នាពេលបច្ចុប្បន្នហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅមានកម្រិតនៅឡើយ ហើយលទ្ធភាពផ្គត់ទឹកពុំមានលទ្ធភាពគ្រប់គ្រាន់សម្រាប់វិស័យកសិកម្ម។ ដោយសារប្រពន្ធ័ធារា

សាស្ត្រខ្លះមានសភាពចាស់ទ្រុឌទ្រោម ដែលមានការលំបាកដល់ការរក្សាទឹក ការបែងចែកទឹក ការផ្តល់ទឹកសម្រាប់វិស័យកសិកម្ម និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

ដើម្បីគ្រប់គ្រងទឹកឱ្យបានប្រសើរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើនការវិនិយោគលើការស្តារ និងការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ក្នុងការគ្រប់គ្រងធនធានទឹក ដើម្បីជៀសវាងការប្រើប្រាស់ទឹកគ្មានសណ្តាប់ធ្នាប់ និងការខូចខាតទៅលើធនធាន ដែលបង្ករភាពអន្តរាយដល់ការអភិវឌ្ឍយូរអង្វែងរបស់ប្រទេសជាតិ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើនពាក់ព័ន្ធនិងការគ្រប់គ្រងធនធានទឹកនៅកម្ពុជាដូចជា[46]៖

១. ការជំរុញវិត្តារកម្មប្រព័ន្ធធារាសាស្ត្រ តាមរយៈការគៀងគរធនធានសាធារណៈ និងធនធានពីប្រភពផ្សេងទៀត ដើម្បីបង្កើនសមត្ថភាពស្រោចស្រពប្រកបដោយវិចារណាភាព ដោយយកចិត្តទុកដាក់លើការលើកកម្ពស់ស្តង់ដារ និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ក៏ដូចជាប្រសិទ្ធភាពនៃការ វិនិយោគគួបផ្សំនឹងការកសាងអាងស្តុកទឹកបម្រុង និងការបន្តរៀបចំប្រឡាយស្រោចស្រពឱ្យបានពេញលេញដោយ យកចិត្តទុកដាក់ផងដែរដល់ភាពចាំបាច់ក្នុងការត្រៀមខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

២. ការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយផ្តោតលើការពង្រឹងក្របខណ្ឌគោលនយោបាយ ក្របខណ្ឌគតិយុត្ត និងយន្តការនៃការប្រើប្រាស់ទឹក ការថែទាំ និងហិរញ្ញប្បទានតាមរយៈការជំរុញរៀបចំ និងអនុវត្តផែនការមេ សម្រាប់ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការជំរុញរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹក ការគ្រប់គ្រងអាងទន្លេ ការគ្រប់គ្រងគុណភាពទឹក និងការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស។

៣. ការជំរុញការសម្របសម្រួលស្ថាប័ន សំដៅធ្វើសមាហរណកម្មលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រជាមួយនឹងការអភិវឌ្ឍវារីអគ្គិសនី និងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិនិយោគ និងការប្រើប្រាស់ធនធានទឹក។

៤. ការលើកកម្ពស់ចីរភាពនៃការប្រើប្រាស់ធនធានទឹក តាមរយៈការអនុវត្តនូវ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងច្បាប់ពាក់ព័ន្ធផ្សេងទៀត។

៥. ការលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់ តាមរយៈការសាងសង់ប្រព័ន្ធដោះទឹក ទំនប់ការពារទឹក អាងស្តុកទឹក និងប្រឡាយបង្ហៀរទឹកដើម្បីកាត់បន្ថយផលប៉ះពាល់ពី

[46] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នីតិកាលទី៥ នៃរដ្ឋសភា (២០១៣-២០១៨), ទំព័រ៦៣-៦៦

គ្រោះធម្មជាតិ។

៦. បន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ និងទីប្រជុំជន តាមរយៈការជំរុញអនុវត្ត យុទ្ធសាស្ត្រជាតិស្តីពី វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ២០១១-២០២៥ ព្រមទាំងការរៀបចំផែនការជាក់លាក់ និងការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន។

៧. ការបន្តការខិតខំប្រឹងប្រែង និងការពង្រីកយន្តការតាមដាន ព្យាករណ៍ និងផ្សព្វផ្សាយព័ត៌មានជលសាស្ត្រ និងឧតុនិយម ឱ្យបានទាន់ពេលវេលា និងឱ្យកាន់តែមានសុក្រឹតភាព ជាពិសេសសំដៅធានាសុវត្ថិភាពនៃការដាំដុះ និងត្រៀមទប់ទល់ នឹងបច្ច័យនៃគ្រោះមហន្តរាយជាយថាហេតុ។

៨. ការបន្តចូលរួមក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទឹក ដើម្បីធានាចីរភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានទឹក ក៏ដូចជាក្នុងការដោះស្រាយបច្ច័យអាក្រក់បណ្ដាលមកពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងពីការប្រែប្រួលអាកាសធាតុ។

### ១.៥.៥ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព[47]

ដើម្បីគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយស្តីពី ការគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម ដើម្បីលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រនៅក្នុងប្រទេស និងជួយដោះស្រាយកង្វះថវិការបស់រដ្ឋ និងម្ចាស់ជំនួយជាដើម។ គោលនយោបាយនេះ មានទិសដៅផ្តល់សិទ្ធិឱ្យកសិករធ្វើការគ្រប់គ្រង និងថែរក្សាប្រព័ន្ធធារាសាស្ត្រដោយខ្លួនពួកគាត់ផ្ទាល់ ដោយបង្កើតជាសហគមន៍កសិករប្រើប្រាស់ទឹក។

នៅខែមិថុនា ឆ្នាំ២០០០ ក្រសួងធនធានទឹក និងឧតុនិយម បានចេញផ្សាយនូវគោលនយោបាយមួយស្តីពី និរន្តរភាពនៃប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ដើម្បីឱ្យការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដំណើរការទៅមុខដោយប្រសិទ្ធិភាព និងយូរអង្វែងជាមួយនឹងការពិនិត្យមើលពីកំណើនប្រជាកសិករដែលបានចូលរួម ហើយនិងឈានទៅរកការកាត់បន្ថយតួនាទីរបស់រាជរដ្ឋាភិបាល។ គោលនយោបាយនេះ ក៏មានគោលបំណងស្វែងរកនូវការកសាងសមត្ថភាពមួយរបស់គណៈកម្មធិការប្រើប្រាស់ទឹក ដើម្បីបង្កើនការយល់ដឹងដល់ប្រជាកសិករ និងលើកទឹកចិត្តដល់ទីភ្នាក់ងារផ្តល់ជំនួយនានាដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមឱ្យមានប្រសិទ្ធភាព។

[47] អភិបាលកិច្ចទឹក , ការវិភាគស្ថានភាពក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ, ទំព័រ១៤

ការកសាងគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម នៅក្នុងឆ្នាំ២០០០ បានពឹងផ្អែកទាំងស្រុងទៅលើសារាចរណែនាំលេខ០១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងឆ្នាំ១៩៩៩ និងមានបំណងធ្វើឱ្យកាន់តែប្រសើរឡើងនូវការរៀបចំអភិបាលកិច្ចល្អរវាងសហគមន៍អ្នកប្រើប្រាស់ទឹក និងរាជរដ្ឋាភិបាល។ មិនតែប៉ុណ្ណោះ ត្រូវលើកទឹកចិត្តដល់ប្រជាកសិករឱ្យទទួលខុសត្រូវក្នុងការគ្រប់គ្រង និងថែរក្សាប្រព័ន្ធធារាសាស្ត្រដោយខ្លួនពួកគាត់ផ្ទាល់។ ក្រសួងធនធានទឹក និងឧតុនិយម បានធ្វើការអនុវត្តជាលើកដំបូងនូវគោលនយោបាយនេះ នៅក្នុងខេត្តចំនួន១១ ជុំវិញបឹងទន្លេសាប និងតាមដងទន្លេមេគង្គ ចាប់ពីឆ្នាំ២០០១ ដល់២០០៥។

នៅឆ្នាំ២០០៩ សារាចរស្តីពីគោលនយោបាយសម្រាប់ប្រព័ន្ធស្រោចស្រពដោយនិរន្តរភាពត្រូវបានអនុម័ត។ សារាចរនេះ បានទទួលស្គាល់គណៈកម្មាធិការប្រើប្រាស់ទឹក ថាជាអង្គភាពស្របច្បាប់មួយដែលមានសិទ្ធិដាក់ចេញនូវបទបញ្ញា ដាក់ទណ្ឌកម្ម មានសិទ្ធបើកគណនីផ្ទាល់ខ្លួននៅធនាគារ អាចខ្ចីប្រាក់ និងចុះកិច្ចសន្យាដោយស្របច្បាប់។ គោលនយោបាយនេះ ក៏បានរួមបញ្ចូលនូវការធ្វើកំណែទម្រង់មួយចំនួនផងដែរ ដែលក្នុងនោះមានដូចជា៖

- ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពនឹងត្រូវធ្វើឡើង នៅពេលដែលមានការស្នើរសុំរបស់ FWUCs ហើយ FWUCs ត្រូវចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោងអភិវឌ្ឍន៍ទាំងនោះ ដែលរួមមាន ការធ្វើសេចក្តីសម្រេចចិត្ត និងការសង្កេតនៅគ្រប់ជំហាននៃគម្រោងវិនិយោគមានដូចជា ការជួសជុល ការវិនិយោគ ការវាយតម្លៃ ការកែលម្អរ ក៏ដូចជាគម្រោងពង្រីកប្រព័ន្ធស្រោចស្រពបន្ថែមជាដើម។
- អ្នកប្រើប្រាស់ទឹក តម្រូវឱ្យបង់ប្រាក់ជាប្រចាំ សម្រាប់ចំណាយក្នុងប្រតិបត្តិការ និងថែរក្សាព្រមទាំងបង្កើតមូលនិធិដើម្បីប្រមូលប្រាក់ជួសជុលក្នុងករណីបន្ទាន់។
- ប្រព័ន្ធស្រោចស្រពនឹងត្រូវបានថែរក្សា និងកែលម្អរជាប្រចាំ ក្រោមកិច្ចសហការគ្នារវាង FWUCs និងរាជរដ្ឋាភិបាល។
- ការផ្គត់ផ្គង់ទឹកនឹងត្រូវចាត់ចែងឡើងដោយ FWUCs ក្នុងលក្ខណ្ឌសមធម៌ និងដែលអាចជឿទុកចិត្តបាន។
- ក្រសួងធនធានទឹក និងឧតុនិយម ទទួលខុសត្រូវផ្នែកបច្ចេកទេស និងការគ្រប់គ្រង តាមដាន និងវាយតម្លៃជាមួយនិងតម្រូវការគាំទ្រផ្សេងៗទៀត។

### ១.៥.៦ ការពង្រឹងសមត្ថភាពស្ថាប័នលើវិស័យធនធានទឹក[48]

នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្ពស់លើការពង្រឹង និងការកសាងសមត្ថភាពបន្ថែមដល់ស្ថាប័នពាក់ព័ន្ធនឹងធនធានទឹក ជាពិសេសក្រសួងធនធានទឹក និងឧតុនិយម ក្នុងការគ្រប់គ្រងធនធានទឹកឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពខ្ពស់។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការចែករំលែក និងផ្ទេរភារកិច្ចទទួលខុសត្រូវមួយចំនួនឱ្យទៅថ្នាក់មូលដ្ឋាន ដូចនេះទាមទារឱ្យមានការបណ្តុះបណ្តាល បន្ថែមទៀតនូវសមត្ថភាពដល់ថ្នាក់ក្រោមជាបន្តបន្ទាប់រហូតដល់ប្រជាពលរដ្ឋខ្មែរទាំងមូលតែម្តង។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងបង្កើនសមត្ថភាពដល់មន្ត្រីគ្រប់លំដាប់ថ្នាក់រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយដូចតទៅៈ

១. បន្តពង្រឹងសមត្ថភាពដល់មន្ត្រីថ្នាក់កណ្តាល ថ្នាក់ក្រោមជាបន្តបន្ទាប់ សហគមន៍ ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ឱ្យយល់ដឹងអំពីអត្ថប្រយោជន៍នៃទឹក ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងណែនាំឱ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការគ្រប់គ្រង ការថែរក្សាការអភិរក្ស និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ និរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីតាមមធ្យបាយនានាដូចជា រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលតាមគ្រឹះស្ថានសិក្សា ធ្វើតាមការផ្សព្វផ្សាយ តាមរយៈព្រឹត្តិប័ត្រព័ត៌មានទស្សនាវដ្តី បណ្តាញវិទ្យុ និងទូរទស្សន៍។ល។

២. បង្កើតគោលការណ៍ណែនាំក្នុងការចូលរួមរបស់សហគមន៍នៅក្នុងវិស័យធនធានទឹក។

៣. ជំរុញ និងលើកស្ទួយដល់ស្ត្រី ឱ្យមានតួនាទីនៅក្នុងការគ្រប់គ្រងធនធានទឹក និងការផ្គត់ផ្គង់សេវាកម្មទឹក។

៤. បង្កើនការណែនាំជាបន្តបន្ទាប់នូវបែបបរដ្ឋបាល និងគ្រប់គ្រងតាមស្តង់ដាជាតិ និងអន្តរជាតិដល់ស្ថាប័ននានាដែលពាក់ព័ន្ធនឹងទឹក។

៥. រៀបចំកញ្ចប់ថវិកា ក្នុងការពង្រឹងសមត្ថភាពដល់មន្ត្រីនៅក្នុងស្ថាប័នវិស័យទឹក នៅតាមថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋានជាបន្តបន្ទាប់។

### ១.៥.៧ គោលនយោបាយហិរញ្ញវត្ថុលើវិស័យធនធានទឹក[49]

និរន្តរភាពហិរញ្ញវត្ថុ គឺជាបញ្ហាសំខាន់មួយនៅក្នុងវិស័យនានានៃសេដ្ឋកិច្ច រួមទាំងវិស័យធនធានទឹកផងដែរ។ ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកទាមទារនូវការវិនិយោគទន់ដ៏ច្រើន។

[48] គោលនយោបាយលើវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា, (២០០៤), ទំព័រ១៨-១៩

[49] គោលនយោបាយលើវិស័យធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា, (២០០៤), ទំព័រ១៩-២០

នាពេលបច្ចុប្បន្ននេះ ការផ្តល់ទុនវិនិយោគប្រចាំឆ្នាំលើការគ្រប់គ្រង និងអភិវឌ្ឍវិស័យធនធានទឹកនៅកម្ពុជានៅមានកម្រិតនៅឡើយ។ ពាក់ព័ន្ធដល់ថវិកាសម្រាប់ទ្រទ្រង់ដល់ការស្តារ ការថែទាំ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ប្រព័ន្ធព្យាករណ៍ឧតុនិយម និងជលសាស្ត្រក៏នៅមានកម្រិត។

បច្ចុប្បន្ននេះ ការអភិវឌ្ឍថាមពលវារីអគ្គិសនី និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមទីក្រុង និងទីរួមខេត្ត និងទីប្រជុំជននានាកំពុងតែមានការចាប់អារម្មណ៍ ព្រមទាំងបាននឹងកំពុងបណ្តាក់ទុនពីក្រុមអ្នកវិនិយោគឯកជនក្នុងស្រុក និងបរទេស និងភ្នាក់ងារផ្តល់ជំនួយនានា។

ដើម្បីជំរុញ និងធានាបានក្នុងការដោះស្រាយបាននូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយដូចខាងក្រោម៖

១. លើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួលដល់អ្នកវិនិយោគ សហគ្រាសឯកជន និងសហគមន៍ ក្នុងការចូលរួមលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យធនធានទឹក។

២. រៀបចំផ្ទេរជាបណ្តើរៗនូវប្រព័ន្ធធារាសាស្ត្រ ឱ្យទៅសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីធ្វើការគ្រប់គ្រង ប្រើប្រាស់ និងថែទាំដោយខ្លួនឯង។

៣. ត្រួតពិនិត្យ និងកែសម្រួលក្នុងករណីចាំបាច់លើការកំណត់ថ្លៃទឹក សម្រាប់បម្រើឱ្យការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រដោយសហគមន៍កសិករប្រើប្រាស់ទឹក។

៤. ផ្ទេរប្រព័ន្ធផ្គត់ផ្គង់ប្រព័ន្ធសេវាកម្មទឹកស្អាត ដែលនៅក្រោមការគ្រប់គ្រងរបស់រដ្ឋឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគ្រាសឯកជន តាមរយៈជួល ការធ្វើកិច្ចសន្យាគ្រប់គ្រង ឬតាមរយៈរូបភាពផ្សេងៗទៀត ដែលធ្វើឡើងតាមនីតិវិធីជ្រើសរើសតាមលក្ខណៈប្រកួតប្រជែងសេរី។

៥. ត្រួតពិនិត្យ និងកែសម្រួលក្នុងករណីចាំបាច់លើការកំណត់តម្លៃសេវាផ្គត់ផ្គង់ទឹកស្អាតដែលគ្រប់គ្រងដោយសហគ្រាស ឬក្រុមហ៊ុនឯកជន។

៦. ត្រួតពិនិត្យ និងកែសម្រួលក្នុងករណីចាំបាច់លើការកំណត់តម្លៃសេវាផ្គត់ផ្គង់ថាមពលវារីអគ្គិសនី ដែលគ្រប់គ្រងដោយសហគ្រាស ឬក្រុមហ៊ុនឯកជន។

៧. ទទួលខុសត្រូវលើការចំណាយថវិកាសម្រាប់ការគ្រប់គ្រង និងការកាត់បន្ថយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

៨. បន្តស្វែងរកជំនួយពីបរទេស និងបង្កើនកញ្ចប់ថវិកាជាតិ សម្រាប់បម្រើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យធនធានទឹក។

## ១.៦ សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក យើងឃើញថាប្រទេសកម្ពុជាក៏មានការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រតាំងពីយូរយាណាស់មកហើយដែរ បើប្រៀបធៀបជាមួយការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រនៅលើពិភពលោក ប៉ុន្តែ ដោយសារតែប្រទេសកម្ពុជា មានការជួបប្រទះនិងសង្គ្រាម និងដោយសារអាយុកាលនៃប្រព័ន្ធធារាសាស្ត្ររួមផ្សំផង បានធ្វើឱ្យប្រព័ន្ធធារាសាស្ត្រនៅសល់ចំនួនតិចតួចបំផុត ដែលអាចនៅប្រើប្រាស់ បាន ហើយប្រព័ន្ធធារាសាស្ត្រខ្លះមានសភាពចាស់ទ្រុឌទ្រោម ដែលមានការលំបាកដល់ការរក្សាទឹក ការបែងចែកទឹក ការផ្គត់ទឹកសម្រាប់វិស័យកសិកម្ម និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

បន្ទាប់ពីបញ្ចប់សង្គ្រាមរួចមក រជ្ជកាលថ្មីនៃការគ្រប់គ្រងធនធានទឹក គឺបានចាប់ផ្តើមនៅពេលដែលក្រសួងធនធានទឹកត្រូវបានបង្កើតឡើង អមដោយមន្ទីរជំនាញគ្រប់ខេត្ត ក្រុង និងសហគមន៍ប្រើប្រាស់ទឹកក៏ត្រូវបានបង្កើតផងដែរ។ ក្នុងបរិបថថ្មីនេះ ហេដ្ឋារចនាសម្ព័ន្ធដែលដែលបម្រើឱ្យការបង្កបង្កើនផលលើវិស័យកសិកម្មត្រូវបានលើកកម្ពស់ និងយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ដើម្បីធ្វើឱ្យសម្រេចបាននូវ គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនទិន្នផលស្រូវសម្រាប់ផ្គត់ផ្គង់នៅក្នុងស្រុកផងដែរ និងការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិផងដែរ។

# ជំពូកទី២

# ស្ថានភាពទូទៅនៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក

## ២.១ ប្រវត្តិនៃការកកើត និងទីតាំងភូមិសាស្ត្រប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក[50]

ប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក បានចាប់ផ្តើមស្ថាបនានៅចន្លោះឆ្នាំ១៩៧៧-១៩៧៨ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (របបប៉ុល ពត)។ ដូចដែលបានដឹងរួចមកហើយថា ប្រព័ន្ធធារាសាស្ត្រជាច្រើនដែលបានសាងសង់នាសម័យនោះគឺមិនត្រឹមត្រូវទៅតាមបច្ចេកទេស ដែលជាហេតុធ្វើឱ្យមានភាពលំបាក់ដល់ដំណើរការនៃការគ្រប់គ្រងទឹកមកដល់ពេលបច្ចុប្បន្ន។ ប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ត្រូវបានស្តារ និងសាងសង់ឡើងវិញឱ្យត្រឹមត្រូវតាមបច្ចេកទេសក្នុងឆ្នាំ ២០១០ ក្រោមកម្ចីសម្បទានពី សាធារណៈរដ្ឋប្រជាមានិតចិន (កម្ចីអនុគ្រោះ) និងបានបញ្ចប់ជាស្ថាពរនៅក្នុងឆ្នាំ២០១៤ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងធនធានទឹក និងឧតុនិយម។

ប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក លាតសន្ធឹងតាមព្រែកកំពង់ត្របែក និងមានទីតាំងស្ថិតស្រុកកំពង់ត្របែក ស្រុកបាភ្នំ និងស្រុកព្រះស្តេច ខេត្តព្រៃវែង។ ដែលមានចំងាយ ២៥គីឡូម៉ែត្រពីទីរួមខេត្ត និង ៧០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។

មុនពេលមានការពង្រីក និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ប្រព័ន្ធនេះគ្រាន់តែជាព្រែកមួយ និងមានលទ្ធភាពផ្គត់ផ្គង់ទឹកលើផ្ទៃដីដាំដុះស្រូវប្រាំងប្រមាណជាង ២០០០ ហិកតា និងស្រូវវស្សាប្រមាណជា ៥០០០ហិកតា ហើយប្រព័ន្ធនេះក៏មិនទាន់មានស្ថានីយ៍បូមទឹកសម្រាប់ការស្រោចស្រពនោះដែរ។ គឺប្រជាកសិករប្រើប្រាស់នូវម៉ាស៊ីនបូមទឹកសម្រាប់ការស្រោចស្រពនៅរដូវប្រាំង។ ក្រោយមានការពង្រីក និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក មានសក្តានុពលផ្គត់ផ្គង់ទឹកស្រោចស្រពលើផ្ទៃដីស្រូវវស្សាចំនួន ៩០០០ហិកតា និងផ្ទៃដីស្រូវប្រាំង ៦០០០ហិកតា។ ប្រព័ន្ធនេះមានប្រភពទឹកមកពីស្ទឹងកំពង់ត្របែក ដែលជាដៃទន្លេមេគង្គក្រោម ហើយការផ្គត់ផ្គង់ទឹកមានរយៈពេលពេញមួយឆ្នាំ។

[50] គម្រោងកិច្ចដំណើរការ និងការងារជួសជុលប្រព័ន្ធធារាសាស្ត្រការពារទឹកជំនន់ និងស្រោចស្រពកំពង់ត្របែក របស់នាយកដ្ឋានធារាសាស្ត្រកសិកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម,២០១៨, ទំព័រ១

## ២.២ ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក

### ២.២.១ ដំណើរការសាងសង់[51]

ដូចដែលបានបញ្ជាក់នៅខាងលើរួចហើយថា ប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ត្រូវបានស្តារ និងសាងសង់ឡើងវិញឱ្យត្រឹមត្រូវតាមបច្ចេកទេសក្នុងឆ្នាំ២០១០ ក្រោមកម្ចីសម្បទានពីសាធារណៈរដ្ឋប្រជាមានិតចិន និងបានបញ្ចប់ជាស្ថាពរនៅក្នុងឆ្នាំ២០១៤។ ក្រោយពីការស្តារ និងសាងសង់ឡើងវិញ ប្រព័ន្ធធារាសាស្ត្រនេះរួមមាន៖

១. ទំនប់សណ្តារការពារទឹកជំនន់កំពង់ត្របែកប្រវែង ៣៦គីឡូម៉ែត្រ

២. ប្រឡាយមេធំ ៣ខ្សែប្រវែង ២២.១៩០ម៉ែត្រ

- ខ្សែទី១ = ១៦.៩៤០ម
- ខ្សែទី២ = ២.៨៥០ម
- ខ្សែទី៣ = ២.៤០០ម

៣. ប្រឡាយមេ ១២ខ្សែប្រវែង ៣១.២៤០ម៉ែត្រ

- ខ្សែទី១ = ១.៦៧០ម
- ខ្សែទី២ = ២.៧២០ម
- ខ្សែទី៣ = ២.៨៤០ម
- ខ្សែទី៤ = ៣.០៩០ម
- ខ្សែទី៥ = ២.២៤០ម
- ខ្សែទី៦ = ២.២៥០ម
- ខ្សែទី៧ = ២.៩៥០ម
- ខ្សែទី៨ = ២.៣៤០ម
- ខ្សែទី៩ = ៣.២៣០ម
- ខ្សែទី១០ = ២.៥៦០ម
- ខ្សែទី១១ = ២.៧៧០ម
- ខ្សែទី១២ = ២.៥៨០ម

៤. ប្រឡាយរង ០៣ខ្សែប្រវែង ៤.៩២០ម៉ែត្រ

- ខ្សែទី១ = ១.៣៧០ម

[51] គម្រោងកិច្ចដំណើរការ និងការងារជួសជុលប្រព័ន្ធធារាសាស្ត្រការពារទឹកជំនន់ និងស្រោចស្រពកំពង់ត្របែក របស់នាយកដ្ឋានធារាសាស្ត្រកសិកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម,២០១៨, ទំព័រ២

- ខ្សែទី១ = ២.៥១០ម
- ខ្សែទី១ = ១.០៨០ម

៥. សំណង់សិល្បការ

- ទ្វារទឹក ២៨កន្លែង (ធំ ១៧កន្លែង)
- លូ ៨៩កន្លែង
- ស្ពាក់ ១៧កន្លែង
- សំណង់បង្ហៀរ ២កន្លែង និងស្ពាន ១៧ កន្លែង។

៦. ស្ថានីយ៍បូមទឹកចំនួន ៥កន្លែង ដែលក្នុងនោះស្ថានីយ៍បូមទឹកសម្រាប់ស្រោចស្រព ៣កន្លែង និង២កន្លែងទៀតមានតួនាទីបូមរំដោះទឹកចូលទន្លេវិញពេលមានទឹកជំនន់កើតឡើងម្តងៗ។

**រូបភាព១៖ ទិដ្ឋភាពនៃការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក (មើលឧបសម្ព័ន្ធទី៣)**

**រូបភាព២៖ ទិដ្ឋភាពនៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែកដែលបានស្តារ និងសាងសង់ហើយ (មើលឧបសម្ព័ន្ធទី៤)**

**រូបភាព៣៖ ផែនទីបង្ហាញពីទីតាំងប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក (មើលឧបសម្ព័ន្ធទី១)**

**រូបភាព៤៖ ផែនទីបង្ហាញពីប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក(មើលឧបសម្ព័ន្ធទី២)**

### ២.២.២ ការគ្រប់គ្រងកិច្ចដំណើរការ និងការជួសជុលថែទាំ[52]

នាយកដ្ឋានធារាសាស្ត្រកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែងនៃក្រសួងធនធានទឹក និងឧតុនិយម បានចាប់ផ្តើមកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រនេះ ដោយផ្តល់វិធីសាស្ត្រដល់ការគ្រប់គ្រងប្រព័ន្ធទាំងមូល ដោយធ្វើការបណ្តុះបណ្តាលដល់មន្ត្រី និងប្រតិបត្តិករមូលដ្ឋាន ចាប់តាំងពីឆ្នាំ២០១៦មក ដើម្បីប្រើប្រាស់ឱ្យអស់នូវសក្តានុពលដែលមាន។ ក្នុងនេះដែរ នាយកដ្ឋានធារាសាស្ត្រកសិកម្ម នឹងផ្តល់នូវទស្សនវិស័យក្នុងការត្រួតពិនិត្យ ធ្វើអធិការកិច្ច និងសម្របសម្រួលការបណ្តុះបណ្តាល ដើម្បីធានាឱ្យកិច្ចដំណើរការ និងការថែទាំប្រព័ន្ធទាំងមូលប្រកបដោយភាពរលូន និងមានប្រសិទ្ធភាព។

ដើម្បីធានាបាននូវដំណើរការគ្រប់គ្រង និងការថែទាំប្រកបដោយប្រសិទ្ធភាព និងមាននិរន្តភាព ដើម្បីធានាដលការស្រោចស្រព នាយកដ្ឋានធារាសាស្ត្រកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែង នៃក្រសួងធនធានទឹក និងឧតុនិយម បានដាក់ចេញនូវផែនការដូចជា៖

[52] គម្រោងកិច្ចដំណើរការ និងការងារជួសជុលប្រព័ន្ធធារាសាស្ត្រការពារទឹកជំនន់ និងស្រោចស្រពកំពង់ត្របែក របស់នាយកដ្ឋានធារាសាស្ត្រកសិកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម,២០១៨, ទំព័រ៦-៨

១. ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់មន្ត្រី (ក្រសួង និងមន្ទីរ) បុគ្គលិកសម្រាប់កិច្ចដំណើរការនៅមូលដ្ឋានដែលរស់នៅក្នុងតំបន់នៃប្រព័ន្ធនោះ ដើម្បីជួយដល់ក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយម លើការងារគ្រប់គ្រង និងថែទាំប្រព័ន្ធ ព្រមទាំងការរក្សាទំនាក់ទំនងយ៉ាងជិតស្និតក្នុងការទទួលបាននូវព័ត៌មានពីតម្រូវការទឹកស្រោចស្រពរបស់កសិករ និងអាជ្ញាធរមូលដ្ឋាន។

២. ផ្តល់សេវាថែទាំជាប្រចាំមានៈ

- ការងារថែទាំសំណង់ស្ថានីយ៍បូមទឹក ០៥កន្លែង
- ជួសជុល និងថែទាប្រព័ន្ធមេកានិចក្នុង និងក្រៅស្ថានីយ៍
- ការថែទាំទំនប់សណ្តរទន្លេ (៣៦.០០០ម)
- ការងារថែទាំកន្លែងដក់ ជាំទឹកនៃខ្នងទំនប់សណ្តទន្លេប្រវែង ១.០០០ម
- ការថែទាំ រៀបថ្មធ្វើជាកូនប្រឡាយកន្លែងដក់ ជាំទឹកនៃខ្នងទំនប់សណ្តទន្លេ
- ជួសជុល និងថែទាំប្រឡាយមេចំនួន ៣ខ្សែ ប្រវែងសរុប ២២.១៩០ម៉ែត្រ
- ជួសជុល និងថែទាំប្រឡាយរងចំនួន ១២ខ្សែ ប្រវែងសរុប ៣១.២០ម៉ែត្រ
- ជួសជុល និងថែទាំសំណង់ទ្វាររំដោះទឹកជំនន់ ១៧កន្លែង (ទ្វារទឹកធំ)
- ជួសជុល និងថែទាំសំណង់ទ្វារទឹកស្រោចស្រពប្រឡាយមេ
- ជួសជុល និងថែទាំលូដោះទឹកនៅតាមបណ្តោយប្រឡាយមេ
- ជួសជុល និងថែទាំស្ពាននៅតាមបណ្តោយប្រឡាយមេ

៤. ដឹកនាំសិក្សាធ្វើផែនការ ដើម្បីកំណត់ការជ្រើសរើសប្រព័ន្ធ និងប្រឡាយនៅក្នុងតំបន់នីមួយៗ ឱ្យមានភាពពេញលេញ និងការគ្រប់គ្រងប្រព័ន្ធ។

៥. អ្នកពាក់ព័ន្ធត្រូវបន្តធ្វើការពិភាក្សាជាមួយកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំផែនការអនាគត សម្រាប់កែលម្អប្រព័ន្ធទាំងមូល។

៦. ការបើកទ្វារទឹកនៅទំនប់បង្វៀងដើម្បី

- ✓ ត្រួតពិនិត្យកម្រិតកម្ពស់ទឹក និងការពារទឹកពីការហូរកាត់ទំនប់
- ✓ រក្សាទឹកទុកសម្រាប់ស្រោចស្រព

៧. ការបើកទ្វារទឹកនៃសំណង់យកទឹកប្រឡាយមេធំនៅទំនប់បង្វែរទឹក

៨. ការបើកទ្វារទឹក ត្រួតពិនិត្យនៅលើប្រឡាយមេធំ ប្រឡាយមេ ប្រឡាយរង ដើម្បីឱ្យកសិករទទួលបានសេវាដែលពួកគាត់ត្រូវការ។

៩. ការបង្កើត និងការកសាងសមត្ថភាពនៃសហគមន៍កសិករប្រើប្រាស់ទឹក

១០. ការចូលរួមប្រជុំជាមួយ សហគមន៍កសិករប្រើប្រាស់ទឹក និងអ្នកពាក់ព័ន្ធដទៃទៀត ស្ដីពីបទបញ្ហាសំខាន់ៗ និងបញ្ហារបាយការណ៍។

១១. ការជួយដោះស្រាយទំនាស់រវាងអ្នកប្រើប្រាស់ទឹក

១២. រាយការណ៍ពីការខូចខាតដោយការកាប់បំផ្លាញទំនប់ ភ្លឺប្រឡាយ (ឧ. ការកាត់ផ្ដាច់ខ្នង ភ្លឺប្រឡាយ និងប្រឡាយដោះទឹក)

១៣. ការប្រមូលស្ថិតិផលិតផលដែលបានមកពីការស្រោចស្រព និងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

**រូបភាព៥៖ សកម្មភាពរបស់មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានធារាសាស្ត្រកសិកម្ម និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រៃវែងចុះធ្វើការកែលម្អរ និងជួសជុលថែទាំប្រចាំ (មើលឧបសម្ព័ន្ធទី៥)**

## ២.៣ ស្ថានភាពទូទៅនៅក្នុងតំបន់ធ្វើការស្រាវជ្រាវ

### ២.៣.១ ស្ថានភាពនៃស្ថានីយ៍បូមទឹកស្រោចស្រពទី២

ស្ថានីយ៍បូមទឹកស្រោចស្រពទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក មានទីតាំងស្ថិតនៅក្នុងភូមិកំពង់ថ្នល់ ឃុំល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែង។ ស្ថានីយ៍នេះមានលទ្ធភាពផ្គត់ផ្គង់ទឹកស្រោចស្រពលើផ្ទៃដីប្រមាណ ២,៧០០ហិកតា ក្នុងស្រុកចំនួន ៦ (ឃុំល្វា ឃុំរំចេក ឃុំដៃកំពក ឃុំអង្គររាជ្យ ឃុំសេនារាជឧត្តម និងឃុំក្រាំងស្វាយ) គិតជាភូមិប្រមាណ ៣៩ភូមិ។ ស្ថានីយ៍ផ្គត់ផ្គង់ទឹកស្រោចស្រពទី២ គ្របដណ្ដប់លើ ប្រឡាយមេធំទី២មួយខ្សែដែលមានប្រវែង ២,៨៥០ម៉ែត្រ ប្រឡាយមេ៣ខ្សែ ប្រវែង ៨,៥៦០ម៉ែត្រ ប្រឡាយរងដែលបានបង្កើតដោយសហគមន៍កសិករប្រើប្រាស់ទឹកចំនួន១៩ខ្សែ ដែលមានប្រវែងប្រមាណជា ៣១,០០០ម៉ែត្រ ទ្វារទឹកទទឹងប្រឡាយចំនួន ៧ និងស្ពានចំនួន ១២។ ស្ថានីយ៍ផ្គត់ផ្គង់ទឹកស្រោចស្រពទី២ មានតួនាទី៖

១. បូមទឹកពីទន្លេកំពង់ត្របែក ចូលទៅក្នុងប្រឡាយនៅពេលដែលប្រជាកសិករមិនមានទឹកគ្រប់គ្រាន់នៅក្នុងការទាញទឹកយកទៅស្រោចស្រពដំណាំ។

២. បូមទឹកពីប្រឡាយចូលទៅក្នុងទន្លេវិញ ក្នុងករណីមានទឹកជំនន់កើតឡើងម្ដងៗ

**រូបភាព៦៖ ទិដ្ឋភាពរបស់ស្ថានីយ៍បូមទឹកស្រោចស្រពទី២ (មើលឧបសម្ព័ន្ធទី៦,៧,៨,៩,១០,១១,១២)**

### ២.៣.២ ស្ថានភាពដំណាំស្រូវ

ព្រះស្ដេច គឺជាស្រុកមួយដែលស្ថិតក្នុងខេត្តព្រៃវែង និងគ្របដណ្ដប់លើឃុំចំនួន១១។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់នេះភាគច្រើនគឺប្រកបរបរកសិកម្ម ជាពិសេសដំណាំស្រូវ។ បច្ចុប្បន្ននេះ ផ្ទៃដីដំណាំដំណាំស្រូវវស្សាមានចំនួនប្រមាណ ៣៨,១៥៥ហិកតា និងស្រូវប្រាំងមាន

ចំនួន ១៥,០០០ហិកតានៅក្នុងឆ្នាំ២០១៧។ ប៉ុន្តែបើយើងមើលពីលទ្ធភាពនៃការផ្គត់ផ្គង់ទឹករបស់ស្ថានីយ៍បូមទឹកស្រោចស្រពទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក មានលទ្ធភាពស្រោចស្រពលើផ្ទៃដីដាំដុះដំណាំស្រូវបានប្រមាណជា ២៧០០ហិកតាប៉ុណ្ណោះលើឃុំចំនួន៦ (ឃុំល្វា ឃុំរំចេក ឃុំដៃកំពក ឃុំអង្គរាជ្យ ឃុំសេនារាជឧត្តម និងឃុំក្រាំងស្វាយ)។ ប្រជាកសិករដែលរស់នៅក្នុងតំបន់នោះ អាចធ្វើការដាំដុះដំណាស្រូវបានពីទៅពីរ ទៅបីដងក្នុងមួយឆ្នាំ។ ដោយសារតែពួកគាត់មានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពនៅក្នុងរដូវប្រាំង។ ចំពោះផលស្រូវវិញគឺពួកគាត់ទទួលបានទិន្នផលខ្ពស់ទាំងស្រូវប្រាំង និងស្រូវវស្សា។

**រូបភាព៧៖ ស្ថានភាពដំណាំស្រូវស្ថិតក្នុងតំបន់ស្រាវជ្រាវ (មើលឧបសម្ព័ន្ធទី១៣)**

### ២.៣.៣ ការប្រើប្រាស់ទឹក

ជាទូទៅ នៅក្នុងការទាញទឹកយកទៅប្រើប្រាស់ពីប្រឡាយក្នុងការស្រោចស្រពទៅលើដំណាំ គឺប្រជាកសិករជាអ្នកទទួលខុសត្រូវដោយខ្លួនឯង។ នៅពេលដែលមានកង្វះខាតទឹកប្រជាកសិករមួយ ឬពីរគ្រួសារមិនអាចទៅសុំការអន្តរាគមន៍បានទេ ហេតុនេះទើបតម្រូវឱ្យប្រជាកសិករបង្កើតជាសហាគមន៍កសិករប្រើប្រាស់ទឹក។ សហាគមន៍កសិករប្រើប្រាស់ទឹកមេបូព៌ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៦ ដែលមានតែមួយឃុំប៉ុណ្ណោះ គឺឃុំល្វា ក្រោយមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែកកាន់តែធំ នៅចុងឆ្នាំ២០១៧ សហាគមន៍នេះបានប្រែក្លាយឈ្មោះទៅជា សហាគមន៍កសិករប្រើប្រាស់ទឹកស្ថានីយ៍ទី២ ដែលមានចំនួន ៦ឃុំ (ឃុំល្វា ឃុំរំចេក ឃុំដៃកំពក ឃុំអង្គរាជ្យ ឃុំសេនារាជឧត្តម និងឃុំក្រាំងស្វាយ)បានចូលរួម។ ប្រជាកសិករដែលបានចូលរួមនៅក្នុងសហាគមន៍ ត្រូវចំណាយទៅលើថ្លៃសេវាប្រើប្រាស់ទឹកចំនួន ១០០,០០០រ ក្នុងមួយឆ្នាំ។

នៅក្នុងករណីដែលមានការខ្វះខាតទឹកស្រោចស្រព សហាគមន៍ត្រូវដាក់ពាក្យស្នើសុំតាមរយៈអនុប្រធានក្រុម រួចធ្វើការបញ្ជូនពាក្យស្នើសុំមកកាន់ស្ថានយ៍ទី២ ដើម្បីធ្វើការបូមទឹកពីទន្លេបញ្ចូលទៅក្នុងប្រឡាយដើម្បីធ្វើការសង្គ្រោះដំណាំស្រូវរបស់ប្រជាកសិករ។ នៅពេលដែលមានទឹកជំនន់កើតឡើង ដែលបណ្តាលឱ្យមានការលិចលង់ដំណាំរបស់ប្រជាកសិករ ប្រធានសហាគមន៍ត្រូវស្នើសុំ មន្ទីរធនធានទឹក និងឧតុនិយម ដើម្បីធ្វើការរំដោះទឹកចេញ ដោយបូមពីប្រឡាយចូលទៅកាន់ទន្លេវិញ។

**រូបភាព៨៖ ការទាញយកទឹកពីប្រឡាយរបស់កសិករនៅក្នុងរដូវប្រាំង (មើលឧបសម្ព័ន្ធទី១៤,១៥)**

## ២.៤អត្ថប្រយោជន៍ដែលទទួលបានក្រោយពីការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក[53]

ក្រោយពីបញ្ចប់ការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រនេះ យើងសង្កេតឃើញថាប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក បានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ប្រជាកសិករដែលស្ថិតនៅក្នុងគម្រោងនេះដូចជា៖

១. ដំណាំស្រូវទទួលបានទិន្នផលខ្ពស់

២. បង្កើនប្រាក់ចំណូលដល់ប្រជាកសិករ និងគ្រួសារនៅក្នុងតំបន់ស្រោចស្រព ដែលធ្វើឱ្យប្រជាកសិករមានជីវភាពប្រសើរជាងមុន ដែលជាកត្តាមួយក្នុងការកាត់បន្ថយការធ្វើចំណាកស្រុក

៣. ធ្វើឱ្យមានកំណើនដាំដុះក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ និងការចិញ្ចឹមសត្វ

៤. កិច្ចដំណើរការ និងថែទាំជាប្រចាំបានផ្តល់នូវស្តង់ដារនៃសេវាបញ្ជូនទឹកបានយ៉ាងប្រសើរ និងបង្កើនភាពជឿជាក់ដល់កសិករក្នុងការវិនិយោគ ការរៀបចំកសិដ្ឋាន និងប្រព័ន្ធដាំដុះរបស់ពួក គាត់។

៥. កាត់បន្ថយការប្តឹងតវ៉ា និងទំនាស់នៃទឹកស្រោចស្រព រវាងអ្នកប្រើប្រាស់ដែលទទួលបានទឹកច្រើនហួស។

៦. កែលម្អរសុវត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការរស់នៅ និងទ្រព្យសម្បត្តិឯកជនរបស់ប្រជាជនជាមូលដ្ឋានក្នុងអំឡុងពេលមានទឹកជំនន់។

៧. កាត់បន្ថយផលប៉ះពាល់ដល់ប្រជាជនដែលរស់នៅជិតព្រំប្រទល់តំបន់ស្រោចស្រព។

៨. ខ្នងទំនប់ប្រឡាយមានលក្ខណៈល្អប្រសើរ ដែលសម្រួលដល់ការងារដឹកជញ្ជូនផលិតផលទៅលក់នៅទីផ្សារ។

៩. ថែទាំ និងការពារធនធានធម្មជាតិនៅក្នុងតំបន់មូលដ្ឋាន។

១០. ផ្សព្វផ្សាយលក្ខណ្ឌវិនិយោគបានល្អប្រសើរ ដើម្បីអភិវឌ្ឍតំបន់មូលដ្ឋាន។

## ២.៥ គោលដៅបន្តនាពេលអនាគត

លោក យុន សាយឿន អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រៃវែង បានលើកឡើងថា អ្វីដែលយើងត្រូវធ្វើបន្តទៅខាងមុខនោះគឺ៖

- ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកដល់ផ្ទៃដីបង្កបង្កើនផល និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ មន្ទីរនឹងធ្វើការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកសម្រាប់ការងារកសិកម្ម ជាពិសេសដំណាំស្រូវ។

[53] គម្រោងកិច្ចដំណើរការ និងការងារជួសជុលប្រព័ន្ធធារាសាស្ត្រការពារទឹកជំនន់ និងស្រោចស្រពកំពង់ត្របែក របស់នាយកដ្ឋានធារាសាស្ត្រកសិកម្ម នៃក្រសួងធនធានទឹក និងឧតុនិយម,២០១៨, ទំព័រ៨-៩

- ជំរុញ និងផ្សព្វផ្សាយបច្ចេកទេសក្នុងការគ្រប់គ្រងធនធានទឹក និងពីរបៀបក្នុងការគ្រប់គ្រង និងថែទាំប្រព័ន្ធធារាសាស្ត្រដល់សហគមន៍កសិករប្រើប្រាស់ទឹក។
- បង្កើនសមត្ថភាពដល់សហគមន៍កសិករប្រើប្រាស់ទឹក ក្នុងការគ្រប់គ្រងធនធានទឹក និងពីរបៀបក្នុងការប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព។
- បន្តការពង្រីកប្រព័ន្ធធារាសាស្ត្រ ដើម្បីបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករ ក្នុងគោលបំណងកាត់បន្ថយការធ្វើចំណាកស្រុក។
- ជំរុញឱ្យមានការវិនិយោគពីដៃគូសហប្រតិបត្តិការអន្តរជាតិ និងផ្នែកឯកជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ការថែទាំ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម។

បន្ថែមលើសពីនេះទៀត បើយោងតាមការលើកឡើងរបស់លោកពូ កែវ ស្រេង ប្រធានសហគមន៍កសិករប្រើប្រាស់ទឹកស្ថានីយ៍ទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក បានលើកឡើងថា នៅក្នុងឆ្នាំ២០១៩ រូបគាត់ និងប្រជាកសិករ នឹងខិតខំប្រឹងប្រែង គឺធ្វើយ៉ាងណាពង្រីកប្រឡាយរងឱ្យមានយ៉ាងតិច ១៥០០ម៉ែត្រក្នុងមួយឃុំ ហើយពង្រីកផ្ទៃដីឱ្យបាន ៦០០០ហិកតា និងបន្ថយតម្លៃសេវាប្រើប្រាស់ទឹកមកនៅត្រឹម ៥០០០០៛ ក្នុងមួយឆ្នាំ និងថែទាំប្រព័ន្ធដែលមានស្រាប់ឱ្យបានល្អតាមដែលអាចធ្វើទៅបាន។

## ២.៦ សេចក្តីសន្និដ្ឋាន

សរុបជារួមមក យើងឃើញថាការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក គឺត្រូវចំណាយថវិកា និងធនធានមនុស្សអស់ជាច្រើន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះបាននាំមកនូវអត្ថប្រយោជន៍ជាច្រើនដល់ប្រជាកសិករ ពោលគឺមិនត្រឹមតែចំពោះវិស័យកសិកម្មប៉ុណ្ណោះទេ តែប្រព័ន្ធនេះក៏បានជួយសម្រួលដល់ប្រជាកសិករក្នុងការរស់នៅប្រចាំថ្ងៃផងដែរ ដូចជាការផ្តល់ទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងផ្លូវសម្រាប់ធ្វើដំណើរជាដើម។ លើសពីនេះទៅទៀត គឺវាបានជួយបង្កើនទិន្នផលដំណាំផ្សេងៗ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ពួកគាត់ ក៏ដូចជាចូលរួមបង្កើននូវសេដ្ឋកិច្ចក្នុងតំបន់ផងដែរ។

# ជំពូកទី៣

# ការវិភាគទិន្នន័យ

## ៣.១ វិធីសាស្ត្រវិភាគ

### ៣.១.១ ប្រៀបធៀបទិន្នផលស្រូវមុននិងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ

តារាង១៖បម្រែបម្រួលទិន្នផលស្រូវមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ

| ដំណាំស្រូវ | មុន | | ក្រោយ | |
|---|---|---|---|---|
| | ផ្ទៃដីដាំដំណាំស្រូវ | ទិន្នផល/ហ.ត | ផ្ទៃដីដាំដំណាំស្រូវ | ទិន្នផល/ហ.ត |
| ស្រូវវស្សា | ៣០០ | ២តោន/ហ.ត | ២០០០ | ៣តោន/ហ.ត |
| ស្រូវប្រាំង | ៣៥០ | ៣តោន/ហ.ត | ២៧០០ | ៤.៥តោន/ហ.ត |

ប្រភព៖ ទិន្នន័យចុះសម្ភាសន៍នៅក្នុងតំបន់ស្រាវជ្រាវ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តាមតារាងខាងលើនេះ យើងសង្កេតឃើញថា មុនពេលមានការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ប្រជាកសិករអាចធ្វើស្រែបានតែមួយដងក្នុងមួយឆ្នាំ ហើយទិន្នផលស្រូវវស្សាគឺបានតែ ២តោនក្នុងមួយហិកតា ចំណែកឯ ស្រូវប្រាំងវិញគឺទទួលបាន ៣តោនក្នុងមួយហិកតា។ ប៉ុន្តែក្រោយពេលមានការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រនេះ ប្រជាកសិករមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើស្រែបានពីរទៅបីដងក្នុងមួយឆ្នាំ ដោយសារតែមានទឹកគ្រប់គ្រាន់ បើនិយាយពីទិន្នផលវិញមានការកើនឡើងខ្លាំងមែនទែន ស្រូវវស្សាអាចទទួលបានទិន្នផល ៣តោនក្នុងមួយហិកតា ចំណែកឯស្រូវប្រាំងវិញគឺចន្លោះពី ៤ទៅ៥តោនក្នុងមួយហិកតា។ ការកើនឡើងនៃទិន្នផលនេះ គឺដោយសារការមានកន្លែងរដោះទឹកចេញសម្រាប់ស្រូវវស្សា និងមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពនៅរដូវប្រាំង។ សព្វថ្ងៃនេះ ភាគច្រើននៃការធ្វើស្រូវប្រាំង ប្រជាកសិករគាត់ជ្រើសរើសពូជស្រូវស្រាលមកធ្វើ (IR) ព្រោះដោយសារមានទឹកគ្រប់គ្រាន់ ហើយពូជនេះចំណាយរយៈពេលខ្លី និងទទួលបានទិន្នផលខ្ពស់។

ក្រាហ្វិក១៖ទិន្នផលស្រូវប្រចាំឆ្នាំគិតជាមធ្យមក្នុងមួយហិកតា (តោន)




ប្រភព៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង (មើលឧបសម្ព័ន្ធទី១៦, ១៧, ១៨, ១៩, ២០, ២១, ២២,២៣,២៤, ២៥, ២៦, ២៧)

តាមរយៈការប្រៀបធៀបទិន្នផលស្រូវប្រចាំឆ្នាំ មុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ យើងសង្កេតឃើញថា ទិន្នផលស្រូវមានការកើនឡើងខ្ពស់ទាំងស្រូវវស្សា និងស្រូវប្រាំង។ បើយើងមើលតាមក្រាហ្វិក យើងឃើញថា ស្រូវប្រាំងគឺមានទិន្នផលខ្ពស់ជាងស្រូវវស្សា។ គួរបញ្ជាក់ផងដែរថា ប្រជាកសិករនៅក្នុងតំបន់នេះ គឺភាគច្រើនប្រើពូជស្រូវ IR នៅរដូវប្រាំង ដោយសារពូជនេះចំណាយរយៈពេលខ្លី និងទទួលបានទិន្នផលខ្ពស់។ នៅក្នុងករណីនេះ មានសំណួរបានចោទសួរថា ហេតុអ្វីបានជាប្រជាកសិករមិនជ្រើសរើសយកពូជ IR ទៅធ្វើការដាំដុះនៅរដូវវស្សា បើពូជប្រភេទនេះចំណាយរយៈពេលខ្លី និងទទួលបានទិន្នផលខ្ពស់?

បើតាមការបញ្ជាក់របស់លោកស្រី គឹម លួន ប្រធានការិយាល័យកសិកម្មស្រុកព្រះស្ដេច បានលើកឡើងថា ភាគច្រើនប្រជាកសិករនៅតំបន់នេះ គឺពួកគាត់ប្រើពូជ IR សម្រាប់ការដាំដុះដំណាំស្រូវនៅក្នុងរដូវប្រាំង ដោយសារតែពូជនេះចំណាយរយៈពេលខ្លី និងទទួលបានទិន្នផលខ្ពស់ ប៉ុន្តែប្រជាកសិករ មិនហ៊ានប្រថុយជ្រើសរើសពូជប្រភេទនេះទៅធ្វើការដាំដុះនៅរដូវវស្សានោះទេ ដោយសារពូជប្រភេទនេះមានកម្ពស់ទាប មិនអាចធន់នឹងទឹកជំនន់បាននៅរដូវវស្សា។

### ៣.១.២ ប្រៀបធៀបចំណូលមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ

តើចំណូលរបស់ប្រជាកសិករប្រែប្រួលដូចម្តេចមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក? ខាងក្រោមនេះគឺជាតារាងដែលបង្ហាញពីការប្រែប្រួលចំណូលរបស់ប្រជាកសិករ។

តារាង២៖ ចំណូលរបស់ប្រជាកសិករមុនមានការពង្រីកប្រព័ន្ធធារាសាស្ត្រ

| ចំណូលជាមធ្យមមុនពេលមានប្រព័ន្ធធារាសាស្ត្រ | | | |
|---|---|---|---|
| ដំណាំស្រូវ | ផ្ទៃដីដាំដំណាំស្រូវ | ទិន្នផល/ហ.ត | តម្លៃស្រូវគិតជាមធ្យម ៨០០៛/គីឡូក្រាម |
| ស្រូវវស្សា | ៣០០ហ.ត | ២ | ១,៦០០,០០០៛ |
| ស្រូវប្រាំង | ៣៥០ហ.ត | ៣ | ២,៤០០,០០០៛ |
| សរុប | | | **៤,០០០,០០០៛** |

ប្រភព៖ ទិន្នន័យចុះសម្ភាសន៍នៅក្នុងតំបន់ស្រាវជ្រាវ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តារាង៣៖ ចំណូលរបស់ប្រជាកសិករក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ

| ចំណូលជាមធ្យមក្រោយពេលមានប្រព័ន្ធធារាសាស្ត្រ | | | |
|---|---|---|---|
| ដំណាំស្រូវ | ផ្ទៃដីដាំដំណាំស្រូវ | ទិន្នផល/ហ.ត | តម្លៃស្រូវគិតជាមធ្យម ៨០០៛/គីឡូក្រាម |
| ស្រូវវស្សា | ២០០០ហ.ត | ៣តោន | ២,៤០០,០០០៛ |
| ស្រូវប្រាំង | ២៧០០ហ.ត | ៤.៥តោន | ៣,៦០០,០០០៛ |
| សរុប | | | **៦,០០០,០០០៛** |

ប្រភព៖ ទិន្នន័យចុះសម្ភាសន៍នៅក្នុងតំបន់ស្រាវជ្រាវ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តារាង៤៖ បម្រែបម្រួលចំណូលកសិករមុន និងក្រោយពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រ

| ដំណាំស្រូវ | ចំណូលមុន | ចំណូលក្រោយ | កំណើនប្រាក់ចំណូល |
|---|---|---|---|
| ស្រូវវស្សា | ១,៦០០,០០០៛ | ២,៤០០,០០០៛ | ៨០០,០០០៛ |
| ស្រូវប្រាំង | ២,៤០០,០០០៛ | ៣,៦០០,០០០ | ១,២០០,០០០៛ |
| សរុប | **៤,០០០,០០០៛** | **៦,០០០,០០០៛** | **២,០០០,០០០៛** |

ប្រភព៖ ទិន្នន័យចុះសម្ភាសន៍នៅក្នុងតំបន់ស្រាវជ្រាវ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តាមរយៈការបង្ហាញអំពីតារាងខាងលើ នៅពេលដែលមិនទាន់មានការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ប្រជាកសិករនៅក្នុងតំបន់នោះដែលដីស្រែមួយហិកតា គឺពួកគាត់អាចទទួលបានចំណូលជាមធ្យមគឺ ៤,០០០,០០០៛។ ប៉ុន្តែក្រោយ មានការស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រនេះ យើងសង្កេតឃើញថា ចំណូលជាមធ្យមក្នុងមួយហិកតាគឺ ៦,០០០,០០០៛ ពោលគឺមានការកើនឡើង។ ហើយចំណូលនេះប្រែប្រួលតិច ឬច្រើនអាស្រ័យលើផ្ទៃដីដែលពួកគាត់ មាន។

តាមរយៈលទ្ធផលនេះ អាចបង្ហាញឱ្យឃើញថាការពង្រីកប្រព័ន្ធធារាសាស្ត្រពិតជាបានចូលរួមនៅក្នុងការបង្កើនទិន្នផលស្រូវពិតមែន អ្វីដែលសំខាន់គឺបានចូលរួមបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករផងដែរ។

## ៣.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារក្រោយមានការពង្រីកប្រព័ន្ធស្រោចស្រព

យោងតាមការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញថានៅមុនពេលមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ប្រជាកសិករមានការលំបាកខ្លាំងក្នុងការប្រកបរបរកសិកម្ម ជាពិសេសដំណាំ ស្រូវ។ នៅក្នុងរដូវវស្សា នៅពេលទឹកឡើងខ្លាំងចេញពីទន្លេកំពង់ត្របែក បានធ្វើឱ្យដំណាំស្រូវរបស់ពួកគាត់មានការលិចលង់ ព្រោះមិនមានកន្លែងរំដោះទឹកចេញ ជាហេតុធ្វើឱ្យខូចខាតដល់ដំណាំស្រូវ និងទទួលបានទិន្នផលទាប។ ចំណែកឯរដូវប្រាំងវិញ ប្រជាកសិករបានជួបប្រទះភាពខ្វះខាតទឹកសម្រាប់ស្រោចស្រពដំណាំ ដោយសារតែប្រឡាយរាក់ ដែលពិបាកនៅក្នុងការស្តុកទឹកទុកពេលដែលមានទឹកម្តងៗ។ ដោយសារតែបញ្ហាទឹកនេះហើយ ទើបធ្វើឱ្យប្រជាកសិករធ្វើស្រែបានតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ។ ពេលខ្លះទៀត ដោយសារតែខ្វះខាតទឹកខ្លាំងពេក ធ្វើឱ្យដំណាំស្រូវរបស់ពួកគាត់ស្អុក ហើយទទួលបានទិន្នផលទៀប ដែលទិន្នផលនេះ មិនអាចផ្តល់ឱ្យពួកគាត់នូវលទ្ធភាពគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមជីវិតនោះឡើយ ជាហេតុធ្វើឱ្យពួកគាត់បោះបង់ការធ្វើស្រែចំការដោយទុកដីទំនេរចោល ហើយសម្រេចចិត្តធ្វើចំណាកស្រុកទៅធ្វើការស៊ីឈ្នួលឱ្យគេជំនួសពីការធ្វើស្រែចំការ។

ក្រោយមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ប្រជាកសិករមានជីវភាពល្អប្រសើរជាងមុន ដោយសារពួកគាត់អាចបង្កបង្កើនផលច្រើនជាងមុន ២ទៅ៣ដង ក្នុងមួយឆ្នាំ ចំណែកឯទិន្នផលវិញគឺចន្លោះពី ៤ទៅ៥តោនក្នុងមួយហិកតាសម្រាប់ស្រូវប្រាំង។ បើតាមសម្តីរបស់លោកពូ កែវ ស្រេង ដែលគាត់ជាប្រធានសហគមន៍កសិករប្រើប្រាស់ទឹក និងរូបគាត់ក៏ជាកសិករមួយរូបផងនោះ លោកមានប្រសាសន៍ថា ភាគច្រើនគឺប្រជាកសិករធ្វើការដាំដុះស្រូវប្រាំង ព្រោះការដាំដុះនៅ

រដូវនេះមិនភ័យព្រួយរឿងអត់ទឹកធ្វើស្រែនោះឡើយ ដែលកសិករអាចធ្វើបានពីរទៅបីដងក្នុងមួយឆ្នាំ ចំណែកឯ ទិន្នផលវិញក៏ទទួលបានខ្ពស់។ ចំពោះពូជគាត់ថា កសិករចូលចិត្តប្រើពូជ IR ដោយសារតែវាចំណាយរយៈពេលខ្លី (២.៥-៣ខែ) ប៉ុណ្ណោះនឹងទទួលបានផល ហើយទិន្នផលខ្ពស់ទៀតផង។ លោកបានបន្តទៀតថា ក្រោយមានការពង្រីកប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក ប្រជាកសិករមានជីវភាពល្អប្រសើរជាងមុន ហើយបានកាត់បន្ថយនូវការធ្វើចំណាកស្រុកបានច្រើនផងដែរ។

## ៣.៣ អត្រាទាញរកភាគចំណេញផ្ទៃក្នុងនៃការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ (Internal Rate of Return = IRR)

**IRR** គឺជារូបមន្តមួយដែលគេប្រើដើម្បីទាញរកភាគចំណេញនៃការវិនិយោគទុន ដែលគេចង់ដឹងថា តើរយៈពេលប៉ុន្មានឆ្នាំទៅមុខទៀតទើបគេអាចទទួលបានផលចំណេញពីការវិនិយោគនេះ។ តើអ្នកវិនិយោគគួរទទួល ឬបដិសេធគម្រោងនៃការវិនិយោគ?

ខាងក្រោមនេះ គឺជាការវិនិយោគលើស្ថានីយ៍បូមទឹកស្រោចស្រពទី២ នៃប្រព័ន្ធធារាសាស្ត្រកំពង់ត្របែក។

១. ការិនិយោគទុនលើស្ថានីយ៍នេះអស់ទឹកប្រាក់ប្រមាណជា ៩,០០០,០០០ ដុល្លាសហរដ្ឋអាមេរិក

២. អត្រាការប្រាក់ 0% (កម្ចីអនុគ្រោះរបស់សាធារណរដ្ឋប្រជាមានិតចិន)

៣. ផ្ទៃដីដាំដុះដំណាំស្រូវដែលស្ថានីយ៍ទី២ ដែលមានលទ្ធភាពផ្គត់ផ្គង់ទឹកស្រោចស្រពលើ

- ស្រូវវស្សា ២០០០ហិកតា
- ស្រូវប្រាំង ២៧០០ហិកតា

៤. ចំណាយជាមធ្យមលើផលិតកម្មស្រូវក្នុងមួយហិកតា

- ស្រូវវស្សា $៣៥០
- ស្រូវប្រាំង $៤៥០

៥. ចំណាយលើការជួសជុល និងថែទាំប្រចាំ, ទិន្នផលស្រូវ, ចំណាយលើផលិតកម្មស្រូវ, ចំណូលលើផលិតកម្មស្រូវសម្រាប់ឆ្នាំ២០១៨,២០១៩ និង២០២០ គឺជាតម្លៃសន្និដ្ឋាន។

តារាង៥៖ ចំណាយ និងចំណូលលើផលិតកម្មស្រូវ

| ឆ្នាំ | ចំណាយលើការជួសជុល និងថែទាំប្រចាំ ($) | ទិន្នផលស្រូវគិតជាមធ្យម ក្នុងមួយហិកតា (តោន) | | ចំណាយលើ ផលិតកម្មស្រូវ គិតជាមធ្យមក្នុងមួយ ហ.ត ($) | | ចំណូលលើ ផលិតកម្មស្រូវ គិតជាមធ្យម ($) ក្នុងមួយ ហ.ត តម្លៃស្រូវមួយគីឡូ ៨០០៛ | |
|---|---|---|---|---|---|---|---|
| | | ស្រូវវស្សា | ស្រូវប្រាំង | ស្រូវវស្សា | ស្រូវប្រាំង | ស្រូវវស្សា | ស្រូវប្រាំង |
| ២០១៥ | ០ | ៣.០៩ | ៤.៧៧ | ៣៥០ | ៤៥០ | ៦១៨ | ៩៥៤ |
| ២០១៦ | ៦២,៦៦២ | ៣.១០ | ៤.៧៨ | ៣៥០ | ៤៥០ | ៦២០ | ៩៥៦ |
| ២០១៧ | ១៦២,៨១២ | ៣.២៨ | ៤.៨០ | ៣៥០ | ៤៥០ | ៦៥៦ | ៩៦០ |
| ២០១៨ | ១៤៥,១៥៧ | ៣.៣០ | ៤.៩០ | ៣៥០ | ៤៥០ | ៦៦០ | ៩៨០ |
| ២០១៩ | ១៥០,០០០ | ៣.៥០ | ៥.០០ | ៣៥០ | ៤៥០ | ៧០០ | ១០០០ |
| ២០២០ | ១៥០,០០០ | ៣.៥០ | ៥.០០ | ៣៥០ | ៤៥០ | ៧០០ | ១០០០ |

ប្រភព៖

- ក្រសួងធនធានទឹក និងឧតុនិយម (មើលឧសម្ព័ន្ធទី២៨, ២៩,៣០)
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង
- ទិន្នន័យចុះសម្ភាសន៍នៅក្នុងតំបន់ស្រោវជ្រាវ នៅថ្ងៃទី៣០ ខែមេសា ឆ្នា២០១៨

តារាង៦៖សរុបការចំណាយ និងចំណូលលើផលិតកម្មស្រូវ ទាញពីតារាង៥

| ឆ្នាំ | ចំណាយលើផលិតកម្មស្រូវប្រចាំឆ្នាំគិតជាមធ្យម (ដុល្លា) | ចំណូលលើផលិតកម្មស្រូវ ប្រចាំឆ្នាំគិតជាមធ្យម (ដុល្លា) | ចំណេញ/ខាត ប្រចាំឆ្នាំគិតជាដុល្លា |
|---|---|---|---|
| ២០១៥ | ១,៩១៥,០០០ | ៣,៨១១,៨០០ | ១,៨៩៦,៨០០ |
| ២០១៦ | ១,៩៧៧,៦៦២ | ៣,៨២១,២០០ | ១,៨៤៣,៥៣៨ |
| ២០១៧ | ២,០៧៧,៨១២ | ៣,៩០៤,០០០ | ១,៨២៦,១៨៨ |
| ២០១៨ | ២,០៦០,១៥៧ | ៣,៩៦៦,០០០ | ១,៩០៥,៨៤៣ |
| ២០១៩ | ២,០៦៥,០០០ | ៤,១០០,០០០ | ២,០៣៥,០០០ |
| ២០២០ | ២,០៦៥,០០០ | ៤,១០០,០០០ | ២,០៣៥,០០០ |

ប្រភព៖

- ក្រសួងធនធានទឹក និងឧតុនិយម
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង
- ទិន្នន័យចុះសម្ភាសន៍នៅក្នុងតំបន់ស្រាវជ្រាវ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

តារាង៧៖ ចំណេញពីផលិតកម្មស្រូវប្រចាំឆ្នាំ ទាញចេញពីតារាង៦

| ការវិនិយោគទុនដំបូងលើធារាសាស្ត្រ | $ ៩,000,000 |
|---|---|
| ចំណេញឆ្នាំទី១ (២០១៥) | $ ១,៨៩៦,៨០០ |
| ចំណេញឆ្នាំទី២ (២០១៦) | $ ១,៨៤៣,៥៣៨ |
| ចំណេញឆ្នាំទី៣ (២០១៧) | $ ១,៨២៦,១៨៨ |
| ចំណេញឆ្នាំទី៤ (២០១៨) | $ ១,៩០៥,៨៤៣ |
| ចំណេញឆ្នាំទី៥ (២០១៩) | $ ២,០៣៥,000 |
| ចំណេញឆ្នាំទី៦ (២០២០) | $ ២,០៣៥,000 |

**បកស្រាយលើរូបមន្ត IRR**

គណនាតាម Excell

=IRR (Values, [**Guess**] )

- បើសិនជារដ្ឋាភិបាលវិនិយោគទុនត្រឹមរយៈពេល ៣ឆ្នាំដំបូង គិតត្រឹមឆ្នាំ២០១៧ រដ្ឋាភិបាលខាត ២១% នៃប្រាក់វិនិយោគទុនដំបូង
